ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 28-Jan-2013, 10:21
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៣នាទី**

**សវនាការលើកទី ១៥១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

លោក ឌុច ផារី

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី
*(Ms. Faiza ZOUAKRI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វេង ហ៊ត់

លោក ឃីត រេយ៍ន័រ (*Mr.Keith RAYNOR*)

**ជនជាប់ចោទ៖**

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ(*Mr.Victor KOPPE*)

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡោ ជុនធី

លោក វ៉ែន ពៅ

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:០៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា សូមលោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី ដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ ដោយមូលហេតុសុខភាព។

ជនជាប់ចោទ នួន ជា និងជនជាប់ចោទ ខៀវ សំផន អវត្តមានដោយមូលហេតុសុខភាព តែតាមរយៈឯកសារលេខ E258/2 និង E223/4 ជនជាប់ចោទទាំងពីរបានលះបង់សិទ្ធិមានវត្តមានក្នុងអំឡុងពេលសវនាការលើឯកសារថ្ងៃនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការដាក់បង្ហាញឯកសារ។

**លោក ឃីត វេយ្យ័ន៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម!

ខ្ញុំសូមចាប់ផ្តើមដោយលើកឡើងអំពីឯកសារដែលយើងបានពិភាក្សាកាលពីម្សិលមិញ ដើម្បីចាប់ផ្តើមឯកសារ E3/781 គឺជាឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជាចុះថ្ងៃទី០៥ ចុះ១ខែ៩ ឆ្នាំ៧៥ ហើយខ្ញុំសូមជម្រាបផងដែរថា វាមានការពណ៌នាអំពីឯកសារនេះដែលជាការពិនិត្យទៅលើការត្រួតពិនិត្យ និងអនុវត្តមាគ៌ានយោបាយក្នុងការបង្កើននូវសេដ្ឋកិច្ច ក៏ដូចជាការកសាងប្រទេសនៅក្នុងគ្រប់ផ្នែកទាំងអស់។

[០៩:០៥:៥៥]

ខ្ញុំសូមចាប់ផ្តើមដោយនិយាយយោងទៅលើឯកសារដែលមានលេខ ERN ភាសាខ្មែរ 00072 373, ភាសាបារាំងគឺមានលេខ 00543749 និងភាសាអង់គ្លេសមានលេខ 00073573 ឯកសារនេះគឺជាឯកសារដែលយើងបានពិភាក្សាអំពីវាលស្រែ។ ហើយខ្ញុំសូមដកស្រង់ដូចតទៅនេះ "ហេតុអ្វីបានជាយើងត្រូវធ្វើទំនប់? មិនមែនដើម្បីគ្រាន់តែទប់ទឹកនោះទេ គឺយើងដើម្បីរក្សាដីឲ្យមានជីវជាតិ។ ទំនប់នេះក៏ប្រើប្រាស់ដើម្បីបង្កើននូវលក្ខណៈរបស់ជនបទ ដើម្បីធ្វើឲ្យសង្គមមានការរីកចម្រើន"។ ហើយក្នុងទំព័រដដែល ដែលមានខ្មែរ និងភាសាបារាំងមានលេខ ERN ដូចគ្នា 00523574 គឺមានការចោទសំណួរទៅលើឯកសារនេះ។

"សះ តើយើងត្រូវដាក់ប្រជាជននៅកន្លែងណា? ចម្លើយគឺនៅជួរបន្ទាប់ "ឆៈ យើងត្រូវធ្វើនៅកន្លែងណាដែលដីមានជីវជាតិ ហើយនិងអាចបង្កបង្កើនផលបានល្អ មិនមែនធ្វើនៅកន្លែងណាដែលពិបាក ឬក៏មិនអាចទទួលផលល្អ"។

[០៩:០៧:៥៥]

ការដកស្រង់បន្ទាប់ គឺនិយាយអំពីទឹក គឺភាសាខ្មែរមានលេខ 00772367 និងបារាំងមានលេខ 00543750, ភាសាអង់គ្លេសមាន 00523574 "នៅបាត់ដំបងឆ្នាំ១៩៧៦ ត្រូវឲ្យមានទឹកគ្រប់តំបន់វាលរាប ព្រោះនៅតាមតំបន់វាលរាបភាគច្រើនមានប្រភពទឹកជាប្រចាំ"។ ហើយប្រអប់ក្របាមបន្ទាប់ទៀតនៅក្នុងទំព័រដដែលគឺការដកស្រង់នូវប្រយោគតែមួយដែលមានដូចតទៅនេះ "នៅក្នុងឆ្នាំ១៩៧៧ ត្រូវធ្វើឲ្យបានផលពាលានក្នុងមួយហិកតា -- បីតោនក្នុងមួយហិកតា"។ ហើយបន្តទៅទៀតនេះទៅខ្មែរ ERN ដែលមានលេខ 00072376, ភាសាបារាំងគឺមានលេខ 00543752 និងភាសាអង់គ្លេសគឺមាន លេខ 00523576 "តាមការប៉ាន់កម្លាំងពលកម្មសព្វថ្ងៃ ៥លាននាក់ កម្លាំងនេះដកយកទៅធ្វើការងារផ្សេងៗ នៅសល់តែ ៤លាន៧សែននាក់។ ក្នុងកម្លាំងនេះយកមួយចំនួនទៅខាងផលិតកៅស៊ូ ចម្ការអំពៅ នៅសល់តែ ៤លាននាក់ទៀតត្រូវធ្វើដី ៣លានហិកតា បើពង្រីកទៅទៀតឡើង ៤លានហិកតា"។

[០៩:១០:១៤]

ហើយការដកស្រង់បន្តគឺមានលេខខ្មែរ 00072381, ភាសាបារាំងគឺមានលេខ 00543755 និងភាសាអង់គ្លេសគឺមានលេខ 00523579។ គឺចំណងជើងមាននិយាយថា "អំពីការប្រើប្រាស់កម្លាំងពលកម្ម និងចាត់ចែងកម្លាំងពលកម្ម"។ "កន្លងមកកន្លែងខ្លះចាត់ចែងកម្លាំងបានល្អ ប្រើមិនសល់ មិនឲ្យលើសខ្វះកម្លាំង។ ការបែងចែកកម្លាំងពលកម្មស្មើឲ្យបានល្អគ្រប់កន្លែងមួយៗ។ កម្លាំងពលកម្មចាត់តាំង

ជាក្រុមៗមានរបៀបរាបរយ ធ្វើដោយមានផែនការ មានមេក្រុម នាំឲ្យមានបរិយាកាសរីករាយសាមគ្គី។ ធ្វើយ៉ាងនេះជាពិសោធន៍មួយល្អ មានលក្ខណៈជាកម្មករវិទ្យាសាស្ត្រ ដែលយើងត្រូវតែផ្សាយពិសោធន៍នេះ និងរៀនសូត្រជាពិសោធន៍របស់យើង។ យើងចាត់កម្លាំងយ៉ាងនេះធ្វើឲ្យពួកថ្មីដែលចេញពីទៅក្រុងភ្នំពេញធ្វើជាមួយគេដែរ។ ឯពិសោធន៍មួយទៀត បានចាត់តាំងកម្លាំងប្រជាជនលើកគ្នាទៅធ្វើកន្លែងណាដែលមានទឹកល្អ ធ្វើបានសស្រាក់សស្រាំ”។

[០៩:១២:៣២]

ការដកស្រង់បន្តគឺមានលេខ 00072382, ភាសាបារាំងគឺមានលេខ 00543755 ដល់ 56 និងភាសាអង់គ្លេសគឺមានលេខ 00523580។ ឯកសារនេះបានធ្វើការប្រៀបធៀបរវាងតំបន់៥០ ដែលនៅជិតភ្នំពេញ ជាមួយនិងតំបន់ពាយ័ព្យ។ ហើយអត្ថបទ គឺមានដូចតទៅនេះ “នៅតំបន់១៥ ត្រូវមានទិសយកកម្លាំងប្រជាជន ៣ ឬ ៤០.០០០ មកធ្វើនៅតាមផ្លូវលេខ៥ កន្លែងនេះធ្វើបានមួយហិកតាបួនតោន នៅពាយ័ព្យអាចធ្វើបាន៣ទៅ៤តោន”។

ការដកស្រង់ឯកសារបន្តគឺខ្មែរមានលេខ 00072394, ភាសាបារាំងគឺមានលេខ 00543764 និងភាសាអង់គ្លេសគឺមានលេខ 00523588 “ក្រោយមកទៀតយើងលុបបំបាត់ភូមិ យើងមិនអនុញ្ញាតឲ្យមានភូមិទេ ហើយយើងធ្វើការរៀបចំសហករណ៍ជំនួសវិញ។ ដូច្នេះហើយគណៈភូមិ និងគណៈឃុំនឹងស្ថិតនៅក្នុងសហករណ៍។ ដូច្នេះហើយឃុំមិនត្រូវឲ្យមានការបែងចែកគ្នានោះឡើយ គេនឹងប្រើប្រាស់ធនធានរបស់សហករណ៍”។ ការដកស្រង់បន្តគឺខ្មែរមានលេខ 00072397, ភាសាបារាំងមានលេខ 00543766 និងភាសាអង់គ្លេសគឺមានលេខ 00523590 “នៅពាយ័ព្យត្រូវការកម្លាំងបន្ថែម ៥០០.០០០ នាក់ទៀត។ ព្រះវិហារស្មើ៥០.០០០ ចំពោះមុខសិន។ នៅព្រះវិហារមានលទ្ធភាពដោះស្រាយស្បៀងបាន។ ព្រះវិហារមានប្រជាជនចាស់ ៧០.០០០នាក់ហើយ។ ដូច្នេះបណ្ដើរៗជូន២០.០០០ សិន។ នៅឧត្តរក៏ត្រូវការប្រជាជន ផ្ដល់ឲ្យខេត្តកំពង់ធំ។ បូព៌ាក៏ត្រូវការកម្លាំងសម្រាប់ផ្ដល់ឲ្យតំបន់ដែលខ្វះខាតប្រជាជន។ ដូច្នេះភូមិភាគមួយៗត្រូវរៀបចំឲ្យសមស្របកុំឲ្យឃ្លោងម្ខាងៗ។ លៃសល់ប៉ុន្មានខាងលើនិងឥតយកទៅចែកកន្លែងផ្សេងៗទៀតទេ”។ ខ្ញុំសូមបញ្ចប់នូវឯកសារមួយនេះ។

[០៩:១៧:០៣]

ឯកសារបន្តគឺឯកសារ E190.1.318 ខ្មែរមានលេខ ERN 00708572, ភាសាបារាំងគឺមានលេខ 00780515 និងភាសាអង់គ្លេសគឺមានលេខ 00005151។ ហើយនេះគឺជាអត្ថបទមួយរបស់អ្នក

សារព័ត៌មាន វីល្លៀម សក្រូស ដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដី ហ្វាអ៊ិសស្ទើន អេកូណូមិក រីវ្យូ បោះពុម្ពផ្សាយនៅថ្ងៃ២ ខែមករា ឆ្នាំ៧៦។ អត្ថបទនេះគឺនិយាយអំពីព័ត៌មានទូទៅដែលទទួលបានពីជនភៀសខ្លួន គឺជនភៀសខ្លួនដែលបានមកដល់ប្រទេសថៃ ដែលមានចំនួនប្រហែលជា៣០នាក់ ក្នុង១សប្ដាហ៍។ ការដកស្រង់ទី១ គឺដូចតទៅនេះ ខ្ញុំសូមអាន ហើយការអានហ្នឹងគឺនិយាយអំពីជនភៀសខ្លួន។

“ជនភៀសខ្លួនពិតជាយល់ព្រមជាមួយនឹងវិទ្យុភ្នំពេញលើចំណុចមួយ ដែលថាជីវិតរាល់គ្នាគឺមិនសំខាន់ដល់ការប្រមូលទិន្នផលស្រូវនោះទេ”។ សូមដកស្រង់ “ចូរដាំៗគ្រប់យ៉ាង។ នេះគឺជាអ្វីដែលវិទ្យុបានប្រកាស។ ការចាប់អារម្មណ៍ជាពិសេសត្រូវតែផ្ដោតលើស្រូវតែប៉ុណ្ណោះ។ ស្រូវជាអ្វីៗគ្រប់យ៉ាង ស្រូវមានន័យថាជាដែក ជារោងចក្រ ជាថាមពល ជាប្រេងឥន្ធនៈ និងជាត្រាក់ទ័រ”។

វិទ្យុដដែល ដែលជាប្រភពផ្ដល់ព័ត៌មានផ្លូវការតែមួយក្នុងប្រទេសកម្ពុជាសព្វថ្ងៃ ទទួលស្គាល់ថា “នៅកន្លែងមួយចំនួន ជាក់ស្ដែងនៅព្រះវិហារស្ថានភាពស្រូវមិនសូវល្អ។ ទោះជាបែបនេះក្ដីទិន្នផលស្រូវបច្ចុប្បន្នត្រូវបានចាត់ថាជាទិន្នផលដែលល្អបំផុតរកគ្មាន ទោះបីជាគេត្រូវដាំវានៅចុងដៃ ចុងខែមេសា និងរហូតដល់ខែឧសភា ដោយកម្លាំងពលកម្មដែលគ្មានជំនាញ និងគ្មានឆន្ទៈក៏ដោយ”។

[០៩:២០:២៩]

ហើយយើងដកស្រង់នូវសម្រង់មួយទៀត ដែលយើងនឹងអាន “លោក អៀង សារី បានប្រាប់រដ្ឋាភិបាលថៃថា កម្ពុជាបានប្ដេជ្ញាចិត្តថានឹងក្លាយជាប្រទេសដែលមានស្រូវគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់តម្រូវការខ្លួនឯង។ ហើយការនេះគឺជាមធ្យោបាយមួយ ដែលជាកត្តាទី២នាំដល់ការជម្លៀសប្រជាជន”។ ជនភៀសខ្លួននិយាយថា “កាលពី២ខែមុន ប្រជាជនប្រមាណ ៣០០.០០០នាក់ ដែលត្រូវបានគេជម្លៀសពីភ្នំពេញនោះ ត្រូវគេជម្លៀសសាជាថ្មីទៀត ដែលលើកនេះត្រូវគេជម្លៀសទៅខេត្តបាត់ដំបង។ ការធ្វើដំណើរត្រូវគេមើលឃើញថា ធ្វើដោយផ្នែកៗ ខ្លះតាមទូក និងខ្លះទៀតតាមរថភ្លើង។ មានប្រជាជនល្មមប៉ុណ្ណោះដែលត្រូវគេទុកឲ្យធ្វើការក្នុងខេត្តភាគខាងត្បូងនិងភាគខាងកើតទីក្រុងភ្នំពេញ ដើម្បីច្រូតកាត់ស្រូវដែលគេបានដាំកាលពីដើមរដូវក្ដៅ។ ចំណែកអ្នកដែលនៅសល់ពីនោះ គឺត្រូវគេបញ្ជូនទៅតំបន់ដីមានជីវជាតិបំផុតក្នុងប្រទេស ដើម្បីពង្រីកទិន្នផលស្រូវនារដូវប្រាំងឆ្នាំក្រោយ”។

[០៩:២២:៥៣]

យើងសូមបញ្ចប់ឯកសារនេះ ហើយឯកសារបន្តគឺឯកសារ D199/26.2.184 ខ្មែរមានលេខ 00548749, ភាសាបារាំងគឺមានលេខ 00389829, ភាសាអង់គ្លេសគឺមានលេខ 00519810។ នេះគឺ

ជាអត្ថបទរបស់អ្នកសារព័ត៌មានដែលធ្វើការផ្សព្វផ្សាយតាមសារព័ត៌មាន។ ឯកសារនេះគឺចុះនៅថ្ងៃ២១ មករា ឆ្នាំ១៩៧៦។ ឯកសារមានចំណងជើងថា "កម្ពុជា៖ ការជម្លៀសប្រជាជនដោយបង្ខំជាថ្មីម្តងទៀត ដែលបង្កគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស" បើតាមកាសែតញូវយ៉កថែមស៍ នៅក្នុងសារឆ្លើយឆ្លងព័ត៌មានខ្លីមួយដែលបានធ្វើនៅទីក្រុងតូចមួយរបស់ថៃនៅជាប់ព្រំដែន ឈ្មោះ អារាញ់ប្រាថេត បាននិយាយថា "កាលពីថ្ងៃពុធ កាសែតញូវយ៉កថែមស៍ បានរាយការណ៍ថា ប្រជាជនកម្ពុជារាប់សែននាក់ត្រូវបានជម្លៀសដោយបង្ខំសាជាថ្មី ពីទីកន្លែងមួយទៅទីកន្លែងមួយថ្មីទៀតក្នុងប្រទេស ហើយមានអ្នកជម្លៀសមួយចំនួនធំបានបាត់បង់ជីវិតក្នុងដំណើរជម្លៀសដ៏សែនលំបាកនោះ"។

[០៩:២៥:០០]

កាសែតញូវយ៉កបានបន្តទៀតថា "ជាទូទៅប្រជាជនត្រូវបានគេជម្លៀសដោយបង្ខំ ឆ្ពោះទៅកាន់តំបន់ដែលពុំសូវមានប្រជាជន និងដែលមានការអភិវឌ្ឍតិចតួចនៅខេត្តបាត់ដំបង ពោលគឺនៅភាគពាយ័ព្យ (ស៊ីក) នៃប្រទេសកម្ពុជា។ បើតាមប្រភពព័ត៌មានពីជនភៀសខ្លួនម្នាក់ ដែលបានរត់ភៀសខ្លួនចេញពីប្រទេសកាលពីថ្ងៃទី០៦ ខែមករា បានឲ្យដឹងថាប្រជាជនដែលត្រូវបានគេជម្លៀសនោះ មួយចំនួនធំដែលភាគច្រើនជាកសិករ បានទទួលរងនូវជំងឺតម្កាត់នានា ដូចជាគ្រុនចាញ់ គ្រុនពោះវៀន អាសន្នរោគ រាកមួលជាដើម។ បើតាមសម្តីរបស់ជនភៀសខ្លួនម្នាក់ ដែលជាគិលានុបដ្ឋាកអាយុ៣៣ឆ្នាំ បានឲ្យដឹងថាមានប្រជាជនភៀសខ្លួនចំនួន៦០០នាក់ បានស្លាប់ក្នុងខែដែលពួកគេបានមកដល់តំបន់ភ្នំស្រុក ដែលគាត់ក៏ស្ថិតនៅទីនោះដែរ"។

[០៩:២៦:១១]

កាសែតបានសរសេរទៀតថា "ការជម្លៀសប្រជាជនដោយបង្ខំជាថ្មីម្តងទៀត ដែលបានធ្វើឡើងក្នុងទ្រង់ទ្រាយធំ ដូចការជម្លៀសប្រជាជននៅភ្នំពេញកាលពីខែមេសាមុនដែរ និងត្រូវបានគេចាប់ផ្តើមអនុវត្តនាដំណាច់ខែតុលា ដើមខែវិច្ឆិកា"។ តាមរយៈសក្ខីកម្មដែលទទួលបានពីញូវយ៉កថែមស៍បានឲ្យដឹងថា "ជាទូទៅប្រជាជនជម្លៀសទទួលបានតែបាយបរិភោគប៉ុណ្ណោះ ហើយពួកគេស្ថិតនៅក្រោមការឃ្លាំមើលរបស់កងយោធាប្រដាប់ដោយអាវុធ។ អ្នកដែលធ្វើដំណើរតាមរថភ្លើង ត្រូវបានគេដាក់នៅក្នុងទូរថភ្លើងដែលចង្អៀត ដូចជាត្រីដែលគេដាក់ក្នុងកន្ត្រក បើយោងតាមជនភៀសខ្លួន។ អ្នកដទៃទៀតត្រូវបានគេជម្លៀសទៅកាន់ទីកន្លែងថ្មីដោយថ្មើរជើង ដោយរទេះគោ ឬដោយរថយន្តកាំម៉ុង។ ក្នុងចំណោមអ្នកជម្លៀសទាំងនោះ មួយភាគធំបានស្លាប់បាត់បង់ជីវិត ដោយសារជំងឺ ឬក៏ដោយសារភាពទ្រុឌទ្រោម

ក្នុងពេលធ្វើដំណើរជាច្រើនយប់ច្រើនថ្ងៃនោះ។

[០៩:២៧:៥២]

ឯកសារបន្តគឺឯកសារ E3/1181 ខ្មែរមានលេខERN 00214486, ភាសាបារាំងគឺមានលេខ 00612289, និងភាសាអង់គ្លេសគឺមានលេខ 00223175។ នេះគឺជារបាយការណ៍ដែលមានចំណងជើងថា “ទិដ្ឋភាពរួមនៅតំបន់៥ ភូមិភាគពាយ័ព្យ”។ យើងឥឡូវនេះយើងទៅដល់ពេលវេលាមួយគឺនៅថ្ងៃ២៧ ខែមិថុនា ឆ្នាំ៧៦ ហើយឯកសារនេះបាននិយាយអំពីផលប៉ះពាល់នៃការជម្លៀសទាក់ទងទៅនឹងចំនួនប្រជាជននៅក្នុងស្រុកជាច្រើនក្នុងភូមិភាគពាយ័ព្យ។ នៅតំបន់៥ យើងសូមបញ្ជាក់ថា តំបន់៥មានប្រជាជនចំនួន ៣៧៧.០០០នាក់ ហើយក្នុងឯកសារនេះក៏បានរៀបរាប់ពីតំបន់ថ្មពួក ខ្មែរមានលេខឯកសារ 0014488 (ស៊ីក) ភាសាបារាំងគឺមានលេខ 00612290, ចំណែកភាសាអង់គ្លេសគឺមានលេខ ERN ដូចនឹងអ្វីដែលខ្ញុំបានអានពីមុន។ នៅថ្មពួក គឺជាអ្វីដែលឯកសារនេះបានលើកមកនិយាយៈ “ប្រជាជនភាគច្រើនក្នុងស្រុកនេះទើបតែរំដោះក្នុងខែ១ ខែ២ ៧៥ ហើយនិងប្រជាជនក្រោយ១៧ ស្ទើរតែ១០០ភាគរយ”។

ឯកសារបន្ទាប់ ឯកសារខ្មែរគឺលេខ 00214489, បារាំង 00612290, អង់គ្លេសមានលេខ 00223176 និយាយអំពីស៊ីសុផុន “ប្រជាជនមានជាង៥០.០០០នាក់ ថ្មីស្ទើរតែ១០០ភាគរយ”។ ឯកសារខ្មែរមួយទៀតគឺ 00214490, បារាំងមានលេខ 00612291, អង់គ្លេសមានលេខដដែលដូចមុន។ នៅពេលនេះនិយាយអំពីភ្នំស្រុក ដែលខ្ញុំបានលើកឡើងមុននេះបន្តិចហើយនៅក្នុងថ្ងៃនេះ គឺភ្នំស្រុក “មានប្រជាជនជាង៧០.០០០នាក់ ប្រជាជនចាស់មានប្រហែល៣០០គ្រួសារ ទៅពីភ្នំពេញប្រហែល ៥០.០០០ប្លាយ។ ប្រជាជនថ្មីក្នុងស្រុកមានជាង ២០.០០០”។ នៅក្នុងទំព័រដដែលនៅក្នុងប្រអប់ពណ៌ក្រហមគឺនិយាយអំពីស្រុកមួយទៀត គឺស្រុកព្រះនេតព្រះ “ប្រជាជនមុន១៧ មេសា មាន១៥០គ្រួសារ ចេញទៅភ្នំពេញជាង ៧០.០០០នាក់”។

[០៩:៣២:២៨]

ហើយខ្មែរ -- ហើយប្រអប់ពណ៌ក្រហមដដែលត្រង់ខ្មែរលេខ ERN។ដដែល គឺបានសរសេរឡើងថា “ប្រជាជនអត់ឃ្លានជាងគេទាំងអស់ ឆ្នាំទៅស្លាប់អស់ជាង ២០.០០០នាក់”។ ខ្ញុំសូមលើកឡើងឯកសារចុងក្រោយបំផុតនៅក្នុងបទបង្ហាញនេះ ដែលខ្ញុំបានលើកបង្ហាញលេខយោងរួចមកហើយ គឺរបាយការណ៍របស់អង្គការលើកលែងទោសអន្តរជាតិ។ ឯកសារមានលេខ E3/3316 ខ្មែរដែលមាន

លេខ ERN ពាក់ព័ន្ធគឺ 00591055, បារាំងមានលេខ 00607929 ហើយអង់គ្លេសមានលេខ 00419 921។ ឯកសារជាភាសាខ្មែរមានសរសេរដូចតទៅ “មានរឿងរ៉ាវរបស់ជនភៀសខ្លួនជាច្រើននាក់ស្ដីពីប្រជាជនស៊ីវិលបែបនេះជាច្រើននាក់ដែលត្រូវបានជម្លៀសចេញ និងក្រោយមកទៀតគេមិនបានឮដំណឹងអ្វីពីពួកគេទៀតឡើយ។ ហើយជនភៀសខ្លួនជឿជាក់ថាពួកគេទាំងអស់ត្រូវបានសម្លាប់ចោលអស់ហើយ។ អ្នកសង្កេតការណ៍មួយចំនួនបានចង្អុលបង្ហាញថា វាអាចកើតមានឡើងបានថាប្រជាជនជាច្រើននាក់បានបាត់ខ្លួន ផ្អែកតាមការជម្លៀសដោយបង្ខំឱ្យទៅធ្វើការងារនៅតំបន់ដាច់ស្រយាល។ រហូតមកទាល់បច្ចុប្បន្ននេះមានរបាយការណ៍ស្ដីពីទេសន្តប្រវេសដោយបង្ខំឥតឈប់ឈរ”។

[០៩:៣៤:២៥]

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព! ខ្ញុំសូមបញ្ចប់ការបង្ហាញឯកសាររបស់ខ្ញុំទាំងអស់នៅត្រឹមពេលនេះ។ យើងបានឮច្រើនហើយអំពីបញ្ហាស្រូវ ដូច្នេះនៅពេលនេះ ខ្ញុំសូមអនុញ្ញាតពីក្រុមប្រឹក្សាជំនុំជម្រះ និងលោកប្រធានឱ្យខាងអង្គភាពសោតទស្សន៍ចាក់ខ្សែវីដេអូលេខ១២។ បាទ ចំពោះលេខឯកសារគឺ E3/3011R ខ្សែវីដេអូនេះមានចំណងជើងថា *“ឡា វិក្ទូលត៍ ឌុយ រីស”*។

សូមអនុញ្ញាតពីលោកប្រធានចាក់ខ្សែវីដេអូលេខ១២ នេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! អ្នកបច្ចេកទេសសោតទស្សន៍ចាក់ផ្សាយវីដេអូក្លីបលេខ១២ តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[០៩:៣៥:៣០]

*(ការបង្ហាញឯកសារជាវីដេអូលេ១២)*

[០៩:៣៩:៤៥]

**លោក ឃីត វេយ៍ន័រ៖**

លោកប្រធានជាទីគោរព! ដល់ត្រង់ចំណុចនេះ គឺដល់កន្លែងដែលខ្ញុំបញ្ចប់ការបង្ហាញឯកសាររបស់យើងខ្ញុំហើយ។ សូមអរគុណច្រើនលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា!

ហើយជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋ-

ប្បវេណី ដើម្បីមានឱកាសក្នុងការធ្វើការបង្ហាញបំពេញបន្ថែម លើឯកសារដែលតំណាងសហព្រះរាជអាជ្ញាបានដាក់បង្ហាញកន្លងមកនេះ ឬក៏បង្ហាញឯកសារលើប្រធានបទផ្សេងៗដែលពាក់ព័ន្ធ នឹងអង្គជំនុំជម្រះកំណត់សម្រាប់ក្នុងការដាក់បង្ហាញឯកសារនៅក្នុងកិច្ចដំណើរការសវនាការនេះ។

សូមអញ្ជើញបាទ!

[០៩:៤០:៣៨]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។ ខ្ញុំសូមចាប់ផ្តើមបង្ហាញឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសូមបញ្ជាក់ថា ដូចដែលយើងធ្លាប់បានធ្វើជាច្រើនលើកច្រើនសារួចមកហើយ យើងជ្រើសរើសក្នុងការបង្ហាញឯកសារដែលជាសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមាននៅក្នុងពាក្យសុំតាំងខ្លួនរបស់ពួកគាត់ ដែលបានផ្តល់នូវព័ត៌មានអង្គហេតុសំខាន់ៗពាក់ព័ន្ធនឹងប្រធានបទដែលយើងជំនុំជម្រះ។

ខ្ញុំធ្វើការជ្រើសរើសដោយមានកម្រិតដោយស្ម័គ្រចិត្ត ដោយសារតែពេលវេលាខ្លី ដូច្នេះខ្ញុំបង្ហាញតែបន្តិចបន្តួចទេ ដើម្បីឲ្យកិច្ចដំណើរការសវនាការនេះប្រព្រឹត្តិទៅបានលឿន។ អង្គជំនុំជម្រះបានដឹងរួចមកហើយ ដូចគាត់ -- ក៏ប៉ុន្តែចំពោះដើមបណ្តឹងរដ្ឋប្បវេណីជាង៣.០០០នាក់ ដែលខ្ញុំចង់បញ្ជាក់ថាដោយសារយើងជ្រើសរើសតែសេចក្តីថ្លែងការណ៍តែមួយចំនួននោះ ដោយសារតែថាយកតិចនេះមិនមែនបានន័យថាសេចក្តីថ្លែងការណ៍ផ្សេងទៀតមិនសំខាន់នោះទេ។ ដើមបណ្តឹងរដ្ឋប្បវេណីខ្លះត្រូវបានស្តាប់ចម្លើយរួចមកហើយ ដូច្នេះខ្ញុំសូមអភ័យទោសផងដែរ ចំពោះសេចក្តីថ្លែងការណ៍មួយចំនួនដែលនឹងត្រូវស្តាប់ចម្លើយដោយអង្គជំនុំជម្រះនៅពេលក្រោយ។ ខ្ញុំសូមបង្ហាញជាដំបូងពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធយោធា ជាពិសេសពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខដែលបង្កើតបានជាធាតុផ្សំនៃរចនាសម្ព័ន្ធយោធា ហើយខ្ញុំមិននិយាយលម្អិតអំពីអ្វីដែលកើតឡើងនៅក្នុងមន្ទីរសន្តិសុខនោះទេ។ ខ្ញុំគ្រាន់តែនិយាយអំពីរបៀបដែលគេនាំ -- របៀបដែលគេដាក់បញ្ចូលសន្តិសុខនេះនៅក្នុងរចនាសម្ព័ន្ធយោធា។

[០៩:៤២:៤៤]

ឯកសារទី១ ដែលខ្ញុំចង់បង្ហាញជូននោះ គឺឯកសារលេខ D22/100។ ខ្ញុំសូមអាននូវសម្រង់ដែលមានលេខ ERN ជាភាសាបារាំង 00850531 ទៅដល់ 00850532, ជាភាសាអង់គ្លេស 00369510 ទៅដល់ 00369511, ជាភាសាខ្មែរ 00358174 ទៅដល់ 00358176។ សម្រង់នេះមានដូចតទៅនេះ

ដូច្នេះខ្ញុំសូមការអនុញ្ញាតបង្ហាញជាភាសាខ្មែរ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានឆ្លើយថា "ថ្ងៃ១៧ មេសា ៧៥ នៅម៉ោងប្រាំពីរព្រឹក ខ្ញុំបានឃើញទាហានខ្មែរក្រហមស្លៀកពាក់ខោអាវខ្មៅដើរ និងជិះម៉ូតូពាសពេញផ្លូវមុខផ្ទះខ្ញុំ។ ហើយទាហានទាំងនោះដើរប្រាប់ប្រជាជនឲ្យចេញពីក្រុងកំពង់សោម ដោយមិនចាំបាច់យកអីវ៉ាន់ទៅច្រើនទេ ពីព្រោះនៅទីនោះមានអង្គការចិញ្ចឹមពួកអ្នកទាំងអស់គ្នាហើយ។ ពេលនោះឪពុកម្តាយខ្ញុំរៀបចំអីវ៉ាន់យកទៅជាមួយបានបន្តិចបន្តួច។ នៅរសៀលនៅឆ្នាំ៧៦ ពូរបស់ខ្ញុំ លីន បានមកប្រាប់ម្តាយខ្ញុំ ថាអង្គការបានចាប់ឪពុកខ្ញុំប្រហែលជាម៉ោងប្រាំបួន នៅពេលដែលពួកគាត់ នៅពេលដែលគាត់រែកដីទៅទំនប់ខ្នាឯង នៅម៉ោងប្រាំមួយល្ងាច ទាហាន ហើយនិងប្រធានអង្គភាពបានមកផ្ទះខ្ញុំ ហើយបានរុញខ្ញុំទម្លាក់ពីជណ្តើរដែលខ្ញុំអង្គុយ ហើយពួកគេចាប់ម្តាយខ្ញុំ។ ពួកគេចង់ចងគាត់ ក៏ប៉ុន្តែកូនៗយំ ដូច្នេះពួកគេក៏បណ្តើរទៅកន្លែងបើកអង្ករនៅក្នុងឃុំស្រែចាម។ ពេលនោះប្អូនខ្ញុំប្រាំ មួយនាក់នៅតូចៗទាំងអស់ ដើរបណ្តើរ យំបណ្តើរ ដោយដើរកាត់ភ្លៀងផង។ ពេលដល់កន្លែងបើកអង្ករ ខ្ញុំឃើញមនុស្សនៅទីនោះ ប្រហែលប្រាំបួនគ្រួសារ ដោយពុំមានឪពុកទេ។ ឪពុកត្រូវបានពួកវាចាប់ទៅមុន។ គ្រួសារដែលអង្គការចាប់ សុទ្ធតែអ្នក១៧មេសា។ ពេលយប់ពួកគេយកទៅវត្ត ហើយទុកនៅទីនោះ២យប់ ដើម្បីចាំទៅចូលរួមជាមួយនឹងគ្រួសារ២៧ផ្សេងទៀត។ នៅម៉ោងម្ភៃពួកគេដឹកតាមឡាន ទៅគុកតានៃដែលស្ថិតនៅភូមិតានៃ ឃុំជើងគោ ស្រុកព្រៃនប់ ខេត្តកំពត"។ ដើមបណ្តឹងរដ្ឋប្បវេណី នេះបានបន្ថែមទៀតថា "នៅក្នុងគុកមានបន្ទប់បួន ហើយមានអ្នកទោសនោះគឺថាជាង១០០នាក់"។

[០៩:៤៦:៥៤]

ឯកសារទី២ ដែលខ្ញុំចង់បង្ហាញជូននោះ គឺពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខដដែល។ គឺពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខគោកក្តួច គឺឯកសារលេខ D22/186។ សម្រង់ដែលខ្ញុំចង់អាននោះគឺស្ថិតនៅ ERN ជាភាសាបារាំង 00816822 ទៅដល់ 23, ជាភាសាអង់គ្លេស 00417896 ទៅដល់ 97, ជាភាសាខ្មែរ 00387631។ ដើមបណ្តឹងរដ្ឋប្បវេណីមានអាយុ៣០ឆ្នាំ នៅឆ្នាំ៧៧។ គាត់បានបញ្ជាក់ប្រាប់យើងថា "នៅឆ្នាំ១៩៧៧ ខ្ញុំនិងប្រពន្ធរបស់ខ្ញុំ ដែលពេលនោះមានជំងឺក្អក ត្រូវបានទាហានខ្មែរក្រហមចាប់ដាក់គុក ដោយចោទខ្ញុំថាជាខ្មាំង ព្រោះខ្ញុំបានប្រាប់គេថា ខ្ញុំជាគ្រូបង្រៀន។ គេបានដឹកខ្ញុំទាំងពីរនាក់តាមរទេះគោទៅដល់បន្ទាយទាហាន នៅតំបន់ប្រាស្រាល ស្រុកសំបូរ ខេត្តក្រចេះ។ ពេលចុះពីរទេះគេបំបែកប្រពន្ធខ្ញុំចេញពីខ្ញុំភ្លាម។ នៅពេលដែលគេចាប់ខ្ញុំ គេដាក់ខ្នោះដៃដោយចងក្រពាត់ដៃខ្ញុំទៅក្រោយ យកក្រមាចងមុខរបស់ខ្ញុំ ហើយភ្ជង់នឹងកាំភ្លើង។ ទៅកន្លែងឃុំឃាំង ខ្ញុំបានឃើញខ្ទមមួយ ដែលនៅក្នុងនោះមានគ្រែ

មួយដែលមានមនុស្សជិត១០នាក់ ត្រូវបានដាក់ខ្នោះដៃ និងខ្នោះជើងរួមគ្នា ហើយកំពុងដេកនៅលើគ្រែនោះ។ ខ្ញុំ គេឃុំខ្ញុំនៅទីនោះអស់រយៈពេល១អាទិត្យ ដោយគ្មានប្រាប់ពីមូលហេតុនៃការចាប់ខ្លួនឡើយ។ ក្រោយមកគេបានអប់រំខ្ញុំ ព្រមទាំងតម្រូវឲ្យខ្ញុំធ្វើស្រែ លើកទំនប់ ក្នុងម្នាក់បីម៉ែត្រគូបក្នុង១ថ្ងៃ។ ក្រោយទៀតគេបានបញ្ជូនប្រពន្ធខ្ញុំ និងកូនមកដាក់ក្នុងគុកជាមួយខ្ញុំដែរ។ ខ្ញុំបានសង្កេតឃើញថា អ្នកទោសបានបាត់ខ្លួនជាញឹកញាប់។

[០៩:៥០:១៤]

ឯកសារទី៣ ដែលខ្ញុំចង់បង្ហាញជូននោះ ជាពាក្យសុំតាំងខ្លួនរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយឯកសារនេះពាក់ព័ន្ធនឹងមន្ទីរសន្តិសុខផងដែរ គឺដើមបណ្ដឹងរដ្ឋប្បវេណីដែលមានលេខ D22/8។ សម្រង់ដែលខ្ញុំចង់អាននោះគឺមាននៅលេខ ERN ជាភាសាបារាំង 00343764, ERN ជាភាសាអង់គ្លេស 00156813, ERN ជាភាសាខ្មែរ 00152355។ សម្រង់នេះមានដូចតទៅ "ដើមឆ្នាំ៧៦ ទាហានខ្មែរក្រហមស្លៀកខ្មៅបាននាំ មិត្តហាក់ ដែលជានាយកសាលាបច្ចេកទេសឫស្សីកែវ ដឹកតាមឡានហ្ស៊ីប តែមិនដឹងដឹកទៅណាទេ។ បន្ទាប់មកពួកភូមិភាគនិរតីបានមកធ្វើជានាយកគ្រប់គ្រងសាលានោះជំនួសវិញ។ ១សប្តាហ៍ក្រោយមក ខ្ញុំ ប្រពន្ធខ្ញុំ និងមនុស្សជាច្រើនទៀតនៅក្នុងសាលាបច្ចេកទេសនោះ ត្រូវបានខ្មែរក្រហមដឹកតាមឡានកាំម៉្យុងមកសហករណ៍តាឡី ដែលស្ថិតនៅក្នុងភូមិតាឡី ឃុំដង្កោ ស្រុកដង្កោ ខេត្តកណ្ដាល ជាកន្លែងលត់ដំប្រជាជនឲ្យធ្វើការ។ ខ្ញុំត្រូវធ្វើការលត់ដំ មានដូចជាធ្វើស្រែ ដាំបន្លែដើមឈើ ...។ល។ ខ្ញុំត្រូវជីកប្រឡាយ។ ខ្ញុំធ្វើការពីម៉ោងប្រាំមួយ ដល់ម៉ោងដប់មួយហូបបាយរួម។ ជួនកាលបាយជួនកាលបបរជាមួយនឹងសម្លសម្បុរឡើងខ្មៅ។ ខ្ញុំមិនបានហូបបាយជាមួយប្រពន្ធខ្ញុំទេ ព្រោះប្រុស និងស្រីត្រូវបានគេបែងចែកដាច់ពីគ្នា។ យើងអាចជួបគ្នាបានតែនៅពេលយប់ប៉ុណ្ណោះ។ នៅខែវិច្ឆិកា ខែធ្នូ ឆ្នាំ១៩៧៦ ខែកត្តិក ខ្មែរក្រហមបានបញ្ឆោឲ្យខ្ញុំ និងប្រពន្ធខ្ញុំទៅបង្រៀនគូររូបនៅសាលារចនាក្រុងភ្នំពេញ។ ខ្មែរក្រហមដឹកពួកខ្ញុំតាមរថយន្តហ្ស៊ីប តាមការពិតខ្មែរក្រហមមិនបានដឹកពួកខ្ញុំទៅសាលារចនានោះទេ គេយកពួកខ្ញុំទៅដាក់នៅមន្ទីរសន្តិសុខ ស-២១ ទួលស្លែង"។

[០៩:៥៣:៣៥]

ខ្ញុំនឹងលើកឡើងនូវឯកសារផ្សេងទៀតដែលសុទ្ធតែជាពាក្យសុំតាំងខ្លួនដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំមិនអានសម្រង់នោះទេ។ ខ្ញុំគ្រាន់តែបញ្ជាក់ប្រាប់ថា តើដើមបណ្ដឹងរដ្ឋប្បវេណីទាំងនោះនិយាយអំពីមន្ទីរសន្តិសុខណាខ្លះ នៅក្នុងពាក្យសុំតាំងខ្លួនរបស់ខ្លួន។

ដើមបណ្តឹងរដ្ឋប្បវេណី D22/1370.1 លើកឡើងអំពីមន្ទីរសន្តិសុខក្រាំងតាចាន់ នៅក្នុងភូមិភាគនិរតី។ ដើមបណ្តឹងរដ្ឋប្បវេណី D22/144 និយាយអំពីគុកសៀមរាប ដែលយើងនឹងនិយាយនៅពេលដែលយើងស្តាប់ចម្លើយរបស់គាត់។ ដើមបណ្តឹងរដ្ឋប្បវេណី D22/1721a និយាយអំពីមន្ទីរសន្តិសុខគោកខ្យង ដែលយើងបានលើកឡើងជាច្រើនលើកច្រើនសានៅក្នុងសវនាការនេះរួមកហើយ នៅភូមិភាគបស្ចិម។ ដើមបណ្តឹងរដ្ឋប្បវេណី D22/3280 លើកឡើងអំពីមន្ទីរសន្តិសុខភ្នំប្រុស និងភ្នំស្រី នៅខេត្តកំពង់ចាម។ ហើយនៅក្នុងសវនាការយើងនេះក៏បាននិយាយជាច្រើនលើកច្រើនសាហើយអំពីមន្ទីរសន្តិសុខនេះ។

ដើមបណ្តឹងរដ្ឋប្បវេណី D22/3820a លើកឡើងអំពីមន្ទីរសន្តិសុខគោកខ្យង និងមន្ទីរសន្តិសុខស-២១ផងដែរ។ ជាចុងក្រោយ គឺដើមបណ្តឹងរដ្ឋប្បវេណី D22/83 គាត់បានលើកឡើងអំពីមន្ទីរសន្តិ-សុខសង់នៅក្នុងភូមិភាគពាយ័ព្យ (សូមទោស) គឺភូមិភាគនិរតីហើយយើងក៏បាននិយាយអំពីមន្ទីរសន្តិសុខនេះជាច្រើនលើកច្រើនសានៅក្នុងសវនាការនេះ។ ខ្ញុំសូមបញ្ចប់ការបង្ហាញឯកសារពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធយោធា។

ប្រសិនបើលោកប្រធានអនុញ្ញាតនោះ ខ្ញុំនឹងបង្ហាញឯកសារពាក់ព័ន្ធទៅនឹងការជម្លៀសដំណាក់កាលទី១ ទី២ ហើយលោក ពេជ អង្គ ក៏នឹងបន្តពាក់ព័ន្ធទៅនឹងការជម្លៀសទី១ ទី២ និងទួលពោធិ៍ជ្រៃ។

[០៩:៥៥:៥៤]

ចំពោះការជម្លៀសដោយបង្ខំដំណាក់កាលទី១ ទី២ ខ្ញុំសូមអានសម្រង់មួយចំនួន។ ក៏ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបាននិយាយអំពីការជម្លៀសដោយបង្ខំទី១ ទី២ និងទួលពោធិ៍ជ្រៃ។ ឯកសារទី១ដែលខ្ញុំចង់បង្ហាញជូនអង្គសវនាការនោះ គឺឯកសារ D22/1240 សម្រង់ដែលខ្ញុំចង់អាននោះ គឺនៅលេខ ERN ដូចតទៅបារាំង 00861757 ទៅដល់ 58, ជាភាសាអង់គ្លេស 00840000, ជាភាសាខ្មែរ 00523356 ទៅដល់ 57។ ដើមបណ្តឹងរដ្ឋប្បវេណីនេះមានអាយុ២៥ឆ្នាំនៅឆ្នាំ១៩៧៥ ហើយគាត់បានបញ្ជាក់នៅក្នុងឯកសាររបស់គាត់ដូចតទៅ នៅក្នុងជួរដំបូងនៃពាក្យសុំរបស់គាត់ "នៅឆ្នាំ៧៥ ខែមេសាមនុស្សម្នានាំគ្នាចេញពីភ្នំពេញ ដោយសារពួកទាហានខ្មែរក្រហមប្រាប់ឲ្យចេញ។ គ្រួសារខ្ញុំក៏ត្រូវពួកខ្មែរក្រហមជម្លៀសចេញពីភ្នំពេញដែរ"។ បន្តទៅទៀត គាត់បានរៀបរាប់នៅពេលនោះថា "ខ្មែរក្រហមបានឲ្យប្រាប់ឈ្មោះ និងប្រាប់មុខងារ"។ គាត់បានបញ្ជាក់ថា "នៅឆ្នាំ១៩៧៥ បងប្រុសឈ្មោះ ប៊ុត សឿន ជាគ្រូបង្រៀន ប្រពន្ធនិងកូនត្រូវខ្មែរក្រហមយកទៅសម្លាប់នៅក្នុងវត្តជីឥដ្ឋ ព្រោះនៅពេលធ្វើការគាត់បាន

ច្រៀងបទចម្រៀងពីសង្គមរាស្ត្រនិយម។ នៅឆ្នាំ១៩៧៥ បងជីដូនមួយឈ្មោះ ជុំ ផន ជាទាហានជើងទឹក ប្រពន្ធ និងកូនត្រូវខ្មែរក្រហមយកទៅសម្លាប់នៅវត្តជីឥដ្ឋដែរ ព្រោះខ្មែរក្រហមដឹងថាគាត់ជាទាហានរដ្ឋាភិបាល។ ខ្ញុំបានដឹងរឿងទាំងពីរនេះ ពីបងជីដូនមួយឈ្មោះ ជុំ សុន រស់នៅឃុំព្រែកឯង ស្រុកកៀនស្វាយ។ នៅខែមិថុនា ឆ្នាំ១៩៧៥ នេះដែរក្រោយប្តីខ្ញុំត្រូវខ្មែរក្រហមសម្លាប់ហើយនោះកូនស្រីខ្ញុំវាចេះតែសួររកឪពុកវា ហើយដោយសារមិនសូវមានអីហូបផងនោះ វាបានឈឺគ្មានថ្នាំព្យាបាល ហើយស្លាប់នៅព្រែកតាម៉ាក់នេះ។ ដើមឆ្នាំ១៩៧៦ ក្រោយពីរស់នៅ និងធ្វើការឯមូលដ្ឋានព្រែកតាម៉ាក់បានប្រហែល៨ខែ នៅពេលប្រមូលផលស្រូវគេបានជម្លៀសគ្រួសារខ្ញុំ និងអ្នកផ្សេងឲ្យទៅនៅមូលដ្ឋានថ្មី គឺនៅបាត់ដំបង ដោយពួកខ្មែរក្រហមនិយាយថា នៅខាងបាត់ដំបងស្រូវច្រើន តែអត់មានអ្នកច្រូត"។

[១០:០១:០៣]

ឯកសារទី២ ដែលខ្ញុំចង់បង្ហាញជូន គឺឯកសារលេខ D22/3751 ខ្ញុំសូមអានសម្រង់នៃឯកសារនេះដែលមានលេខ ERN ជាភាសាបារាំង 00865640, ជាភាសាអង់គ្លេស 00569592, ជាភាសាខ្មែរ 00873721 ទៅដល់ 22 ដើមបណ្តឹងរដ្ឋប្បវេណីនេះ មានអាយុ ៦ឆ្នាំ នៅឆ្នាំ១៩៧៥។ គាត់បានបញ្ជាក់ដូចតទៅ "សុបិនអាក្រក់បានចាប់ផ្តើមនៅក្រោយថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ នៅពេលដែលគ្រួសារខ្ញុំដែលមានសមាជិកប្រាំពីរនាក់ត្រូវបានគេបណ្តេញឲ្យចេញពីផ្ទះ ដែលជាទីជម្រកដ៏កក់ក្តៅរបស់ពួកយើងនៅទីក្រុងភ្នំពេញនៅជិតផ្សារអូឡាំពិក។ ទីក្រុងនេះត្រូវបានកាត់កាប់ទាំងស្រុងដោយពួកទាហានខ្មែរក្រហម។ ហើយពួកគេបានប្រកាសតាមវិទ្យុឲ្យពួកយើងចាកចេញពីទីក្រុងភ្លាមៗតែរយៈពេល៣ថ្ងៃប៉ុណ្ណោះ ឲ្យបានមុនពេលយន្តហោះអាមេរិកចាប់ផ្តើមទម្លាក់គ្រាប់បែកមកលើទីក្រុងភ្នំពេញ។ ពួកគេបានសន្យាជាមួយយើងថា ក្រោយ៣ថ្ងៃ យើងនឹងអាចត្រឡប់មកផ្ទះរបស់ពួកយើងវិញហើយ"។

[១០:០៣:០៤]

ខាងក្រោមមកទៀតដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានបញ្ជាក់ផងដែរថា "បន្ទាប់មកយើងជិះទូកដើម្បីទៅដល់គោកខ្សាច់ទន្លា យើងនៅទីនោះប្រហែលជា៧ ទៅ៨ខែ ក្រោយមករដ្ឋាភិបាលកណ្តាលរបស់ខ្មែរក្រហមហៅអង្គការ បានបង្ខំឪពុកម្តាយខ្ញុំឲ្យផ្លាស់ទៅខេត្តបាត់ដំបង។ គ្រួសារខ្ញុំ និងខ្ញុំរួមជាមួយនិងប្រជាជនស្លូតត្រង់ជាច្រើនផ្សេងទៀត ត្រូវពួកវារុញ និងបោះដោយបង្ខំទៅលើរថភ្លើងដូចគោដូចក្របី។ ពួកយើងធ្វើដំណើរតាមរថភ្លើងរយៈពេល២ ទៅ៣ថ្ងៃ ទើបបានទៅដល់ខេត្តបាត់ដំបង។ ចេញពីក្រុងមួយក្នុងខេត្តបាត់ដំបងដែលខ្ញុំមិនចាំឈ្មោះនោះ ពួកយើងត្រូវជិះរទេះគោធ្វើដំណើរទៅភូមិ

កំពង់សំបូរ។ ខ្ញុំនៅចាំថា ពេលនោះ គឺនៅដើមឆ្នាំ១៩៧៦"។

[១០:០៤:២៧]

ហើយបន្ទាប់មកទៀតដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានបញ្ជាក់ថា "ប៉ុន្មានខែក្រោយមកខ្ញុំត្រូវគេបំបែកចេញពីឪពុកម្តាយ គេឲ្យខ្ញុំទៅរស់នៅជាមួយក្មេងៗឯទៀត ដែលប្រមូលពីក្នុងភូមិជិតៗនោះ។ ខ្ញុំរស់នៅក្នុងផ្ទះតូចមួយជាមួយក្មេងៗប្រហែលពី៣០ ទៅ៤០នាក់ ដែលមានអាយុចន្លោះពី ៦ ទៅ១០ឆ្នាំ។ ពួកក្មេងៗ និងខ្ញុំត្រូវបានមេខ្មែរក្រហមប្រាំ ឬប្រាំមួយនាក់ មើលការខុសត្រូវ ដោយបានព្យាយាមលាងដុសខាត់ខួរក្បាលរបស់ពួកយើង។ ពួកគេបាននិយាយថា "ពួកយើងគឺជាទ្រព្យសម្បត្តិរបស់អង្គការហើយឪពុកម្តាយរបស់ពួកយើងគឺជាខ្មាំង"។

ឯកសារទី៣របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលខ្ញុំចង់បង្ហាញជូនពាក់ព័ន្ធទៅនឹងការជម្លៀសដោយបង្ខំនេះ គឺដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខ D22/3850។ ដើមបណ្តឹងរដ្ឋប្បវេណីនេះមានអាយុ៣០ឆ្នាំនៅពេលកើតរឿងហេតុ ហើយមានកូនអាយុ៥ឆ្នាំ ហើយនិងមានអាយុ៦ខែ។

[១០:០៥:៥៥]

សម្រង់ដែលខ្ញុំចង់អាននោះគឺមាននៅលេខ ERN ដូចតទៅ ជាភាសាបារាំង 00860735 ទៅដល់ 36, ជាភាសាអង់គ្លេស 00867203 ទៅដល់ 04, ជាភាសាខ្មែរ 00571056 ទៅដល់ 58។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានបញ្ជាក់ថា "នៅពេលបន ប៉ុល ពត ចូលភ្នំពេញថ្ងៃទី១៧ មេសា ៧៥ ពួកយោធាវាមានឯកសណ្ឋានខ្មៅ ដៃកាន់កាំភ្លើង មុខឡើងមាំដូចមនុស្សមានកំហឹង ហើយបានដេញប្រជាជនទាំងអស់ទៅ ហើយដេញចេញពីផ្ទះឆាប់ៗ ចេញពីភ្នំពេញទៅ ដោយនិយាយកុហកថា អាមេរិកាំងនឹងមកទម្លាក់គ្រាប់បែកលើទីក្រុងឆាប់ៗ។ យើងត្រូវតែចេញក្នុងរយៈ៣ថ្ងៃសិន"។

ខាងក្រោមមកទៀត ដើមបណ្តឹងរដ្ឋប្បវេណីនេះបានបញ្ជាក់ដូចតទៅ "នៅពេលដែលទៅដល់ក្បាលថ្នល់ ខ្ញុំក្រឡេកឃើញបងថ្លៃស្រីម្នាក់ទៀតឈ្មោះ បៃ ម៉ារទីន ប្តីគាត់ជានាយប៉ូលិសភ្នំពេញ គាត់ហើយនិងគ្រួសារគាត់។ ខ្ញុំចង់ទៅជួបគាត់ តែមិនអាចទៅបាន។ ចម្ងាយប្រហែល១០ម៉ែត្រពីគ្នាប៉ុណ្ណោះ ខ្ញុំកៀកកូនយ៉ាងជាប់ព្រោះខ្លាចរបូតដៃបែកគ្នា។ កូនង៉ែតខ្ញុំក្តៅពេក ខ្ញុំឱបជាប់នឹងទ្រូងខ្ញុំ ខ្ញុំចេះតែដើរបន្តិចៗរហូតមកជាច្រើនថ្ងៃ។ ដល់កន្លែងមួយនោះ ភ្លៀងធ្លាក់យ៉ាងជោកជាំ គ្មានអ្វីសម្រាប់ជ្រកនោះទេ។ ខ្ញុំឱបកូនក្រោមទ្រូង យកខ្នងខ្ញុំបាំងនឹងគ្រាប់ភ្លៀង ហើយក្បាលកូនៗតូចៗពីរនាក់ទៀតក៏ក្រាបនៅក្រោមទ្រូងខ្ញុំដែរ។ ខ្ញុំនិងកូនង៉ែតទទឹកជោកមួយយប់ទាល់ភ្លឺ គេងអត់បាន។ ភ្លឺឡើងក៏ចាប់បន្តដំណើរ

E1/164.1

តទៅទៀត។ ក្នុងរយៈពេល៨ថ្ងៃទើបយើងដើរទៅដល់វត្តពោធិ៍ត្រើយស្លា មុខព្រែកតូច ស្រុកស្អាង ខេត្តកណ្ដាល។ កូនង៉ែតខ្ញុំ ដោយត្រូវកម្ដៅក្ដៅផង ត្រូវទឹកភ្លៀងផងនោះ ក៏ចាប់ឈឺភ្លាម។ ខ្ញុំសម្រេចចិត្តថាមិនដើរទៅមុខទៀតទេ ព្រោះកូនឈឺហើយ ហើយឲ្យមិត្តភក្ដិគេបន្តដំណើរទៅមុខទៀតចុះ ខ្ញុំមិនបន្តទៅទេ”។

[១០:០៩:៤៣]

ឥឡូវនេះ ខ្ញុំគ្រាន់តែលើកឡើងនូវពាក្យសុំតាំងខ្លួនរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនទៀតដែលលើកឡើងអំពីការជម្លៀសដោយបង្ខំ។ ដើមបណ្ដឹងរដ្ឋប្បវេណី D22/10 បានលើកឡើងអំពីការជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញ ហើយផ្ដល់នូវសេចក្ដីលម្អិតមួយចំនួនពាក់ព័ន្ធទៅនឹងការជម្លៀសនេះ។

ដើមបណ្ដឹងរដ្ឋប្បវេណី D22/121a បាននិយាយអំពីការជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញ។ ដើមបណ្ដឹងរដ្ឋប្បវេណី D22/203 លើកឡើងអំពីការជម្លៀសដោយបង្ខំដំណាក់កាលទី២។ ដើមបណ្ដឹងរដ្ឋប្បវេណី D22/216 លើកឡើងពីការជម្លៀសដោយបង្ខំពីទីក្រុងភ្នំពេញ។ ដើមបណ្ដឹងរដ្ឋប្បវេណី D22/235 និយាយអំពីការជម្លៀសដោយបង្ខំចេញពីទីរួមខេត្តកំពង់ស្ពឺ។ ដើមបណ្ដឹងរដ្ឋប្បវេណី D22/257 រៀបរាប់អំពីការជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងការប្រព្រឹត្តចំពោះក្រុមជាក់លាក់មួយចំនួននៅពេលដែលជម្លៀសនោះ។

[១០:១១:៣៧]

ដើមបណ្ដឹងរដ្ឋប្បវេណី D22/273 រៀបរាប់ជាពិសេសអំពីការជម្លៀសដោយបង្ខំនៅដំណាក់កាលទី២។ ដើមបណ្ដឹងរដ្ឋប្បវេណី D22/348 រៀបរាប់អំពីការជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងដើមបណ្ដឹងរដ្ឋប្បវេណី D22/354 ក៏បានលើកឡើងអំពីការជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញផងដែរ។

ខ្ញុំសូមបញ្ចប់ការបង្ហាញឯកសារសំខាន់ៗ ដែលមិនមែនជាឯកសារបន្ថែមទៅលើអ្វីដែលសហព្រះរាជអាជ្ញាបង្ហាញនោះទេ។ ឯកសារទាំងអស់នេះគឺជាឯកសារសំខាន់ ពីព្រោះថាដើមបណ្ដឹងបានផ្ដល់នូវព័ត៌មានអង្គហេតុទៅលើព្រឹត្តិការណ៍ ដែលបានកើតឡើង ហើយដែលពួកគាត់មានវត្តមាននៅពេលនោះ។ ខ្ញុំសូមអរគុណលោកប្រធាន ហើយខ្ញុំសូមផ្ដល់វេទិកានេះជូនលោក ពេជ អង្គ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី។ សូមអញ្ជើញលោកមេធាវី ពេជ អង្គ!

[១០:១៣:០៨]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ យើងខ្ញុំមានពាក្យសុំទម្រង់បែបបទព័ត៌មានដើមបណ្ដឹងរដ្ឋប្បវេណី២៥ សម្រាប់បង្ហាញពេលនេះ ដូចលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត បានជម្រាបរួចហើយ នេះគ្រាន់តែជាពាក្យសុំមួយចំនួននៅក្នុងចំណោមពាក្យសុំជាច្រើនរបស់ដើមបណ្ដឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ។ ហើយក៏មានពាក្យសុំផ្សេងៗទៀត ដែលមានព័ត៌មានជាក់លាក់អំពីអង្គហេតុដែលបានកើតឡើង។

ជាដំបូងខ្ញុំបាទសូមលើកពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានលេខ D22/1999។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានលើកឡើងថា បាទសូមទោស ខ្ញុំត្រូវលើកអំពី ERN ផងដែរ។ ERN ជាភាសាខ្មែរគឺលេខ 00541456 ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានលើកឡើងថា “មុនឆ្នាំ១៩៧៥ នាងខ្ញុំរស់នៅជាមួយប្ដីនាងខ្ញុំឈ្មោះ ទេព ស៊ុប ជាទាហាននៅខេត្តមណ្ឌលគិរី (មិនចាំភូមិ ឃុំ ស្រុក)។ គាត់បានឲ្យនាងខ្ញុំត្រឡប់មកនៅឃ្លាំងរំសេវក្រុងភ្នំពេញ មិនចាំភូមិសង្កាត់។ កន្លះខែក្រោយមក នាងខ្ញុំបម្រុងនឹងទៅរកប្ដីនៅខេត្តក្រចេះ ប៉ុន្តែពេលនោះ ទូកដែលត្រូវចេញទៅខេត្តក្រចេះ គេថាលែងធ្វើដំណើរទៅខេត្តក្រចេះហើយ ព្រោះពួកកងទ័ពខ្មែរក្រហមបានចូលវាយពេញផ្លូវខេត្តក្រចេះ។ ដូច្នេះនាងខ្ញុំក៏នាំកូនត្រឡប់មកវិញ។ នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលទីក្រុងភ្នំពេញ ហើយពួកខ្មែរក្រហមជម្លៀសក្រុមគ្រួសារនាងខ្ញុំ ក៏ដូចជាប្រជាជននៅក្នុងក្រុងភ្នំពេញឲ្យធ្វើដំណើរទៅតាមខេត្តទាំងអស់ ព្រោះពួកអាមេរិកនឹងមកទម្លាក់គ្រាប់នៅក្រុងភ្នំពេញ។ ពេលនោះដែរ នាងខ្ញុំបានបំបែកកូននាងខ្ញុំទាំងបីនាក់ ព្រោះពួកគេបានរត់ទៅជាមួយម្ដាយខ្ញុំឈ្មោះ អ៊ូច សាប៊ុន ទៅខេត្តតាកែវ ចំណែកនាងខ្ញុំរត់ទៅវ៉ាបាត់ដឹង ខាងលិចស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ធ្វើដំណើរថ្មើរជើងរហូតពេល២យប់ ២ថ្ងៃទើបដល់។ នៅទីនោះពួកខ្មែរក្រហមឲ្យប្រជាជនថ្មី ឬហៅថា ពួក១៧ មេសា នៅផ្ទះជាមួយពួកមូលដ្ឋាន ហើយនាងខ្ញុំត្រូវបានខ្មែរក្រហមប្រើឲ្យដាំដំឡូង ស្ពៃ។ ឯការហូបចុកវិញ ក្នុងមួយថ្ងៃហូបបាយពីរពេល។

[១០:១៧:០៣]

ដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបទៀត ដែលមានលេខ D22/525 ដែលមានលេខ ERN ជាភាសាខ្មែរទំព័រដែលទាក់ទងនោះគឺលេខ 00496962 ខ្ញុំសូមដកស្រង់ “មុនឆ្នាំ១៩៧៥ គ្រួសារខ្ញុំរស់នៅភូមិព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល តែពេលមានសង្គ្រាមនៅសម័យលន់ នល់ យើងបានផ្លាស់

ទៅនៅទីក្រុងភ្នំពេញ។ នៅពេលដែលរបប លន់ នល់ ចាញ់ពួកខ្មែរក្រហម បានចូលមកធ្វើការជម្លៀសប្រជាជនឲ្យចេញពីផ្ទះ ចេញពីទីក្រុង ដោយពួកវាបានប្រាប់ថា ពួកអាមេរិកាំងទម្លាក់គ្រាប់បែក។ នៅពេលប្រាប់ឲ្យប្រជាជនចេញនោះ អ្នកខ្លះមិនព្រមចេញ ត្រូវពួកខ្មែរក្រហមយកកាំភ្លើងផ្ទង់ ហើយខ្លះត្រូវបាញ់សម្លាប់។ គ្រួសារខ្ញុំត្រូវបានជម្លៀសចេញមកទិសខាងកើត ឆ្លងទឹកមកកាន់ផ្លូវលេខ៦អា ធ្វើដំណើរជាច្រើនថ្ងៃ ដោយមានសម្រាកតាមផ្លូវផង ទើបមកដល់ភូមិឫស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្ដាលជាកន្លែងដែលពួកខ្មែរក្រហមបញ្ជូនគ្រួសារខ្ញុំឲ្យទៅរស់នៅ។ នៅទីនោះពួកខ្មែរក្រហមចាប់ផ្ដើមធ្វើការស្រាវជ្រាវប្រវត្តិរូបប្រជាជនថ្មី ដោយឲ្យអ្នកទាំងនោះចេញបង្ហាញខ្លួនប្រាប់ពីការងាររបស់ខ្លួន ដែលធ្វើពីមុន ដោយពួកវាប្រាប់យើងថា អ្នកណាធ្លាប់ធ្វើការពីមុន អង្គការនឹងឲ្យទៅធ្វើការងារនោះវិញ”។

ដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបទៀត ដែលមានលេខសម្គាល់ D22/2953 ត្រង់លេខ ERN ជាភាសាខ្មែរ 00557816 បានលើកឡើងថា “មុនឆ្នាំ៧៥ ក្រុមគ្រួសារខ្ញុំជាអ្នកដែលមានជីវភាពធូរធារនៅក្នុងភូមិដង្កោខេត្តកណ្ដាល ដោយឪពុកគាត់ជាទាហាន ហើយបងប្អូនគឺបានចូលរៀនទាំងអស់ ហើយមីងដែលជាប្អូនប៉ា ឈ្មោះ សោម ស៊ីម ក៏ជាបុគ្គលិកធនាគារជាតិដែរ។ នៅពេលដែលពួកខ្មែរក្រហមបានជ័យជម្នះលើទាហាន លន់ នល់ ១៧ មេសា ១៩៧៥ ពួកវាបានចូលកាន់កាប់ពាសពេញទីក្រុងភ្នំពេញ និងខេត្តកណ្ដាល ក្រុមគ្រួសារមានប្រាំបួននាក់ ឪពុកខ្ញុំ -- ខ្ញុំសូមរំលងបន្តិច នៅពេលពួកវាចូលមកដល់បានប្រកាសថា ប្រទេសយើងលែងមានសង្គ្រាមទៀតហើយ ពីថ្ងៃនេះទៅគឺមានសន្តិភាព ពួកវាទាហានស្លៀកពាក់ខ្មៅស្រែកជយោ នឹងជ័យជម្នះ ស្រាប់តែនៅថ្ងៃស្អែកឡើងពួកខ្មែរក្រហមបានប្រកាសឲ្យប្រជាជនទាំងអស់ចាកចេញពីលំនៅដ្ឋានដើម្បីធ្វើការរៀបចំ និងសម្អាតខ្មាំង មិនចាំបាច់យកអីវ៉ាន់ច្រើនទៅទេ។ គឺអង្គការឲ្យចេញរយៈពេល៣ថ្ងៃ។

[១០:២១:២៤]

ក្រុមគ្រួសារខ្ញុំ និងប្រជាជននៅទីលំនៅក្បែរគ្នាចាកចេញតាមបញ្ជារបស់ពួកវាទាំងងឿងឆ្ងល់។ ដោយពួកវាប្រើចុងកាណុងកាំភ្លើងគំរាមកំហែងឲ្យចេញពីផ្ទះតែម្ដង។ អ្នកមិនចេញតាមបញ្ជារបស់ពួកវាគឺពួកវារៃនឹងស្វាយកាំភ្លើង ពេលនោះក្រុមគ្រួសារខ្ញុំចាប់ផ្ដើមបែកគ្នា រូបនាងខ្ញុំ និងបងស្រី សាម វាសនា បានដើរតាមព្រែកឯង និងសួរផ្លូវទៅខេត្តកណ្ដាលដើម្បីទៅស្រុកកំណើតវិញ។ នាងខ្ញុំនឹងបងស្រីលួចរត់ទៅតាមផ្លូវដើម្បីកុំឲ្យពួកវាឃើញ។ តាមផ្លូវគឺគ្មានអ្វីហូបទាំងអស់ តែសុំបាយអ្នកធ្វើដំណើរបានដូចគ្នា -- ធ្វើដំណើរដូចគ្នាហូប។ ខ្ញុំសូមរំលងមកក្រោយទៀត ១៩៧៦ អង្គការបានជម្លៀសក្រុម

គ្រួសារខ្ញុំឲ្យជិះឡានពីភូមិរកាខ្ពស់ មានប្រជាជនរាប់ពាន់នាក់ឲ្យមកស្នាក់នៅពោធិ៍ចិនតុង ចាំរថភ្លើងមកទទួលនៅទីនោះរយៈពេល៣ថ្ងៃ។

[១០:២២:៤៤]

ពួកអង្គការបើកអង្គរឲ្យហូប លុះដល់រថភ្លើងមកដល់ពួកវាឲ្យឡើងលើរថភ្លើងទាំងអស់គ្នា និងមានការគ្រប់គ្រងរបស់ទាហានខ្មែរក្រហម។ រថភ្លើងបានចេញដំណើររហូតដល់ពេលយប់ដេកតាមផ្លូវលុះព្រឹកឡើងទៀត បន្តដំណើររហូដល់ត្រពាំងជង។ ពេលមកដល់ពីនេះ មានរទេះគោជាច្រើនដែលរង់ចាំជាស្រេច"។

ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀត ដែលមានលេខ D22/1340 ត្រង់លេខ ERN ចាប់ពីលេខ 00526053 ទៅបានលើកឡើងថា "១៧ មេសា ១៩៧៥ ខ្ញុំកំពុងរស់នៅក្នុងបន្ទាយចោមចៅ ខ្ញុំជាប្រពន្ធទាហាន" សូមរំលងបន្តិចទៅ "នៅវេលាម៉ោងមួយយប់ទាហានក្នុងបន្ទាយឈ្មោះ សំ ផាន បានមកប្រាប់ថា ខ្ញុំ -- ប្រាប់ឲ្យខ្ញុំរើអីវ៉ាន់ចេញពីបន្ទាយព្រោះទាហានខ្មែរក្រហមវាយបែកភ្នំពេញ។ ហើយពេលនោះ នៅក្នុងបន្ទាយចោមចៅខ្ញុំក៏ប្រញាប់រើអីវ៉ែអីវ៉ាន់ចេញទាំងយប់ធ្វើដំណើរទៅជាមួយប្អូនថ្លៃ និងកូនខ្ញុំ។ ចំណែកឯកប្អូនប្រុសខ្ញុំរត់បែកគ្នា ខ្ញុំកំពុងពោះធំកូនទី៣ នៅពេលនោះ ខ្ញុំនិងប្តីខ្ញុំមិនបាននៅជុំគ្នាទេ ព្រោះគាត់ជាប់ទៅខាងមុខបន្ទាយ។ ខ្ញុំបានចេញដំណើរទាំងយប់ចេញពីបន្ទាយ ពេលនោះខ្ញុំឃើញខ្មែរក្រហមឈរកាន់កាំភ្លើងត្រៀបត្រាពេញនៅតាមផ្លូវ។ មានមនុស្សយ៉ាងច្រើនកុះករធ្វើដំណើរចេញពីទីក្រុងដូចខ្ញុំដែរ។ ខ្លះមានអីវ៉ាន់សំពីងសំពោង ពរកូនចៅ ខ្លះយំ ខ្លះស្រែក ដោយសារតែវង្វេងកូននិងគ្រួសារ។ ទិដ្ឋភាពពេលនោះគឺពោរពេញដោយភាពតក់ស្លុត និងភ័យខ្លាចនៅតាមផ្លូវ។ ពីបន្ទាយ ខ្ញុំឃើញតែសាកសពដែលត្រូវខ្មែរក្រហមសម្លាប់ ដេកស្លាប់យ៉ាងច្រើន។ ខ្លះអង្គុយស្លាប់នៅក្នុងឡាន ខ្លះក្នុងបន្ទាយ និងតាមផ្លូវដែលមិនដឹងថាស្លាប់ដោយសារថ្នាំអ្វីទេ ព្រោះសាច់ខ្មោចផុយដូចជាត្រូវថ្នាំអ្វីម្យ៉ាង។

[១០:២៥:៣៨]

ខ្ញុំដើរទាំងភ័យខ្លាចនៅតាមផ្លូវ នៅខាងក្រោយឃ្លាំង ស៊ុំ សក្តិ ខ្ញុំឃើញមានផ្ទះចិញ្ចឹមជ្រូកដែលគ្មានមនុស្សទេ ព្រោះត្រូវខ្មែរក្រហមជម្លៀសចេញពីភ្នំពេញដែរនោះ។ គឺនៅសល់តែសត្វជ្រូកដែលគ្មានចំណីស៊ី។ ខ្ញុំឃើញជ្រូក ឆ្កែ ចេញមកស៊ីសាកសពមនុស្សយ៉ាងខ្លោចផ្សាណាស់។ ខ្ញុំធ្វើដំណើរក្រោមការយាមកាមពីកងទ័ពខ្មែរក្រហមដែរនៅអមតាមផ្លូវឥតដាច់ និងប្រដាប់ដោយកាំភ្លើង។ មកដល់ជម្ពូវ័នទាំងយប់ ចូលទៅក្នុងវត្តខ្មែរក្រហមមិនឲ្យខ្ញុំសម្រាកនៅទីនោះទេ គឺគេ (ខ្មែរក្រហម) ដេញចេញមក

វិញទាំងខ្ញុំ ទាំងលោកសង្ឃនៅក្នុងវត្តនោះដែរ។ ពេលនោះលោកសង្ឃដែលខ្មែរក្រហមដេញចេញពីវត្តក៏ធ្វើដំណើរមកជាមួយខ្ញុំដែរ។ ពួកយើងធ្វើដំណើរជាបន្ត យប់ត្រង់ណាដេកត្រង់នោះ។ ជួនដេកក្រោមឈើ ជួនកាលដេកក្រោមទឹកភ្លៀងឱបកូនទាំងសើមខ្លួនជោកដោយទឹកភ្លៀង។ ក្មេងៗខ្លះស្រែយំព្រោះវង្វេងម្តាយ ត្រូវគេជាន់ស្លាប់យ៉ាងវេទនា”។

[១០:២៧:០៧]

ព័ត៌មានរបស់ដើមបណ្ដឹងជាបន្ទាប់គឺដើមបណ្ដឹងរដ្ឋប្បវេណីលេខ D22/1322 ត្រង់លេខ ERN 00525684 បានលើកឡើងថា “១៨ មេសា ១៩៧៥ ខ្មែរក្រហមជម្លៀសគ្រួសារខ្ញុំចេញពីភ្នំពេញ។ ខ្មែរក្រហមប្រកាសតាមមីក្រូតាមឡានថា បងប្អូនចេញពីផ្ទះទៅជាយក្រុងរយៈពេល៣ថ្ងៃ ព្រោះថានឹងមានអាមេរិកទម្លាក់គ្រាប់បែក។ អីវ៉ាន់យកបន្តិចបន្តួចបានហើយ មិនបាច់ចាក់សោផ្ទះ អង្គការមើលខុសត្រូវ។ សម្បីតែបន្តិចក៏មិនឲ្យបាត់ដែរ បើស្រលាញ់សម្តេចឪ ប្រគល់ឡាន វិទ្យុ ឲ្យអង្គការ។ ខ្ញុំបានឮថាមានចិនម្នាក់បិទទ្វារចាស់សោមិនព្រមចេញ ខ្មែរក្រហមបាញ់កាំភ្លើងបំបែកសោ ក្រោយមកឮគេនិយាយថា ចិននោះត្រូវខ្មែរក្រហមសម្លាប់។ នៅតាមផ្លូវខ្ញុំឃើញសុទ្ធតែសាកសពទាហាន លន់ នល់។ ខ្មែរក្រហមមិនបានប្រាប់ឲ្យទៅណាទេ ទៅណាស្រេចតែយើង។ ក្រុមគ្រួសារខ្ញុំមានគម្រោងទៅស្រុកកំណើតនៅស្រុកកោះសូទិន ខេត្តកំពង់ចាម”។

[១០:២៨:៥១]

ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះក៏បានលើកឡើងទៀតថា “នៅ កក្កដា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសគ្រួសារខ្ញុំទៅខេត្តកំពង់ធំ ដោយហៅឈ្មោះ ហើយដឹកតាមឡាន ដោយប្រាប់ថាត្រូវប្តូរទៅនៅតំបន់ថ្មី នៅខេត្តកំពង់ធំ។ ឪពុកម្តាយជាមួយប្អូនប្រុស ប្អូនៗខ្ញុំទាំងអស់ទៅនៅជាមួយប្រជាជនមូលដ្ឋានយាយ យឹម នៅភូមិលាបទង ឃុំទ្រា ស្រុកស្ទោង ចំណែកខ្ញុំ និងយាយខ្ញុំ ទៅរស់នៅផ្ទះប្រជាជនមូលដ្ឋាន”។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣០នាទី ដល់ម៉ោង ១០:៥៧ នាទី)*

[១០:៥៧:១៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបន្តការដាក់បង្ហាញឯកសារភស្តុតាង។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគីអង្គសវនាការទាំងមូល និងដើមបណ្តឹងរដ្ឋប្បវេណីសាជាថ្មី។

ដើមបណ្តឹងរដ្ឋប្បវេណីជាបន្ត គឺដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខ D22/1248 ត្រង់លេខ ERN ជាភាសាខ្មែរ 00523449។ ដើមបណ្តឹងរដ្ឋប្បវេណីនេះបានលើកថា “នៅចន្លោះឆ្នាំ១៩៧០-១៩៧៥ ខ្ញុំបាទជាសិស្សរៀននៅសាលាបឋមសិក្សាទួលទំពូងក្រុងភ្នំពេញ។ ថ្ងៃទី១៧ មេសា ១៩៧៥ គ្រួសារខ្ញុំបាទ ត្រូវខ្មែរក្រហមឲ្យចេញពីផ្ទះនៅទីក្រុងភ្នំពេញ (មិនចាំភូមិ សង្កាត់ ខណ្ឌ) និងបានប្រកាសឲ្យប្រជាជនចេញទូទាំងក្រុងភ្នំពេញ ឲ្យចេញពីទីក្រុងក្នុងរយៈពេល៣ថ្ងៃប៉ុណ្ណោះ ពីព្រោះពួកខ្មែរក្រហមត្រូវសម្អាតខ្មាំង។ ពួកខ្មែរក្រហមនិយាយបន្តថា បើប្រជាជនណាមិនចេញ ពួកវាចោទថាជាខ្មាំង និងបាញ់សម្លាប់ចោលភ្លាម។ គ្រួសាររបស់ខ្ញុំឃើញទិដ្ឋភាពបែបនេះ ឪពុកខ្ញុំ ចៅ កាន់យុទ្ធ បាននាំប្រពន្ធកូនមានគ្នាប្រាំពីរនាក់ចេញពីផ្ទះឲ្យផុតពីទីក្រុងតាមផ្លូវស្ទឹងមានជ័យ មកដល់ចោមចៅ ទៅតាមផ្លូវជាតិលេខ៣ ចូលទៅដល់វត្តអង្គតាប្រូច អស់រយៈពេល៣ខែ ទាហានរបស់អង្គការខ្មែរក្រហម (មិនស្គាល់ឈ្មោះ) បានប្រាប់ឪពុកខ្ញុំឈ្មោះ ចៅ កាន់យុទ្ធ ថា “ពួក១៧ មេសាឯង អង្គការឲ្យផ្លាស់ទៅនៅតំបន់៤វិញ។ លុះព្រឹកឡើងគ្រួសារទាំងអស់ដែលស្នាក់នៅក្នុងវត្តអង្គតាប្រូច បានប្រមូលអីវ៉ាន់កូនចៅឡើងឡាន ដឹកនាំដោយពួកខ្មែរក្រហម ឆ្លងកាត់ទីក្រុងភ្នំពេញតាមផ្លូវចិត្តលេខ៥ ទៅដល់តំបន់ក្រឡោមភ្លុក មិនចាំភូមិ ឃុំ ក្នុងស្រុងមោងឫស្សី ក្នុងខេត្តបាត់ដំបង។ ពួកខ្មែរក្រហមបានបែងចែកឲ្យក្រុម

គ្រួសាររបស់ខ្ញុំរស់នៅក្នុងភូមិមួយហៅថា ភូមចាមរអា សហករណ៍ទំលែង គឺសហករណ៍ គឺស្មើឃុំ ស្រុកមោង ខេត្តបាត់ដំបង។ បានរយៈពេល១ខែ ម្តាយរបស់ខ្ញុំឈ្មោះ ស៊ូ អេង បានសម្រាលកូនប្រុស ឈ្មោះ ទឹម កំសត់។ ស្ថានភាពរស់នៅទីនោះ ក្រុមគ្រួសារខ្ញុំត្រូវបានពួកខ្មែរក្រហមឲ្យហូបបាយរួម ធ្វើការរួម បែងចែកមនុស្សចាស់ទៅតាមមនុស្សចាស់ ស្រីតាមមនុស្សស្រី យុវជនតាមយុវជន យុវនារីតាមយុវនារី កុមារីតាមកុមារី កុមារាតាមកុមារ ទារកតាមទារក។ និយាយរួមគឺគ្រួសារទាំងអស់ត្រូវតែរស់នៅបែកគ្នាទាំងអស់ សូម្បីតែហូបក៏ផ្សេងពីគ្នាដែរ”។

[១១:០១:៤៦]

សូមរំលងបន្តិច។ “នៅថ្ងៃបន្តបន្ទាប់ ពួកខ្មែរក្រហមបានប្រើពួកយើងខ្ញុំធ្វើការជាទម្ងន់ ដូចជា លើកទំនប់ ជីកប្រឡាយ រែកដី លើកភ្លឺស្រែ ភ្ជួររាស់ ដកស្ទូង កាប់ដីដាំដំណាំ ដាំពោត ដំឡូង។ល។ រស់នៅទីនោះ ពួកខ្មែរក្រហមតាមដានប្រជាជន ប្រជាពលរដ្ឋថ្មីហៅថា ពួក១៧មេសា ជារៀងរាល់ថ្ងៃ មិនថាពេលធ្វើការ ឬពេលដេកយប់ ពួកកងឈ្លបតែងតែលួចតាមដាន មិនថាពេលហូបនិយាយគ្នា ដេកឬធ្វើការឡើយ។ បងប្អូនប្រជាពលរដ្ឋយើងជាញឹកញាប់ ពួកខ្មែរក្រហមតែងតែសួរពីប្រវត្តិរូប។ ការរស់នៅកាន់តែពិបាកឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ ដោយហូបចុកមិនឆ្អែត ហើយធ្វើការពីបីប្រាំទៅដប់ម៉ោងក្នុងមួយថ្ងៃ។ ពេលប្រជុំនិយាយពីគោលការណ៍នយោបាយបដិវត្តន៍ ហាមមិនឲ្យលួច មិនឲ្យនិយាយមិនល្អពីអង្គការ ដោយឲ្យយើងកសាងខ្លួនជម្រុះចោលនូវរបៀបរបបសង្គម ខោអាវពណ៌ជម្រុះចោលអស់ត្រូវស្លៀកតែពណ៌ខ្មៅ”។

[១១:០៣:១៩]

ដើមបណ្តឹងរដ្ឋប្បវេណីបន្ទាប់មានលេខ D22/3129 នៅត្រង់លេខ ERN ជាភាសាខ្មែរ 00560829។ ដើមបណ្តឹងរដ្ឋប្បវេណីនេះបានលើកថា “នៅក្នុងឆ្នាំ១៩៧៥ ក្រុមគ្រួសារខ្ញុំត្រូវបានគេជម្លៀសចេញពីក្រុងភ្នំពេញ ដោយប្រជាជនទាំងអស់ត្រូវធ្វើដំណើរដោយថ្មើរជើង តាំងពីពេលនោះ ក្រុមគ្រួសាររបស់ខ្ញុំត្រូវបែកគ្នាទៅកាន់ទីកន្លែងផ្សេងៗគ្នា។ នៅខែធ្នូ ឆ្នាំ១៩៧៥ ប្អូនស្រីរបស់ខ្ញុំឈ្មោះ ផូ សំរ៉ាន់។ នាងមានប្តីជាជនជាតិថៃ មានឋានៈស័ក្តិ៥ ត្រូវបានគេយកទៅសម្លាប់ទាំងប្តី ទាំងប្រពន្ធនៅភ្នំបូកគោ ខេត្តកំពត ដោយគ្មានកំហុស។ នៅចុងខែធ្នូ ១៩៧៥ ទៀតសោត ម្តាយក្មេករបស់ខ្ញុំ សំ រិន ត្រូវបានគេយកទៅសម្លាប់យ៉ាងសាហាវ ដោយគេចោទគាត់ថា ជាជនសក្តិភូមិនៅខេត្តបាត់ដំបង។ រីឯឪពុកបង្កើតរបស់ខ្ញុំឈ្មោះ ពេជ្រ សុផាន ត្រូវបានគេសម្លាប់នៅស្រុកច្បារមន ខេត្តកំពង់ស្ពឺ។ រំលងបានមួយ

ឆ្នាំ សេចក្តីស្លាប់ក៏បានយាយីមកលើសាច់សាលោហិតខ្ញុំម្តងទៀតនៅពាក់កណ្តាលឆ្នាំ១៩៧៧។ ក្រុមគ្រួសារបងប្រុសបង្កើតរបស់ខ្ញុំត្រូវបានអង្គការយកទៅសម្លាប់ដោយបាញ់នឹងកាំភ្លើង បន្ទាប់ពីវាបានដឹងពីសាវតាររបស់គាត់។ គួរបញ្ជាក់ផងដែរ បងប្រុសរបស់ខ្ញុំមានឈ្មោះក្នុងជួររដ្ឋាភិបាល លន់ នល់ មានឋានៈស័ក្តិ៥។ សមាជិកក្នុងគ្រួសារប្រាំប្រាំមួយនាក់របស់គាត់បានស្លាប់បាត់បង់ជីវិតនៅក្នុងថ្លុកឈាមដ៏ជោកជាំ។ នៅចុងឆ្នាំ១៩៧៧ ទៀត ក្មួយរបស់ខ្ញុំដែលមានវ័យប្រមាណ១៣ ទៅ១៤ ឆ្នាំ ចំនួនប្រាំបីនាក់ត្រូវបានពួកយកទៅសម្លាប់ផងដែរ។ គិតទៅទ្រឹស្តី និងការអនុវត្តដឹកស្មៅត្រូវដឹកទាំងឫស ពិតជាត្រឹមត្រូវមែន។ រីឯជីវិតរបស់ខ្ញុំក៏ស្ថិតនៅក្នុងភាពប្រថិតប្រថើយដែរ។ ទោះជាអត់ឃ្លានប៉ុនណាក៏ដោយ ក៏ខ្ញុំខំប្រឹងប្រែងខំមាត់សង្កត់ចិត្ត ក្រែងគេដឹងពីប្រវត្តិរបស់ខ្ញុំ។ ខ្ញុំខំប្រឹងធ្វើការសព្វបែបយ៉ាង ទោះជាពុំពេញយ៉ាងណាក៏ដោយឲ្យតែជីវិតបានរស់។

[១១:០៦:២៤]

ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀត លេខ D22/3787 ត្រង់លេខERN ជាភាសាខ្មែរ 00570179 បានលើកឡើងថា នាថ្ងៃ១៤ ខែមេសា ឆ្នាំ១៩៧៥ ពួកខ្មែរក្រហមបានវាយកកាន់កាប់ខេត្តកំពង់ស្ពឺ ពេលនោះខ្ញុំបានជម្លៀសខ្លួនទៅកាន់ភ្នំពេញតាមយន្តហោះទាហានលន់ នល់ មួយគ្រឿង ក្នុងតម្លៃឈ្នួលមួយនាក់ប្រាំពីររដ្ឋ។ ខ្ញុំរស់នៅក្រុងភ្នំពេញជាមួយពូមីងម្ដាំរោងកុឋានសួគ៌។ នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ពួកខ្មែរក្រហមរំដោះបានក្រុងភ្នំពេញទាំងមូល។ នៅវេលារសៀលម៉ោងពីរ ថ្ងៃ១៧ ដដែលពួកខ្មែរក្រហមបានប្រកាសឲ្យប្រជាជនភ្នំពេញទាំងមូលជម្លៀសចេញជាបន្ទាន់ ជៀសវាងពីការទម្លាក់គ្រាប់បែកពីយន្តហោះអាមេរិក។ ក្រុមគ្រួសាររបស់ខ្ញុំបានធ្វើដំណើរដោយថ្មើរជើងថ្ងៃយប់ និងស្នាក់នៅតាមផ្លូវជាតិលេខ៤ អស់ជាច្រើនយប់ ទើបមកដល់ភូមិដូនអាត់ មិនដឹងឃុំស្រុកអ្វី ខ្ញុំមិនចាំ តែដឹងថាក្នុងខេត្តកំពង់ស្ពឺ។ ក្នុងវ័យកុមារ ពួកខ្មែរក្រហមបានប្រើខ្ញុំឲ្យរែកបាយស្មុក ឲ្យពួកយុវជន យុវនារី លើកទំនប់ដូនអាត់។ រស់នៅទីនោះមួយខែកន្លះ ទើបពួកខ្មែរក្រហមបានជម្លៀសក្រុមគ្រួសាររបស់ខ្ញុំតាមរថភ្លើងទាំងថ្ងៃទាំងយប់ មកកាន់ខេត្តបន្ទាយមានជ័យ។ បន្ទាប់មកប្រជាជនមូលដ្ឋានរបស់ពួកវាបានយករទេះគោមកដឹកក្រុមគ្រួសារខ្ញុំទៅរស់នៅក្នុងភូមិពានកាំ ឃុំរហាល ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ ពួកវាបានបំបែកខ្ញុំចេញពីក្រុមគ្រួសារឲ្យទៅធ្វើការតាមកងកុមាររើសកស្រូវ បន្ទាប់មកលើកទំនប់ភ្លឺស្រែ ឃ្វាលគោ ដឹកកណ្តាប់ ដោយទទួលបានបាយមួយចានក្នុងខែច្រូតកាត់ តែបានបបរមួយវែកនាខែវស្សា។ ខ្ញុំមានរាងការយស្គមស្គាំង។ ប្រជាជនប្រុសស្រីមួយចំនួនដែលមានកំហុសបន្តិចបន្តួចត្រូវ

ពួកវាចោទជាខ្សែយកទៅសម្លាប់ទាំងយប់ កប់ក្នុងរណ្ដៅ ដោយយកលេសថាយកទៅរៀនសូត្រ តែបែរយកទៅសម្លាប់ទៅវិញ។ ពាក្យមួយពួកវាថា ទុកមិនចំណេញ ដកចេញមិនខាត។

[១១:០៩:៣៧]

ដើមបណ្ដឹងរដ្ឋប្បវេណីបន្ទាប់ ដែលមានលេខ D22/247 ត្រង់លេខERN ជាភាសាខ្មែរ 00421489 បានលើកឡើងថា "នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមចូលដល់ទីក្រុងភ្នំពេញ ពួកគេបានបង្ខំឲ្យប្រជាជនទាំងអស់ចេញពីទីក្រុង ឲ្យទៅរស់នៅជនបទមួយរយៈសិន បើអ្នកណាហ៊ានប្រឆាំងគេនឹងបាញ់សម្លាប់ចោលតែម្ដង។ ដោយមានការភ័យខ្លាច ស្អែកឡើងគ្រួសារខ្ញុំបានបង្ខំចិត្តចេញពីផ្ទះទាំងក្ដីសោកស្ដាយ ពេលនោះដោយខ្ញុំទើបសម្រាលកូនបានតែជាង១០ថ្ងៃប៉ុណ្ណោះ។ ដូច្នេះពុំអាចយកសម្ភារៈអ្វីបានទេ។ ពួកខ្ញុំធ្វើដំណើរឆ្ពោះទៅទិសខាងលិចតាមផ្លូវជាតិលេខ៤ ក្នុងបំណងទៅស្រុកកំណើតខេត្តកំពង់ស្ពឺ។ នៅតាមផ្លូវធ្វើដំណើរ ខ្ញុំមានការលំបាកវេទនាខ្លាំងណាស់ ណាខ្លះឯងទើបបានសម្រាលកូនរួច ណាកូនៗសុទ្ធតែនៅតូចនៅឡើយ គ្មានទឹក និងអាហារសម្រាប់ហូបគ្រប់គ្រាន់ គ្មានកន្លែងស្នាក់នៅជាបណ្ដោះអាសន្នសមរម្យ។

[១១:១១:១៤]

ជារឿយៗកូនៗតូចៗរបស់ខ្ញុំ ក៏ដូចជាក្មេងៗដទៃទៀត បានស្រេកឃ្លានដោយហត់នឿយក្នុងការធ្វើដំណើរក្រោមកំដៅថ្ងៃផង និងដោយស្រេកឃ្លានអាហារផងគួរឲ្យសង្វេកបំផុត។ នៅតាមផ្លូវមានសាកសពមនុស្សស្លាប់ជាច្រើន នៅពេលខ្ញុំដើរទៅមុខលែងរួចប្ដីខ្ញុំច្នៃធ្វើរទេះអូសយ៉ាងលំបាក។ ពួកខ្ញុំបានស្នាក់នៅក្រោមដើមឈើនៅតាមផ្លូវជាច្រើនកន្លែង។ នៅពេលទៅដល់ផ្សារថ្នល់ទទឹងព្រំប្រទល់ខេត្តកណ្ដាល និងខេត្តកំពង់ស្ពឺ ពួកខ្ញុំធ្វើដំណើរទៅទិសខាងជើងឆ្ពោះទៅផ្សារឧដុង្គវិញ ព្រោះត្រូវលាក់ប្រវត្តិរូបប្ដីខ្ញុំដែលធ្លាប់ធ្វើប៉េអឹម ទើបមិនហ៊ានទៅស្រុកកំណើត។ ពេលទៅដល់ខាងជើងផ្សារបាត់ដឹងជិតវត្តបឹងខ្នារក្នុងស្រុកឧដុង្គ ពួកខ្ញុំក៏ត្រូវទាហានខ្មែរក្រហមបញ្ជាឲ្យស្នាក់នៅទីនោះជាបណ្ដោះអាសន្ន។ លុះប្រហែល៣ខែក្រោមមក គឺអំឡុងខែកញ្ញា ឆ្នាំ១៩៧៥ គ្រួសារខ្ញុំ និងប្រជាជនដែលចេញពីភ្នំពេញជាច្រើនគ្រួសារទៀត ត្រូវអង្គការខ្មែរក្រហមបញ្ជូនចេញពីទីនោះតាមរថយន្តយកទៅខេត្តពោធិ៍សាត់។

[១១:១២:៥០]

នៅពេលទៅដល់ខេត្តពោធិ៍សាត់ ពួកខ្ញុំត្រូវគេឲ្យទៅនៅសហករណ៍ភូមិវត្តហ្លួងក្នុងស្រុកបាកាន។ ដោយសារពួកខ្ញុំគេចាត់ទុកជាអ្នក ១៧មេសា គឺលំបាកវេទនាខ្លាំងណាស់ ដោយពុំមានកន្លែងសម្រាប់នៅ

សមរម្យទេ។ ស្បៀងអាហារវិញ គឺគេចែកអង្ករឲ្យក្នុងប្រាំប្រាំមួយនាក់បានមួយកំប៉ុងសម្រាប់១ថ្ងៃ។ ដូច្នេះដើម្បីឲ្យអាចហូបបាន យើងត្រូវដើររកបេះបន្លែបង្កាស្លឹកឈើព្រៃយកមកបបរលាយរាល់ថ្ងៃ។ បានប្រហែល ២ខែក្រោយមក គេឲ្យហូបរួមនៅក្នុងសហករណ៍វិញ ពេលនោះកាន់តែលំបាកខ្លាំងឡើងថែមទៀត ព្រោះបបររាវហើយ វាល់ចែកគ្នាបានម្នាក់មួយ ឬពីរវែកប៉ុណ្ណោះ។ លុះដល់ដើមឆ្នាំ១៩៧៦ សមាជិកគ្រួសារខ្ញុំត្រូវគេបំបែកចេញពីគ្នាអស់ហើយ គឺប្ដីខ្ញុំគេឲ្យទៅនៅកងបុរស ចេញទៅឆ្ងាយៗពីសហករណ៍ ឯកូនខ្ញុំពីរនាក់ រ័ត្ន រ៉ុនណារិទ្ធ និង រ័ត្ន ពិសិដ្ឋ គេឲ្យទៅនៅកងកុមារដោយធ្វើការងារដូចមនុស្សធំដែរ ដែលពុំដែលបានរៀនសូត្រអ្វីទេ។ ចំណែកឯរូបខ្ញុំវិញ ដោយសារមានកូនតូចគេឲ្យនៅសហករណ៍ ប៉ុន្តែក៏ពុំបានទៅមើលថែទាំកូនដែរ គឺត្រូវចេញទៅធ្វើការងារកសិកម្ម លើកទំនប់ ជីកប្រឡាយ និងការងារផ្សេងៗទៀត បាត់ៗរហូតដល់ម៉ោងប្រាំបួន ដប់យប់ទើបបានមកជួបមុខកូនៗដែលទុកឲ្យយាយៗមើល យូរៗទើបខ្ញុំបានជួបមុខប្ដី និងកូនពីរនាក់ដែលនៅកងមួយភ្លែត។ នៅក្នុងអំឡុងខែកក្កដា ឆ្នាំ១៩៧៦ កងរបស់ប្ដីខ្ញុំបានផ្លាស់មកនៅជិតសហករណ៍វត្តហ្លួង ដែលខ្ញុំរស់នៅ ប៉ុន្តែមិនឃើញប្ដីខ្ញុំសោះ។ ថ្ងៃមួយខ្ញុំឃើញបុរសម្នាក់ (មិនស្គាល់ឈ្មោះ) ដែលនៅកងជាមួយប្ដីខ្ញុំ ពាក់អាវប្ដីរបស់ខ្ញុំ។ ឃើញដូច្នេះ ខ្ញុំក៏ទៅសួររកប្ដីខ្ញុំ មុនដំបូងបុរសនោះមិនហ៊ានប្រាប់ខ្ញុំទេ តែក្រោយមក ទើបគាត់ខ្សឹបប្រាប់ខ្ញុំថា ប្ដីខ្ញុំឈ្មោះ រ័ត្ន ហ៊ល នោះត្រូវកងឈ្លបចាប់យកទៅសម្លាប់ចោលបាត់ហើយកាលពីប៉ុន្មានថ្ងៃមុន តែមិនដឹងថាមានរឿងអ្វីនោះទេ។ គ្រាន់តែទទួលដំណឹងនោះភ្លាម ខ្ញុំរន្ធត់ចិត្តស្ទើរសន្លប់បាត់ស្មារតី ហើយក៏មិនហ៊ានសួរនាំវែងឆ្ងាយតទៅទៀតដែរ។ ចាប់ពីពេលនោះមក ខ្ញុំហាក់អស់សង្ឃឹមក្នុងជីវិត តែប្រឹងតស៊ូដើម្បីបាននៅមើលមុខកូនៗដែលនៅតូចៗនៅឡើយ។ ប៉ុន្តែដោយសារអាហារហូបចុកមិនគ្រប់គ្រាន់ ឈឺគ្មានថ្នាំព្យាបាល និងពុំទទួលបានការថែទាំត្រឹមត្រូវរយៈពេលជិត៤ខែប៉ុណ្ណោះ គឺពីខែកញ្ញា ដល់ខែធ្នូ ឆ្នាំ១៩៧៦ កូនខ្ញុំទាំងប្រាំមួយនាក់បានស្លាប់ដោយសារជំងឺខ្វះជីវជាតិអាហារជាបន្តបន្ទាប់រហូតអស់គ្មានសល់ម្នាក់ឡើយ ដោយស្លាប់ក្នុងមួយខែពីរនាក់ក៏មាន"។

[១១:១៦:៤៨]

ដើមបណ្ដឹងរដ្ឋប្បវេណីនេះក៏បានបញ្ជាក់ថា អ្នកនៅក្នុងសហករណ៍នោះបានបាត់ខ្លួនជាបន្តបន្ទាប់ និងខ្លះបានស្លាប់ដោយសារជំងឺអត់អាហារស្ទើររាល់ថ្ងៃ។ "នៅពេលប្ដី និងកូនៗស្លាប់អស់ រូបខ្ញុំស្ទើរក្លាយជាមនុស្សឡប់សតិទៅហើយ"។

ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ទៀតដែលមានលេខសម្គាល់ D22/2818 ត្រង់លេខ ERN 00556

891 ជាភាសាខ្មែរ បានលើកឡើងថា “នៅមុនឆ្នាំ១៩៧៥ នាងខ្ញុំរស់នៅក្បែរផ្សារទួលទំពូង ក្រុងភ្នំពេញ។ វំលងឃ្លាបន្តិច “នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នាងខ្ញុំកំពុងនៅផ្ទះជាមួយកូនៗទាំងប្រាំពីរនាក់ និងស្វាមីនាងខ្ញុំឈ្មោះ មេ ទុំ នៅកំពុងកន្លែងធ្វើការ ប៉េសេសង់ត្រាល់ ក្បែរស្តាតចាស់ក្រុងភ្នំពេញ (មិនចាំភូមិ សង្កាត់ ខណ្ឌ) ខណៈនោះនាងខ្ញុំឮសូរកាំភ្លើងធំ និងកាំភ្លើងតូចពីចម្ងាយ ពីគ្រប់ទិសសំដៅចូលក្រុងភ្នំពេញ និងបានសំដៅចូលកន្លែងសំខាន់ៗក្នុងក្រុងភ្នំពេញ ក៏ដូចជាស្ថានីយផ្សាយព័ត៌មានស្ថានីយប៉ុស្តិ៍ទូរស័ព្ទទំនាក់ទំនង នាងខ្ញុំបានដឹងថា នោះគឺជាក្រុមកងទ័ពខ្មែរក្រហម ស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ វ័ណ្ណក្រមា បង់កពណ៌ក្រហម។ ក្រោយពីស្ងកាំភ្លើងបានស្ងាត់ នាងខ្ញុំបានឃើញកងទ័ពខ្មែរក្រហមចូលពេញផ្សារទួលទំពូង ក៏ដូចជាទីក្រុងភ្នំពេញទាំងមូល។ មានកងទ័ពជាច្រើននាក់ មានរថយន្តតូចធំ រថក្រោះ បន្ទាប់ក៏មានខ្មែរក្រហមខ្លះដើរ ខ្លះជិះរថយន្ត ស្រែកប្រកាសដាក់មីក្រូថា សូមពុកម៉ែ បងប្អូនមិត្តយើងទាំងអស់គ្នា ចាកចេញពីផ្ទះជាបន្ទាន់ ដោយមិនចាំបាច់យកអីវ៉ាន់អ្វីទេ ហើយការចាកចេញតែ៧ថ្ងៃតែប៉ុណ្ណោះនឹងត្រូវត្រឡប់មកផ្ទះវិញ ព្រោះខ្លាចទាហានអាមេរិកទម្លាក់គ្រាប់បែក។ ខ្មែរក្រហមបានដាក់ឈើជាសញ្ញាព្រួញ កំណត់សម្គាល់ទិសសម្រាប់ឲ្យប្រជាជនដើរតាមទិសសញ្ញាព្រួញទាំងនោះ និងមិនឲ្យដើរត្រឡប់ក្រោយទេ។ ពេលនោះហើយដែលនាងខ្ញុំ និងកូនៗ ទាំងប្រាំពីរនាក់ត្រូវបានជម្លៀសដោយកងទ័ពខ្មែរក្រហម ហើយបានចេញបែកពីស្វាមីឈ្មោះ មេ ទុំ រហូតដល់បច្ចុប្បន្ន។ ពេលកំពុងធ្វើដំណើរចាកចេញពីលំនៅដ្ឋានទាំងបង្ខំចិត្ត នាងខ្ញុំឃើញកងទ័ពខ្មែរក្រហមសម្លាប់ប្រជាជននៅនឹងកន្លែង ដោយមូលហេតុមិនស្តាប់បញ្ជាក្នុងការជម្លៀសចេញពីលំនៅដ្ឋាន។ នាងខ្ញុំនិងកូនៗប្រាំពីរនាក់ ព្រមទាំងប្រជាពលរដ្ឋជាច្រើននាក់ បានធ្វើដំណើរថ្មើរជើងតាមបណ្តោយផ្លូវជាតិលេខ១អា ឬផ្លូវទៅអ្នកលឿងបានឆ្លងកាត់ស្ពានមួយ (ស្ពានជ្រោយតាអោក) ហើយក៏បានធ្វើ -- ហើយអំឡុងពេលធ្វើដំណើរនោះ នាងខ្ញុំបានឃើញមនុស្សបានស្លាប់តាមបណ្តោយផ្លូវជាតិលេខ១។ ខ្លះស្លាប់អង្គុយលើកៅអីខ្លះស្លាប់ហើម។

[១១:២១:០៥]

ទៅដល់រោងកុនច្បារអំពៅ ពេលដល់វត្តនិរោធបានរយៈពេល៧ថ្ងៃ នាងខ្ញុំបានឃើញខ្មែរក្រហមស្រែកប្រកាសមីក្រូថា សូមពុកម៉ែ បងប្អូន មិត្តទាំងអស់ដែលធ្លាប់មានសក្តិ ឬធ្វើការងារមានតួនាទីអ្វីគឺត្រូវចុះមកចុះឈ្មោះ ដើម្បីអង្គការបញ្ជូនឲ្យទៅធ្វើការនោះវិញ។ នៅពេលដែលមានបុរសខ្មែរកម្ពុជាក្រោមម្នាក់ (មិនស្គាល់ឈ្មោះ) ដែលបានធ្វើដំណើរជាមួយនាងខ្ញុំ ដោយសារការធ្វើដំណើរលំបាកពេក

គ្មានសក្តិ និងគ្មានតួនាទីអ្វីផង ក៏ចុះឈ្មោះផងដែរ បន្ទាប់មកនាងខ្ញុំក៏បានឃើញអ្នកជិតខាងធ្លាប់រស់នៅក្បែរផ្ទះនាងខ្ញុំម្នាក់ឈ្មោះ ស្រួច (ហៅ ប៉ាអារី) គាត់មានសក្តិ (មិនដឹងស័ក្តិប៉ុន្មានទេ) បានរត់សំដៅទៅចុះឈ្មោះ នាងខ្ញុំក៏ស្រែសួរថា ពូទៅណា? ខ្ញុំទៅទទួលសម្តេចឪ សម្តេចនរោត្តម សីហនុ។ ក្រោយពីបានចុះឈ្មោះរួចរាល់ ខ្មែរក្រហមឲ្យប្រជាជនរាប់រយនាក់ទាំងនោះស្លៀកពាក់សម្លៀកបំពាក់ស្អាតៗ ឈរតម្រង់ជួរជាជួរលើបណ្តោយផ្លូវជាតិលេខ១ ដើម្បីធ្វើដំណើរត្រឡប់ចូលទៅទីក្រុងភ្នំពេញវិញ ដើម្បីទទួលសម្តេចឪ។ នាងខ្ញុំនិងកូនទាំងប្រាំពីរនាក់ក៏បានបន្តដំណើររួមជាមួយប្រជាជនដទៃទៀត ទៅមុខបន្តទៀត"។

[១១:២២:៥៧]

ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀត ដែលមានលេខ D22/40 ត្រង់លេខ ERN ជាភាសាខ្មែរ 00323606។ បានលើកឡើងថា "នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យើងត្រូវបានបណ្តេញចេញពីភ្នំពេញ ក្រោមការគំរាមកំហែងដោយអាវុធ។ ពួកទាហានខ្មែរក្រហមបាននិយាយប្រាប់យើងថា ពួកអាមេរិកាំងនឹងទម្លាក់គ្រាប់បែកមកលើទីក្រុង ហើយពួកយើងត្រូវតែធ្វើការចាកចេញក្នុងរវាងប៉ុន្មានថ្ងៃទៀត ដើម្បីរកកន្លែងជ្រកកោនពីការទម្លាក់គ្រាប់បែកនេះ។ ពេលនោះខ្ញុំនៅជាមួយឪពុកម្តាយខ្ញុំ ហើយនិងកូនខ្ញុំបីនាក់ទៀត អាយុ៨, ៥ និង ៤ឆ្នាំ ព្រមទាំងប្អូនប្រុសម្នាក់ ប្អូនស្រីម្នាក់របស់ខ្ញុំ"។ ដើមបណ្តឹងរដ្ឋប្បវេណីនេះបានលើកថា "ពេលដែលទៅដល់មូលដ្ឋាន ខ្ញុំត្រូវបានគេបង្ខំឲ្យធ្វើការ។ ខ្ញុំជីកគាស់រានចម្ការដើម្បីដាំពោត ឬពេលខ្លះខ្ញុំកាប់រានព្រៃឈើ។ ជារៀងរាល់ថ្ងៃ ខ្ញុំធ្វើការតាំងពីព្រលឹមទាល់ព្រលប់ដោយពុំដែលមានពេលសម្រាកទាល់តែសោះ។ ខ្ញុំត្រូវបានឃ្លាំមើលដោយពួកឈ្លបនៃកងទ័ពខ្មែរក្រហម។ ខ្ញុំភ័យខ្លាចជាខ្លាំង ទោះជាបី -- ទោះបីជាពេលដែលខ្ញុំឈឺ ឬនឿយហត់ក៏ខ្ញុំមិនអាចសម្រាកបានឡើយ។

[១១:២៥:០៨]

ដើមបណ្តឹងរដ្ឋប្បវេណីមួយទៀត ដែលមានលេខ D22/35 ត្រង់លេខ ERN ចាប់ពី 00323529 ជាភាសាខ្មែរ បានលើកឡើងថា "នៅថ្ងៃ១៧ មេសា ខ្ញុំរស់នៅក្រុងភ្នំពេញជាមួយបងប្អូនស្រីទាំងប្រាំនាក់ បងប្អូនប្រុសបីនាក់ និងឪពុកម្តាយខ្ញុំនៅម្តុំអយស្ម័យយាន ដោយរស់នៅក្នុងនិវេសនដ្ឋានសម្រាប់មន្ត្រីរដ្ឋការផ្នែកអយស្ម័យយាន។ បន្ទាប់ពីថ្ងៃត្រង់បន្តិច -- សូមរំលងឃ្លាបន្តិច "បន្ទាប់ពីថ្ងៃត្រង់បន្តិចមក ឪពុកម្តាយខ្ញុំបានប្រកាសប្រាប់ខ្ញុំ និងសមាជិកគ្រួសារទាំងអស់ថា ពួកយោធាខ្មែរក្រហមឲ្យចាកចេញពីផ្ទះបណ្តោះអាសន្ន ដោយហេតុថា អាមេរិកាំងនឹងទម្លាក់គ្រាប់បែកក្នុងពេលខ្លីខាងមុខ"។

រំលងបន្តិចទៀត "នៅតាមផ្លូវទាហានខ្មែរក្រហមជាអ្នកកំណត់ផ្លូវដែលត្រូវដើរ គឺធ្វើយ៉ាងណាកុំឱ្យចាកចេញពីផ្លូវនោះបាន។ យោធាខ្មែរក្រហមដែលមានអាវុធអាកា៤៧ មិនរួញរានឹងសម្លាប់អ្នកដែលមិនដើរតាមផ្លូវដែលត្រូវធ្វើដំណើរ ឬក៏ឃ្លាតឆ្ងាយពីផ្លូវនោះទេ។ ខ្ញុំចាំបានយ៉ាងច្បាស់ថា ខ្ញុំធ្លាប់បានឃើញការសម្លាប់បែបនេះដែរ"។

[១១:២៧:០០]

ដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបទៀតដែលមានលេខសម្គាល់ D22/3751 ដែលមានលេខ ERN សម្គាល់ជាភាសាខ្មែរ -- សូមទោស ខ្ញុំសូមរំលងដោយសារជាន់គ្នា។

ដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបទៀត គឺលេខ D22/2451 ត្រង់លេខ ERN ជាភាសាខ្មែរ លេខ 00551621 បានលើកឡើងថា "នាងខ្ញុំមានឈ្មោះ អាយុ៦៣ឆ្នាំ រស់នៅភូមិព្រៃធំ ឃុំទូកមាសខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត។ ប្ដីនាងខ្ញុំឈ្មោះ កើត លន់ អាយុ៦៥ឆ្នាំ និងមានកូនប្រាំនាក់។ នៅឆ្នាំ ១៩៧០ គ្រួសារនាងខ្ញុំរស់នៅទីក្រុងភ្នំពេញធ្វើកម្មករ រកស៊ីធម្មតា។ លុះដល់ឆ្នាំ៧៥ ខ្មែរក្រហមចូលវាយភ្នំពេញ នាងខ្ញុំ និងគ្រួសារបាននាំគ្នាមករកស្រុកកំណើតវិញ ពេលដែលមកដល់ស្រុក គេចាត់ទុកថាគ្រួសារខ្ញុំជាពួក១៧ គឺពួកថ្មី។ ពេលនោះកម្មាភិបាលខ្មែរក្រហមបានមករឹបអូសមាសប្រាក់របស់នាងខ្ញុំអស់។ ពេលនោះ នាងខ្ញុំរកអ្វីចិញ្ចឹមកូនមិនបាន គឺរស់ដោយសារលួចដូរខោអាវបន្តិចបន្តួចដូរជាមួយបងប្អូនមូលដ្ឋាន"។

[១១:២៩:២៥]

ដើមបណ្ដឹងរដ្ឋប្បវេណីបន្ទាប់ ដែលមានលេខ D22/1794 ត្រង់លេខ ERN ជាភាសាខ្មែរលេខ 00535334 បានលើកឡើងថា "នៅឆ្នាំ១៩៧៥ កម្មាភិបាលខ្មែរក្រហមបានជម្លៀសម្ដាយខ្ញុំ ព្រមទាំងមាមីង និងក្មួយៗទាំងអស់ចំនួនប្រាំពីរនាក់ ឱ្យទៅនៅឃុំអន្លុងកី ឃុំត្រពាំងស្ដៅ ស្រុករំដួលខេត្តស្វាយរៀង ព្រមទាំងបានបង្ខិតបង្ខំឱ្យធ្វើការជាទម្ងន់ ធ្វើហួសកម្លាំង ពេលឈឺថ្កាត់គ្មានថ្នាំព្យាបាល ហូបបបរបន្តិចបន្តួចគ្មានសេរីភាព វាចោទថាជាពួក១៧មេសា"។

ខ្ញុំនៅមិនច្រើនទៀតទេ ដើមណ្ដឹងរដ្ឋប្បវេណីបន្ទាប់ទៀត មានលេខ D22/3461 លេខ ERN ជាភាសាខ្មែរ 00566392 បានលើកឡើងថា "៣ថ្ងៃ ក្រោយពី -- ក្រោយ ១៧មេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវពួកខ្មែរក្រហមបង្ខំឱ្យចាកចេញពីទីក្រុងភ្នំពេញធ្វើដំណើរតាមផ្លូវជាតិលេខ៥ ហើយបានឆ្លងទន្លេនៅត្រង់គីឡូម៉ែត្រលេខ៦ ដោយមិនមានយកសម្ភារៈមានតម្លៃទៅតាមខ្លួនទេ ព្រោះពួកខ្មែរក្រហមប្រាប់ឱ្យចេញ

តែ៣ថ្ងៃប៉ុណ្ណោះដើម្បីរៀបចំទីក្រុង។

[១១:៣១:៤៩]

នៅតាមផ្លូវអ្នកមិនព្រមចាកចេញ គេគំរាមបាញ់សម្លាប់ ហើយមានសាកសពទាហាន លន់ នល់ ជាច្រើនស្លាប់តាមផ្លូវ។ ខ្ញុំត្រូវពួកវាបង្ខំឲ្យដើរតាមបញ្ជារបស់ពួកវា គឺដើរតាមស្ពានកំពង់ចាម ព័ទ្ធតាមជីហែ ទើបមកដល់ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ដោយធ្វើដំណើរជាង១៥ថ្ងៃ។ ពេលមកដល់ឃុំវិហារសួគ៌ ខ្ញុំនិងប្ដីបានរស់នៅជាមួយបងស្រីឈ្មោះ ឃឹម នាង បាន ៥ថ្ងៃ ហើយប្ដីខ្ញុំសុំទៅរស់នៅស្រុកក្រូចឆ្មារ ខេត្តកំពង់ចាមជាមួយម្ដាយក្មេងវិញ។ ទៅដល់ក្រូចឆ្មារបានមួយយប់ ពួកវាបញ្ជូនខ្ញុំ និងប្ដីឲ្យទៅរស់នៅម្ដុំជាមួយអ្នក១៧មេសា នៅក្នុងវត្តខ្ពប។ មួយរយៈក្រោយមកពួកវាបានបញ្ជូនពួកខ្ញុំទៅនៅតំបន់ថ្មីមួយទៀត គឺភូមិជាំម្លូដែលជាតំបន់ចាញ់។ នៅភូមិជាំម្លូមានផ្ទះជាង១០០ខ្នង សុទ្ធតែអ្នក១៧មេសា ដែលជម្លៀសមកពីកន្លែងផ្សេង ហើយពេលនោះពួកវាប្រើប្ដីខ្ញុំឲ្យទៅកាប់ឫស្សីបន្លាក្នុងមួយគុម្ព១ថ្ងៃ។ ចំណែកខ្ញុំកិនស្រូវនៅរោង“គ” ក្នុងសហករណ៍ភូមិជាំម្លូ ហើយក្នុង១ថ្ងៃពួកខ្ញុំបានបបរអង្ករកន្លះកំប៉ុង តែគ្មានម្ហូបទេ មានតែទឹកអំបិល”។

[១១:៣៣:៥៥]

ដើមបណ្ដឹងរដ្ឋប្បវេណីបន្ទាប់មានលេខ សម្គាល់ D22/231 ត្រង់លេខ ERN ជាភាសាខ្មែរ 00421213 គាត់បានលើកឡើងថា “នៅមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ គ្រួសារខ្ញុំរស់នៅក្នុងទីក្រុងភ្នំពេញ គឺនៅម្ដុំខាងជើងផ្សារអូរឫស្សីជិតរោងកុនអង្គរ។ ខ្ញុំមានប្ដីឈ្មោះ អ៊ុក ជា មុខរបរធ្វើទាហាន លន់ នល់។ រូបខ្ញុំជាមេផ្ទះ ខ្ញុំមានកូនទាំងអស់ប្រាំពីរនាក់ ស្រីពីរ ប្រុសប្រាំ សុទ្ធតែរៀនទាំងអស់។ នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ពេលចូលឆ្នាំខ្មែររួចទាហានខ្មែរក្រហមស្លៀកពាក់ខ្មៅបានចូលដល់ទីក្រុងភ្នំពេញ។ ពេលនោះគេបានបាញ់កាំភ្លើងផង ភ្លង់គំរាមផង បង្ខំឲ្យប្រជាជនទាំងអស់ រួមទាំងគ្រួសាររបស់ខ្ញុំផងចេញពីទីក្រុងទៅនៅតាមជនបទស្រែចម្ការមួយរយៈសិន។ ដោយមានការភ័យខ្លាច គ្រួសារខ្ញុំបាននាំកូនៗទាំងប្រាំពីរនាក់ចាកចេញពីផ្ទះ ដោយយកអីវ៉ែអីវ៉ាន់តែបន្តិចបន្តួចព្រោះគ្មានមធ្យោបាយដឹកជញ្ជូន។ យើងបាននាំកូនដើរដោយជើងទទេ គ្មានយានជំនិះ ហើយម្នាក់ៗសុទ្ធតែមានកាន់ទូលយួរអីវ៉ាន់ខ្លះផង។ ដំបូងធ្វើដំណើរជាមួយប្រជាជនជាច្រើនកុះករតាមផ្លូវជាតិលេខ១ ទៅទិសខាងកើតតាមបញ្ជារបស់ទាហានខ្មែរក្រហម។ ពេលទៅដល់អ្នកលឿង ពួកខ្ញុំក៏ចុះពីផ្លូវជាតិ ធ្វើដំណើរតាមផ្លូវលំទៅទិសខាងត្បូង រួចបត់មកខាងលិចវិញ ក្នុងគោលបំណងទៅស្រុកកំណើតរបស់ប្ដីខ្ញុំនៅឯស្រុកសំរោង ខេត្ត

តាកែវ ក្រែងបានជួបបងប្អូនញាតិសន្តានខ្លះ។ យើងធ្វើដំណើរអស់រយៈពេលប្រហែល២ខែ ទើបទៅដល់គោលដៅ។ ការធ្វើដំណើរមានការលំបាកវេទនាជាទីបំផុត ព្រោះខ្ញុំទើបនឹងសម្រាលកូនបានប្រហែល២សប្តាហ៍ប៉ុណ្ណោះ ត្រូវដើរដោយជើងទទេរាប់រយគីឡូម៉ែត្រក្រោមកម្តៅថ្ងៃខែចែត្រ គ្មានទឹក និងស្បៀងអាហារគ្រប់គ្រាន់។ ខ្ញុំមានការអាសូរដល់កូនតូចៗរបស់ខ្ញុំខ្លាំងណាស់ ព្រោះជាញឹកញាប់ពួកគេបានស្រែកយំ ដោយសារភាពនឿយហត់ក្នុងការធ្វើដំណើរ និងស្រេកឃ្លានអាហារដ៏គួរសង្វេគបំផុត។

[១១:៣៦:៥១]

ពេលមកដល់ស្រុកកំណើតប្តីខ្ញុំ នៅភូមិអង្គរផ្លៀង ឃុំសំរោង ស្រុកសំរោង ខេត្តតាកែវ ខ្ញុំភ្លេចឈ្មោះកន្លែងដែលខ្មែរក្រហមដាក់ជាលេខនោះហើយ។ គ្រួសារខ្ញុំគេចាត់ទុកជាអ្នក១៧ មេសា ត្រូវអ្នកស្រុកទីនោះរើសអើងប្រមាថមើលងាយ ឯបងប្អូនខាងប្តីខ្ញុំមិនសូវរាប់រកដែរ។ គេមិនបានផ្តល់ស្បៀងអាហារឲ្យពួកខ្ញុំបានហូបគ្រប់គ្រាន់ដូចអ្នកមូលដ្ឋានទេ។

ដើមបណ្តឹងរដ្ឋប្បវេណី D22/2751 ត្រង់លេខERN ជាភាសាខ្មែរ 00556117 បានលើកឡើងថា "ថ្ងៃទី១៧ មេសា ១៩៧៥ គ្រួសារខ្ញុំរស់នៅទីក្រុងភ្នំពេញ។ ប្តីខ្ញុំជាទាហាន លន់ នល់ នៅថ្ងៃនោះពួកខ្មែរក្រហមបានចូលរំដោះទីក្រុងភ្នំពេញបាន៣ថ្ងៃ ពួកវាក៏ចាប់ផ្តើមបណ្តេញប្រជាជនឲ្យចេញពីទីក្រុងភ្នំពេញ។ នៅក្នុងពេលនោះពួកអាវខ្មៅ -- ខោអាវខ្មៅ គឺពួកខ្មែរក្រហមបានបាញ់គំរាមកំហែងស្ទើរគ្រប់ទីកន្លែង ជួនកាលវាបាញ់សម្លាប់គ្រួសារដែលនៅជិតខាងផ្ទះរបស់ខ្ញុំ ហើយពួកវាស្រែកថា បើអាណាមិនចេញ អញបាញ់ចោល។ ក្រោយមកវាក៏ស្រែកបន្តទៀតថា អាណាមកពីភូមិស្រុកណា ទៅភូមិស្រុកនោះវិញ ដើម្បីទុកទីក្រុងឲ្យរៀបចំឡើងវិញ។

[១១:៣៨:៤៨]

ពេលធ្វើដំណើរពីទីក្រុងភ្នំពេញ ចេញតាមបណ្តោយផ្លូវជាតិលេខ២ ដើម្បីមកស្រុកកំណើតវិញ ខ្ញុំក៏បានឃើញសាកសពហើមស្អុយជាប់កែងផ្លូវ។ ខ្ញុំបានធ្វើដំណើរអស់រយៈពេលជាង១ខែទើបមកដល់កន្លែងដែលពួកវាឲ្យស្នាក់នៅ។ គេហៅឃុំនោះថា ឃុំអូរអន្លក់។ គ្រួសារខ្ញុំបានរស់នៅទីនោះរយៈពេល៣ថ្ងៃ រួចពួកវាក៏បញ្ជូនគ្រួសារខ្ញុំឲ្យទៅនៅភូមិតាអាំ ឃុំរាមអណ្តើក ស្រុកគិរីវង់ ខេត្តតាកែវ។ គ្រួសារខ្ញុំរស់នៅទីនោះ ពួកវាតែងតែហៅពួកខ្ញុំថា អាពួក១៧ មេសា (សូមទោស) អាពួក១៧។ ហើយវាឲ្យគ្រួសារខ្ញុំធ្វើការជាច្រើន ជាពួកនៅមូលដ្ឋាន។ ហើយពួកវាឲ្យពួកខ្ញុំហូបតិចជាងពួកនៅទីនោះ បើគេចែកបបរឲ្យមួយចាន ពួកខ្ញុំបានកន្លះចានតែប៉ុណ្ណោះ។ ដើមបណ្តឹងរដ្ឋប្បវេណីនេះក៏បានលើកឡើងថា

ប្ដីរបស់គាត់ត្រូវបានគេទារុណកម្មនៅវត្តព្រៃរំដេង៣ថ្ងៃ ទើបពួកវាយកទៅសម្លាប់ចោល។

[១១:៤០:១៩]

ដើមបណ្ដឹងរដ្ឋប្បវេណីបន្ទាប់មានលេខ D22/519 ត្រង់លេខ ERN ជាភាសាខ្មែរ 00496869 បានលើកឡើងថា “ដើមឆ្នាំ៧៦ ពេលអត់ពីឪពុកខ្ញុំ គ្រួសាររបស់ខ្ញុំត្រូវបានពួកខ្មែរក្រហមប្រមូលឲ្យជិះឡានចេញពីភូមិនេះទៅភូមិផ្សេងទៀត។ ពួកខ្មែរក្រហមយកឡានមកដឹកប្រជាជន គឺឡាន សេអ៊ីមសេកង់១០ ដោយដឹកពួកមូលដ្ឋានដាក់ឡានផ្សេងពីអ្នក១៧ មេសា។ ពេលនោះ ឡានអ្នក១៧ មេសា ពេញគ្រួសារខ្ញុំក៏ត្រូវពួកខ្មែរក្រហមឲ្យឡើងឡាន ឡើងជិះឡានជាមួយពួកមូលដ្ឋាន។ ពេលជិះឡានមកតាមផ្លូវជាតិលេខ៣ ខេត្តកំពត ពេលមកដល់ជ្រោះប្ញកគោ មានឡានប្រាំពីរជាឡានដឹកប្រជាជន១៧ មេសា បានបត់ចូលទៅកន្លែងជ្រោះជ្រៅ ដោយថយឡានចាក់ប្រជាជននៅក្នុងជ្រោះទាំងអស់។ ចំណែកឡានមូលដ្ឋានមានបីឡាន នាំប្រជាជនឲ្យមកស្នាក់នៅឃុំទូកមាស ស្រុកទូកមាស ខេត្តកំពត។ ពេលនោះគ្រួសារនាងខ្ញុំត្រូវខ្មែរក្រហមឲ្យទៅរស់នៅភូមិខ្លាយ ខាងជើងទូកមាស ស្រុកទូកមាស ខេត្តកំពត”។

[១១:៤២:១៨]

ដើមបណ្ដឹងរដ្ឋប្បវេណីលេខ D22/3623 ត្រង់លេខ ERN ចាប់ពីលេខ 00567828 ជាភាសាខ្មែរ បានលើកឡើងថា “មុនឆ្នាំ១៩៧៥ ខ្ញុំធ្វើជាទាហាន លន់ នល់ រស់នៅភូមិកោះធំ ស្រុកស្អាង ខេត្តកណ្ដាល រហូតដល់ឆ្នាំ១៩៧៥ ពេលក្រុមខ្មែរក្រហមច្បាំងឈ្នះទាហាន លន់ នល់ ខ្ញុំឈប់ធ្វើទាហានលន់ នល់ ហើយខំលាក់ប្រវត្តិរូបមិនឲ្យគេដឹងថាបានធ្វើទាហាន លន់ នល់ ទេ។ បន្ទាប់ពីខ្មែរក្រហមបានទទួលជ័យជម្នះ ខ្ញុំនិងក្រុមគ្រួសារត្រូវបានទាហានខ្មែរក្រហមធ្វើការជម្លៀសដោយប្រជុំថា អង្គការរៀប -- អង្គការយើងរៀបចំប្រទេសជាតិឲ្យជាសង្គមនិយម។ សូមបងប្អូនចេញទៅខាងភូមិភាពពាយ័ព្យមួយរយៈសិន។ ហើយអង្គការបានជម្លៀសខ្ញុំ និងក្រុមគ្រួសារដោយឲ្យដើរថ្មើរជើង ហើយសម្ភារៈមួយចំនួនគឺទូល រែក ដោយកម្លាំង។ ការធ្វើដំណើរដោយថ្មើរជើងមានរយៈពេល២ខែគត់ទើបមកដល់ខេត្តបន្ទាយមានជ័យ (កាលនោះជាខេត្តបាត់ដំបង)។

[១១:៤៣:៥២]

លើកដំបូងចេញពីភូមិកោះធំ ស្រុកស្អាង ខេត្តកំពង់ឆ្នាំង -- ដល់ខេត្តកំពង់ឆ្នាំង។ អង្គការឲ្យឈប់សម្រាករយៈពេលពីរបីថ្ងៃ ហើយជារៀងរាល់ថ្ងៃ អង្គការហៅមកប្រជុំទាំងប្រជាជនថ្មី ទាំងប្រជាជនចាស់ ដោយអង្គការមិនស្គាល់ឈ្មោះបានលើកឡើងថា សូមបងប្អូនពុកម៉ែត្រូវលះបង់របស់ស្ងួនតួ

របបរាជានិយម និងរបបនិយម -- របបនិធននិយម -- របបមូលធននិយម ត្រូវកម្ចាត់ចោលឲ្យអស់ពីក្នុងអារម្មណ៍ពុកម៉ែ។ អង្គការយើងរៀបចំសាជាថ្មីគឺឲ្យមានភាពស្មើគ្នា ដោយគ្មានអ្នកមាន គ្មានអ្នកក្រ ព្រោះកន្លងមករបបមូលធននិយមគឺជាអ្នកជិះជាន់អ្នកក្រ។ អង្គការយើងធ្វើសង្គមនិយមគឺអ្វីៗស្មើគ្នាទាំងអស់ ទ្រព្យសម្បត្តិផ្ទាល់ខ្លួនត្រូវដាក់រួម គឺយើងកសាងប្រទេសជាតិជាថ្មី។ គ្មានវណ្ណៈអ្នកមាន អ្នកក្រទៀតទេ។

ដូច្នេះយើងត្រូវលត់ដំជាថ្មី ត្រូវប្រើកម្លាំងពលកម្មទាំងអស់គ្នា គឺធ្វើដោយស្ម័យប្រវត្តិ មិនឲ្យអ្នកមានជិះជាន់អ្នកក្រទេ ទើបកសាងប្រទេសជាតិឈានឡើងជាសង្គមនិយមបាន។ អង្គការបែងចែកប្រជាជនជាពីរក្រុម គឺមួយក្រុមទៅខាងពួកនិរតី ភូមិភាគនិរតី និងមួយក្រុមទៀតទៅភូមិភាគពាយ័ព្យ។ ក្រុមខ្ញុំត្រូវទៅភូមិភាគពាយ័ព្យ គឺត្រូវមកនៅភូមិខ្នឹង ឃុំស្នួរ ខេត្តបាត់ដំបង (បច្ចុប្បន្នជាខេត្តបន្ទាយមានជ័យ)។ ពេលមកដល់រស់នៅក្នុងភូមិនោះ អង្គការតែងតែចាត់ទុកគ្រួសារខ្ញុំជាប្រជាជនថ្មី ប្រជាជន ១៧ មេសា ១៩៧៥។ តែអង្គការឲ្យខ្ញុំចូលទៅធ្វើការជាមួយប្រជាជនមូលដ្ឋាន"។

[១១:៤៦:៥៧]

ដើមបណ្តឹងរដ្ឋប្បវេណីមួយទៀត ដែលមានលេខ D22/1414 បានលើកឡើងថា នៅក្នុងលេខទំព័រ ERN ជាភាសាខ្មែរ 00528133 ថា "បន្ទាប់មកនៅខែស្ទួង ខែភ្លៀង មនុស្សដែលត្រូវគេជម្លៀសទៅថ្នល់បត់ ស្រុកបាកាន ខេត្តពោធិ៍សាត់ ត្រូវបានគេចាត់ទុកជាប្រជាជន ១៧មេសា។ ពួកគេត្រូវគេឃ្លាំមើលយ៉ាងទៀងទាត់ពីសំណាក់ទាហានឈ្លប។ គ្រួសារខ្ញុំក៏ត្រូវពួកវាចាត់ទុកជាប្រជាជន ១៧មេសាដែរ។ ទោះជាយើងដើរទៅណាមួយជំហានក៏ពួកវាឃ្លាំមើលឪពុកម្តាយខ្ញុំដែរ ហើយពួកវាសួរប្អូនរបស់ខ្ញុំថា ឪពុកម្តាយរបស់ឯងធ្វើអ្វី? បើប្រាប់ឪពុកម្តាយ នឹងបានធ្វើធំ។ ពួកវាពូកែតាមដានណាស់ មិនថាចាស់ ឬក្មេងនោះទេ សុទ្ធតែចាញ់កលពួកវាទាំងអស់ ដូចអ្នកខ្លះដែលជាអាជីវករ ខ្លះជាទាហាន អ្នកខ្លះជាគ្រូ ដែលពួកវាចាត់ទុកថាជាប់និន្នាការនោះ គឺពួកវាឃោសនាឲ្យទៅធ្វើការកន្លែងចាស់នោះ ពួកគាត់ទាំងនោះសុទ្ធតែឆ្លើយថា ធ្វើនេះធ្វើនោះ ត្រូវពួកវាដឹងទាំងអស់ ត្រូវពួកវាដឹកទាំងឡានៗយកទៅ។

[១១:៤៧:៣៨]

នេះគឺជាទម្រង់បែបបទព័ត៌មានចុងក្រោយសម្រាប់ ពាក់ព័ន្ធទៅនឹងការជម្លៀសទី១ និងជម្លៀសទី២។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះគឺមានលេខ D22/2470 ត្រង់ទំព័រដែលមានលេខ ERN ជាភាសាខ្មែរ 00551851។ ដើមបណ្តឹងរដ្ឋប្បវេណីនេះបានលើកឡើងថា "ក្រោយថ្ងៃ១៧ មេសា ១៩៧៥ ពួក

ប៉ុល ពត បានជម្លៀសឪពុកខ្ញុំបាទ បូកនឹងក្រុមគ្រួសាររបស់ខ្ញុំបាទពីភ្នំពេញ ឲ្យមករស់នៅភូមិត្រពាំងឈូក ឃុំកក់ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ជាស្រុកកំណើតរបស់ឪពុកខ្ញុំបាទ។ លុះមកដល់ទីកំណើតវិញ ពួកកម្មាភិបាល ប៉ុល ពត បានប្រមូលអ្នក ១៧មេសា ទាំងប៉ុន្មានយកមកដាក់ភូមិមួយ ហៅថា ភូមិថ្មី ឃុំកក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ (សូមបញ្ជាក់ថា បច្ចុប្បន្នជាស្រុកបរសេដ្ឋ ក្នុងខេត្តកំពង់ស្ពឺ)។ ភូមិថ្មីនេះពួកវារៀបចំឡើងសម្រាប់តែអ្នក១៧មេសាតែប៉ុណ្ណោះ។ លុះមកដល់ខែវិច្ឆិកា ឆ្នាំ១៩៧៦ ត្រូវបានពួកកម្មាភិបាល ប៉ុល ពត បានហៅឪពុកខ្ញុំបាទនៅវេលាម៉ោងប្រាំមួយល្ងាច បូកនឹងអ្នក១៧មេសា ក្នុងភូមិថ្មីទាំងអស់ ទៅដាំដំឡូងមីនៅភ្នំកក់ ចម្ងាយដីប្រហែល ៤០០ម៉ែត្រពីភូមិថ្មី ដាំដំឡូងរហូតដល់ម៉ោងដប់យប់ហើយ អស់ពួកវាបានឲ្យកងឈ្លបឃុំកក់ និងមេភូមិទៅចាប់ឪពុកខ្ញុំបាទយកមកវ៉ៃធ្វើទារុណកម្មយ៉ាងព្រៃផ្សៃឃោរឃៅបំផុត។ ពួកវាចាប់ក្រៀក ហើយវះពោះយកថ្លើមមកធ្វើស៊ីយ៉ាងព្រៃផ្សៃបំផុត។ បច្ចុប្បន្នកន្លែងពិឃាដនៅខាងជើងអនុវិទ្យាល័យរត្នមុនី ក្នុងឃុំកក់ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។ ក្រោយពីសម្លាប់ឪពុកហើយ ពួកវាបានចាត់តាំងឲ្យកងឈ្លបឃុំតាមដានក្រុមគ្រួសារខ្ញុំបន្តទៀត ព្រោះវាថាពួកអាបំណុលឈាម ហើយពួកវាធ្វើបាបមិនឲ្យស៊ីគ្រប់គ្រាន់ និងធ្វើការជាទម្ងន់។ លុះដល់ឆ្នាំ១៩៧៧ ពួកវាបានចាប់បញ្ជូនម៉ែខ្ញុំ រូបខ្ញុំ និងប្អូនខ្ញុំយកទៅដាក់នៅមន្ទីរឃុំឃាំងជ្រៃអូរញ៉ៅ ហៅកន្លែងតំបន់ អតីតស្រុកគងពិសី នៅមន្ទីរ ឃុំឃាំងនោះ ពួកវាបានឲ្យម៉ែខ្ញុំ រូបខ្ញុំនិងប្អូនខ្ញុំធ្វើការទាំងយប់ទាំងថ្ងៃ បាក់កម្លាំងស៊ីមិនឆ្អែត មិនដែលឆ្អែត ពេលឈឺ វាឲ្យលេបតែថ្នាំអាចម៍ទន្សាយ បើឈឺបន្តិចបន្តួចមិនហានឈប់ធ្វើការទេ ខ្លាចពួកវាថាទម្រន់ គឺវ៉ៃចោលតែម្តង។ ចំណែកឯផ្ទះសម្បែង ពួកវាបានរុះមកធ្វើជាស្ពានយកទ្រព្យសម្បត្តិទាំងអស់ ហើយបង្ខំឲ្យធ្វើការជាទម្ងន់យ៉ាងឃោរឃៅបំផុត”។

[១១:៥១:៣៣]

ខ្ញុំនៅមានទម្រង់បែបបទចំនួនបួនថែមទៀត ពាក់ព័ន្ធទៅហ្នឹងទួលពោធិ៍ជ្រៃ។ ដើម្បីបណ្តឹងរដ្ឋប្បវេណីលេខ D22/1079 ត្រង់លេខ ERN ជាភាសាខ្មែរ 00518541 បានលើកឡើងថា “ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានចូលកាន់កាប់ទីរួមខេត្តពោធិ៍សាត់ ហើយបានប្រកាសមីក្រូជម្លៀសប្រជាជន ចេញពីរួមខេត្ត និងរកសមាសភាពមន្ត្រីរាជការ ទាហាន ប៉ូលិស ពេទ្យទៅរៀនសូត្របន្ថែម។ ពេលបានរៀនសូត្រចប់មកវិញ ចំណែកប្រពន្ធកូនចាំទៅតាមក្រោយ។ ទាហានខ្មែរក្រហមបានប្រមូលអ្នកធ្វើការទាំងនោះ ព្រមទាំងឪពុករបស់គាត់ដែលជាទាហានលន់ នល់ ស័ក្តិ២។ ឪពុករបស់ដើមបណ្តឹងរដ្ឋប្បវេណី (សុំទោស) ទៅប្រជុំនៅសាលាខេត្តពោធិ៍សាត់ រួចដឹកដាក់ឡានដំរីទឹកធំៗចេញទៅ

បាត់រហូត ដល់សព្វថ្ងៃ។ ម្តាយរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលគេចោទថា ជាប្រពន្ធទាហាន លន់ នល់ ព្រមទាំងប្អូនរបស់គាត់ពីរនាក់ត្រូវខ្មែរក្រហមសម្លាប់ជាមួយនឹងប្រពន្ធកូនទាហាន លន់ នល់ ដទៃទៀតនៅក្នុងឆ្នាំ១៩៧៧”។

[១១:៥៣:៣៨]

ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀតដែលមានលេខ D22/1529 ដែលមានលេខ ERN ជាភាសាខ្មែរ 00530043 បានលើកឡើងថា “ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ពួកខ្មែរក្រហមចូលកាន់កាប់ទីក្រុងពោធិ៍សាត់ និងប្រកាសឲ្យមន្ត្រីរាជការទាំងអស់ រួមទាំងប្តីរបស់គាត់ទៅរៀនសូត្រពីច្បាប់ថ្មីរយៈពេល៣ខែ -- ៣ថ្ងៃ នៅសាលាខេត្ត បន្ទាប់ត្រូវគេប្រមូលដាក់ឡានដឹកចេញទៅ ប្រហែលម៉ោងដប់ព្រឹកជាច្រើនឡានយកទៅសម្លាប់នៅទួលពោធិ៍ជ្រៃ ដោយគេឃើញមានសាកសពជាច្រើនត្រូវបានសម្លាប់នៅទីនោះ”។

ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀត មានលេខសម្គាល់ D22/2011 ត្រង់លេខ ERN ជាភាសាខ្មែរ 00541770 បានលើកឡើងថា “នៅថ្ងៃ១៨ មេសា ឆ្នាំ១៩៧៥ កងទ័ពរំដោះខោអាវខ្មៅកាន់កាំភ្លើងស្រែកប្រកាសឲ្យប្រជាជនចេញពីលំនៅដ្ឋាន៣ថ្ងៃ ដើម្បីទៅទទួលសម្តេចឪ ហើយអ្នករាជការឲ្យទៅចុះឈ្មោះរៀនសូត្រ ដើម្បីកាន់តំណែងធំរួមទាំងបងជីដូនមួយគាត់ផងដែរ។ អ្នកដែលចុះឈ្មោះត្រូវពួកទាហានខ្មែរក្រហមដឹកឡានយកទៅសម្លាប់ទាំងអស់ ដោយឃើញមានសាកសពជាច្រើននៅបន្ទាយទួលពោធិ៍ជ្រៃ ឃុំកណ្តៀង ស្រុកបាកាន ខេត្តពោធិ៍សាត់។

[១១:៥៦:00]

ដើមបណ្តឹងរដ្ឋប្បវេណីបន្ទាប់លេខ D22/1557 បានលើកនៅក្នុងទម្រង់ព័ត៌មានបែបបទជនរងគ្រោះរបស់គាត់ នៅក្នុងទំព័រ ដែលមានលេខ ERN 00530391 ថា “ឆ្នាំ១៩៧៥ គាត់ជាអតីតទាហានកំម្មង់ដូនៅភូមិក្បាលឈើពុក ឃុំស្វា ស្រុកបាកាន ខេត្តពោធិ៍សាត់ ពេលដែលខ្មែរក្រហមឡើងកាន់អំណាចពេញលេញ គាត់បានប្រគល់អាវុធទៅឲ្យទ័ពខ្មែរក្រហម។ ពេលនោះមានប្រជាជនជាច្រើនត្រូវបានជម្លៀសពីភ្នំពេញ ហើយគេបែងចែកប្រជាជនមូលដ្ឋាន -- បែងចែកពីប្រជាជនមូលដ្ឋាន។ ឆ្នាំ១៩៧៦ អង្គការបានប្រកាសស្វែងរកសមាសភាពអ្នកដែលជាមន្ត្រីរាជការ ទាហាន និស្សិត ពេលប្រជុំជីវភាពដើម្បីទៅរៀនសូត្រ។ ប្អូនថ្លៃគាត់ដែលទហាន លន់ នល់ ពាក់ស័ក្តិ៣ ត្រូវពួកវាយកទៅសម្លាប់នៅបន្ទាយទួលពោធិ៍ជ្រៃ ឃុំកណ្តៀង ស្រុកបាកាន ខេត្តពោធិ៍សាត់។

ខ្ញុំសូមលើកដើមបណ្ដឹងរដ្ឋប្បវេណីចុងក្រោយដែលខ្ញុំមិនបានលើកពីមុន ហើយនិយាយពាក់ព័ន្ធទៅនឹងជម្លៀសដែរ គឺដើមបណ្ដឹងរដ្ឋប្បវេណីលេខ D22/32 នៅក្នុងទំព័រ 00279757 បានលើកឡើងថា "មុនឆ្នាំ១៩៧៥ គ្រួសាររបស់ខ្ញុំរស់នៅផ្សារអូរឫស្សី។ ក្រោយពេលដែលខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ខ្មែរក្រហមជម្លៀសគ្រួសារខ្ញុំទៅពោធិ៍ចិនតុង ម្ដុំបូរី១០០ខ្នងរយៈពេលមួយឆ្នាំ ចុងឆ្នាំចិតសិប (មិនច្បាស់ឆ្នាំ)។ ខ្ញុំ និងគ្រួសារត្រូវបានជម្លៀសចេញពីបូរី១០០ខ្នងទៅនៅពោធិ៍ចិនតុង។ ចេញពីពោធិ៍ចិនតុងទៅស្រុកបាកាន ខេត្តពោធិ៍សាត់។

[១១:៥៨:៤៧]

នៅស្រុកបាកាន បងស្រីរបស់ខ្ញុំត្រូវបានសម្លាប់ដោយខ្មែរក្រហម។ ឯប្អូនស្រីរបស់ខ្ញុំត្រូវស្លាប់ដោយសារជំងឺ។ ខ្ញុំឃើញប្អូនស្រីខ្ញុំស្លាប់ហើមនៅតាមភ្លឺស្រែ។ ក្រោយមកនៅចុងឆ្នាំ១៩៧៨នោះដែរប៉ារបស់ខ្ញុំបានទៅលួចបបរបាយជ្រូក គេយកមកឲ្យម៉ាក់ខ្ញុំ និងខ្ញុំញុំា។ ពេលនោះគេមកចាប់ គេក៏ចាប់ប៉ាខ្ញុំទៅអប់រំ។ តែក្រោយមកប៉ា ខ្ញុំក៏ទៅលួចបាយជ្រូកគេទៀត គេក៏ចាប់បាន។ ហើយពួកឈ្លបនោះចងស្លាបសេកខ្ញុំ ប៉ា ម៉ាក់ខ្ញុំ និងខ្ញុំបណ្ដើរយកទៅសម្លាប់។ ពួកឈ្លបខ្មែរក្រហមឲ្យប៉ាខ្ញុំឈរមុខរណ្ដៅ ហើយចាក់គាត់ពីក្រោយខ្នងទម្លាក់ក្នុងរណ្ដៅ។ ហើយបន្ទាប់ពួកឈ្លបនោះបានចាក់ម្ដាយខ្ញុំទម្លាក់ក្នុងរណ្ដៅទៀត។ ពេលនោះមានឈ្លបខ្មែរក្រហមបានស្រែកឲ្យគ្នាវាស្រាយខ្ញុំចេញទុកចាត់ការ។ ពេលដែលនៅក្នុងរណ្ដៅនោះ ម្ដាយខ្ញុំផ្ដៀតស្រែកកុំឲ្យខ្ញុំព្រមនឹងពួកខ្មែរក្រហមនោះ។

បន្ទាប់មកឈ្លបខ្មែរក្រហមបានចាប់ទាញខ្ញុំទៅរំលោភនៅក្នុងគុម្ពោតព្រៃក្បែររណ្ដៅនោះ។ ពួកឈ្លបខ្មែរក្រហមនោះបានចាប់ខ្ញុំរំលោភម្ដងម្នាក់ៗរហូតគ្រប់គ្នាទាំងបីនាក់ ពេលនោះមានឈ្លបខ្មែរក្រហមម្នាក់ក្នុងចំណោមទាំងបីនាក់នោះ បានប្រាប់ខ្ញុំឲ្យរត់ភៀសខ្លួនទៅសហករណ៍ផ្សេង ព្រោះឈ្លបខ្មែរក្រហមពីរនាក់ទៀតនឹងយកខ្ញុំទៅសម្លាប់ចោល។ ឮសួរដូច្នេះ ខ្ញុំក៏បានរត់ភៀសខ្លួនទៅសហករណ៍មួយទៀត ដែលមានចម្ងាយបួនគីឡូម៉ែត្រ។ ឈ្លបដែលប្រាប់ខ្ញុំឲ្យរត់នោះឈ្មោះ រិទ្ធិ។ នៅពេលដែលខ្ញុំស្នាក់នៅសហករណ៍នោះ បានបីបួនថ្ងៃ ឈ្លបរិទ្ធិ បានទៅរកខ្ញុំឃើញ។ ឈ្លបនោះតែងតែមកលបដេកជាមួយខ្ញុំជារៀងរាល់យប់។ ខ្ញុំរស់នៅសហករណ៍នោះរហូតដល់ថ្ងៃបែករបបខ្មែរក្រហម។ ក្រោយមកបានកើតបានកូនប្រុសមួយ ដោយកូនប្រុសនោះគឺជាលទ្ធផលនៃការរំលោភរបស់ឈ្លបទាំងបីនាក់នោះ"។

សូមអរគុណលោកប្រធាន ខ្ញុំសូមបញ្ចប់ការលើកព័ត៌មានរបស់ជនរងគ្រោះត្រឹមនេះ។ ទាំងអស់នេះគឺជាទម្រង់បែបបទជនរងគ្រោះមួយចំនួនតែប៉ុណ្ណោះ ហើយនៅមានទម្រង់បែបបទជនរងគ្រោះជា

ច្រើនផ្សេងទៀត ដែលយើងខ្ញុំថា ពេលនេះមិនទាន់ -- មិនមានពេលនឹងអនុញ្ញាតឲ្យយើងខ្ញុំលើកបានទេ។ ដូច្នេះ យើងខ្ញុំសូមលើកតែប៉ុណ្ណេះចុះ។ សូមអរគុណលោកប្រធាន។

[១២:០១:៤៧]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះដល់ពេលសមល្មមសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយនៅរសៀលនេះអង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅភាគីមេធាវីការពារក្តីទាំងបីក្រុម ដែលចាប់ផ្តើមពីមេធាវីការពារក្តី នួន ជា ដើម្បីមានឱកាសក្នុងការធ្វើអត្ថាធិប្បាយ ឬជំទាស់ចំពោះបណ្តាឯកសារគន្លឹះនានា ដែលតំណាងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដាក់បង្ហាញពាក់ព័ន្ធនឹងអង្គហេតុនៃការបម្លាស់ទីប្រជាជននៅដំណាក់កាលទី១ ទី២ និងទីកន្លែងសម្លាប់នៅទួលពោធិ៍ជ្រៃ។ ហើយក៏ជាការបន្ថែមដែរ គឺពាក់ព័ន្ធជាមួយនឹងអង្គហេតុនៃរចនាសម្ព័ន្ធកងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលដាក់បង្ហាញឯកសារដោយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅព្រឹកមិញនេះ ហើយនឹងអាចផ្តល់វេទិកាជូនទៅភាគីមេធាវីការពារក្តីដាក់បង្ហាញឯកសារគន្លឹះនានា ពាក់ព័ន្ធទៅនឹងអង្គហេតុ ដូចអង្គជំនុំជម្រះបានបញ្ជាក់ជូននៅក្នុងឯកសារ E223/3 ត្រង់កថាខណ្ឌ៤ លើកលែងតែឯកសារដែលពាក់ព័ន្ធទៅនឹងអង្គហេតុគោលនយោបាយសហករណ៍ក្រុម និងតួនាទីរបស់ជនជាប់ចោទ ដែលអង្គជំនុំជម្រះនឹងកំណត់កាលបរិច្ឆេទធ្វើសវនាការនាពេលសមស្របខាងមុខ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង១២:០៣ នាទី ដល់ម៉ោង ១៣:៣៨ នាទី)*

[១៣:៣៨:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត រេយ៉ន័រ៖**

សូមអរគុណលោកប្រធាន។ លោកប្រធានមុនពេលឈប់សម្រាក លោកប្រធានបានបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការបង្ហាញអំពីឯកសារអំពីសហឧក្រិដ្ឋកម្មរួមនោះនឹងត្រូវធ្វើនៅដំណាក់កាលក្រោយ។ ដូច្នេះ ខ្ញុំសូមសួរដោយការគោរពថា តើអង្គជំនុំជម្រះអាចផ្តល់គោលការណ៍ណែនាំមកខាងខ្ញុំក៏ដូចជាសហការីនានាថា តើអង្គជំនុំជម្រះបានធ្វើការសម្រេចណាមួយដែរឬទេទាក់ទងនឹងការធ្វើបទបង្ហាញទាក់ទងទៅនឹងតួនាទីរបស់ជនជាប់ចោទ។

[១៣:៣៩:៤៦]

នេះគឺជាប្រធានបទនៃបទបង្ហាញដែលខាង ក.ស.ព ទទួលបានការស្នើសុំឱ្យធ្វើបទបង្ហាញនៅសប្តាហ៍ក្រោយ។ ក្នុងពេលឥឡូវនេះ យើងកំពុងតែធ្វើការរៀបចំទាក់ទងទៅនឹងការធ្វើបទបង្ហាញនៅសប្តាហ៍ក្រោយព្រមទាំងធ្វើការសម្រេចថា តើតួនាទីរបស់ជនជាប់ចោទមានលក្ខណៈបែបណាដែរ។ ដូច្នេះ យើងសូមឱ្យអង្គជំនុំជម្រះជួយផ្តល់ជាគោលការណ៍ណែនាំ ឬក៏សេចក្តីណែនាំមកខាង ក.ស.ព ដើម្បីឱ្យយើងអាចធ្វើការពិចារណា ហើយយើងក៏សូមថ្លែងអំណរគុណជាមុន ប្រសិនបើអង្គជំនុំជម្រះអាចផ្តល់នូវគោលការណ៍ណែនាំ ឬក៏សេចក្តីណែនាំណាមួយពាក់ព័ន្ធទៅនឹងបញ្ហាអស់ទាំងអស់នេះ។ សូមអរគុណលោកប្រធាន។

[១៣:៤០:៣៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤១:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ តាមការពិភាក្សាក្នុងចំណោមចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះមានផែនការថានៅក្នុងសប្តាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងកំណត់នូវកាលវិភាគសម្រាប់ធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-565 នៅថ្ងៃចន្ទ ប្រសិនបើជនជាប់ចោទ នួន ជា លះបង់សិទ្ធិមិនមានវត្តមានរបស់គាត់នៅក្នុងកិច្ចដំណើរការសវនាការពិភាក្សាដេញដោល ស្តាប់សក្ខីកម្មសាក្សីរូបនេះ នេះជាចំណុចទី១។ ហើយដោយឡែកចំណុចទី២ គឺសវនាការលើការដាក់ឯកសារពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ អង្គជំនុំជម្រះមានការពិភាក្សាថា នឹងកំណត់កាលវិភាគសម្រាប់ធ្វើសវនាការដាក់បង្ហាញឯកសារនេះដោយតំណាងសហព្រះរាជអាជ្ញាហើយនិងភាគី នៅថ្ងៃពុធសប្តាហ៍

ក្រោយ។ ហើយបញ្ហាទាំងអស់នេះគឺមិនទាន់ជាក់ច្បាស់ទេ វាអាស្រ័យទៅព័ត៌មានដែលអង្គជំនុំជម្រះនឹងទទួលបានពីខាងមេធាវីការពារក្តីលោក នួន ជា។ ហើយអង្គជំនុំជម្រះនឹងជម្រាបជូនទៅសហព្រះរាជអាជ្ញា ក៏ដូចជាភាគីពាក់ព័ន្ធតាមសារអេឡិចត្រូនិកនៅថ្ងៃស្អែកវេលារសៀលនៅពេលដែលអង្គជំនុំជម្រះបានទទួលបានព័ត៌មានពេញលេញអំពីបញ្ហានេះ។

[១៣:៤៣:៥៣]

**លោក ឃីត រេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមថ្លែងអំណរគុណចំពោះការផ្តល់ព័ត៌មាននេះ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ពីព្រឹកមិញមុននឹងចប់ពេលសម្រាកបាយថ្ងៃត្រង់លោកប្រធានបាននិយាយអំពីការបង្ហាញឯកសារអំពីតួនាទីរបស់ជនជាប់ចោទ និងសហឧក្រិដ្ឋកម្មរួម។ ហើយអម្បាញ់មិញលោកប្រធានបានបញ្ជាក់អំពីសវនាការទៅលើតួនាទីរបស់ជនជាប់ចោទដែលនឹងអាចធ្វើនៅសប្តាហ៍ក្រោយ។ សំណួរដែលយើងខ្ញុំចង់សុំឲ្យលោកប្រធានបញ្ជាក់ថែមទៀតថា តើសវនាការនៅលើសហឧក្រិដ្ឋកម្មរួមនឹងប្រព្រឹត្តទៅពេលជាមួយគ្នាលើសវនាការបង្ហាញឯកសារ លើតួនាទីរបស់ជនជាប់ចោទ ឬក៏ពេលផ្សេងពីគ្នា? សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បញ្ហាគឺវាអាចមានការវិវត្តបន្តិចដោយសារបញ្ហាព្រឹកមិញគឺវាមានព័ត៌មានដូច្នេះ។ អ៊ីចឹងហើយបានជាយើងខ្ញុំបានជម្រាបជូនអំពីបញ្ហាថា លទ្ធភាពមិនទំនងជាមិនទាន់អាចធ្វើបានទេ លើឯកសារពាក់ព័ន្ធជាមួយនឹងអង្គហេតុទាំងពីរ គឺគោលនយោបាយសហឧក្រិដ្ឋកម្មរួម និងតួនាទីរបស់ជនជាប់ចោទ។ ប៉ុន្តែបន្ទាប់ពីយើងសម្រាកទៅឃើញថា អង្គជំនុំជម្រះបានទទួលព័ត៌មានពីតំណាងសហព្រះរាជអាជ្ញា ថាខ្លួនមានលទ្ធភាពនៅក្នុងការរៀបចំនូវឯកសារពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ ហើយដែលអាចនឹងដំណើរការដាក់ឯកសារពាក់ព័ន្ធទៅនឹងអង្គហេតុនេះនៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងថ្ងៃពុធសប្តាហ៍ក្រោយ។ នេះគឺមានការបត់បែនមួយ ដើម្បីឲ្យបង្កើនល្បឿននូវកិច្ចដំណើរការនីតិវិធីសវនាការរបស់យើងឲ្យបានទៅមុខ។

[១៣:៤៦:០៣]

បញ្ហាអង្គហេតុគោលនយោបាយ សហឧក្រិដ្ឋរួម គឺអង្គជំនុំជម្រះមិននិយាយទេ បានន័យថា

អ្វីដែលយើងបានជម្រាបជូនដល់ភាគីកាលពីព្រឹកមិញថា អង្គជំនុំជម្រះនឹងកំណត់ពេលវេលាសមស្រប សម្រាប់ធ្វើការងារនេះនៅពេលក្រោយ។ ទំនងជាអាចប្រើប្រាស់ពេលវេលាមួយសមស្រប ដើម្បីឲ្យភាគីពាក់ព័ន្ធហ្នឹងគឺរៀបចំឯកសារពាក់ព័ន្ធនឹងការងារនេះសព្វគ្រប់ អង្គជំនុំជម្រះនឹងកំណត់កាលបរិច្ឆេទ និងជម្រាបជូនភាគីជាក្រោយ។ អ៊ីចឹងបញ្ហានេះដាក់ដោយឡែកពីគ្នារវាងបញ្ហាទាំងពីរនេះ។ អ៊ីចឹងអង្គជំនុំជម្រះដែលលើកមានបំណងនៅក្នុងការរៀបចំឲ្យភាគីដាក់បង្ហាញឯកសារនៅថ្ងៃពុធហ្នឹង តែតួនាទីរបស់ -- ពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទតែប៉ុណ្ណោះ។

សូមអញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រមជាទីគោរព ហើយនិងភាគីទាំងអស់ជាទីគោរព។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ថានៅក្នុងក្របខ័ណ្ឌនៃព័ត៌មានទាក់ទងទៅនឹងសុខភាពរបស់កូនក្តីរបស់ខ្ញុំ ក៏គួរតែគិតផងដែរ ពីព្រោះថាខ្ញុំមានតែលិខិតបញ្ជាក់លើកមុន ដែលចុះនៅថ្ងៃទី២២ មករា អ៊ីចឹងគួរតែ យើងគប្បីឲ្យមានព័ត៌មានច្បាស់ដើម្បីឲ្យដឹងថាតើសប្តាហ៍ក្រោយ តើយើងធ្វើយ៉ាងម៉េច? ព្រោះថាខ្ញុំមានតែលិខិតបញ្ជាក់ចុះពីថ្ងៃទី២២ មករា នោះទេ។ អ៊ីចឹងខ្ញុំមិនដឹងថាតើកូនក្តីរបស់ខ្ញុំមានលទ្ធភាពចូលរួមក្នុងសវនាការនេះដែរឬក៏អត់ទេលោកប្រធាន? ដូច្នេះ ខ្ញុំសូមទាញចំណាប់អារម្មណ៍អស់លោកស្រីចៅក្រមលើចំណុចនេះ។

[១៣:៤៨:១០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការទាញចំណាប់អារម្មណ៍នេះ។ ខ្ញុំសូមជម្រាបជូនថា តាមព័ត៌មានដែលអង្គជំនុំជម្រះទទួលបាន ហើយអង្គជំនុំជម្រះមិនពន្លាតទៅដល់ការងារលើបញ្ហាសុខភាពរបស់លោក ខៀវ សំផន នេះ ដោយសារការទទួលបានព័ត៌មាននេះ អង្គជំនុំជម្រះរំពឹងថាលោក ខៀវ សំផន នឹងបានចេញពីមន្ទីរពេទ្យឆាប់ៗខាងមុខនេះ ទំនងជានៅក្នុង នៅចុងសប្តាហ៍នេះ។ ហើយប្រសិនបើបញ្ហាលោក ខៀវ សំផន នៅតែប្រឈមនៅក្នុងការសម្រាកទទួលការព្យាបាលនៅមន្ទីរពេទ្យនោះ គឺអង្គជំនុំជម្រះនឹងជម្រាបជូននូវពេលជាមួយគ្នាតែម្តង ព្រោះលទ្ធភាពនេះវាផ្ទុយពីការរំពឹងទុករបស់អង្គជំនុំជម្រះ។ អង្គជំនុំជម្រះដែលមិនបាននិយាយនេះ ដោយសារអង្គជំនុំជម្រះផ្អែកលើព័ត៌មានមួយចំនួនពាក់ព័ន្ធជាមួយនឹងស្ថានភាពសុខភាពរបស់គាត់ដែលវិវត្តន៍ល្អប្រសើរ ដែលខាងគ្រូពេទ្យរំពឹងថាគាត់នឹងមានលទ្ធភាពអាចចាកចេញ

ពីមន្ទីរពេទ្យនៅចុងសប្តាហ៍។ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះមិនពាក់ព័ន្ធបញ្ហានេះជាមួយគាត់។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ កិច្ចដំណើរការនីតិវិធីក្នុងការអនុវត្តគោលការណ៍សវនាការចំពោះអង្គជំនុំជម្រះនៅតែប្រកាន់ខ្ជាប់ជាដាច់ខាតនៅក្នុងកិច្ចដំណើរការសវនាការទៅតាមវិធានដែលផ្ទៃក្នុងដែលបានកំណត់។

បើសិនជាលទ្ធភាពនេះវាផ្ទុយពីការរំពឹងទុក នោះគឺយើងនឹងដោះស្រាយតាមកាលៈទេសៈ និងតាមស្ថានភាពជាក់ស្តែង ថាតើយើងធ្វើវិធីណា ដោះស្រាយវិធីណា ដែលសមស្រប ដែលត្រឹមត្រូវតាមច្បាប់នោះ។

[១៣:៤៩:៥៥]

បាទ ជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅមេធាវីការពារក្តី ដែលចាប់ផ្តើមពីក្រុមមេធាវីការពារក្តីលោក នួន ជា មុនភាគី អំ! មុនមេធាវីពីរក្រុមទៀត ដើម្បីមានឱកាសក្នុងការធ្វើអត្ថាធិប្បាយ ឬជំទាស់ចំពោះបណ្តាឯកសារជាគន្លឹះទាំងឡាយដែលតំណាងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខបានដាក់កន្លងមកនេះ ដែលពាក់ព័ន្ធទៅនឹងអង្គហេតុដូចអង្គជំនុំជម្រះបានជម្រាបជូនកាលពីព្រឹកមិញ។ ហើយដោយឡែក គឺបន្ថែមផងដែរលើការដាក់បង្ហាញឯកសារពាក់ព័ន្ធជាមួយនឹងអង្គហេតុរចនាសម្ព័ន្ធកងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលបង្ហាញដោយក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

ហើយទន្ទឹមនឹងនេះ ក៏ក្រុមមេធាវីការពារក្តីក៏អាចដាក់បង្ហាញឯកសារគន្លឹះនានា ដែលពាក់ព័ន្ធនឹងអង្គហេតុ ដូចអង្គជំនុំជម្រះបានជម្រាបជូននៅក្នុងកថាខណ្ឌ៤ នៃអនុស្សរណៈ E223/3 លើកលែងតែអង្គហេតុពាក់ព័ន្ធជាមួយនឹងគោលនយោបាយសហខក្រិដ្ឋកម្មរួម ហើយនិងតួនាទីរបស់ជនជាប់ចោទដែលយើងកំណត់ធ្វើសវនាការនៅពេលក្រោយ។

សូមអញ្ជើញ!

[១៣:៥១:២៥]

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រីចៅក្រម។ ដូចដែលយើងបានបញ្ជាក់រួចមកហើយ យើងនឹងផ្តល់នូវការអង្កេតផ្ទាល់ខ្លួន ហើយយើងនឹងដាក់នូវការជំទាស់ជាលាយលក្ខណ៍អក្សរ។ នៅពេលដែលយើងបានទទួលការណែនាំពីកូនក្តីរបស់ខ្ញុំ នៅដំណាក់កាលនេះយើងមិនមានការជំទាស់ ឬក៏មិនមានការសង្កេតអ្វីនោះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនក្រុមមេធាវីការពារក្តីលោក អៀង សារី។

**លោក ម៉ែខល កាណាវាស៖**

សូមជម្រាបលោកប្រធាន លោក លោកស្រីចៅក្រម។ សូមជម្រាបសួរដល់ភាគីទាំងអស់ ហើយសូមជម្រាបសួរដល់អស់លោក លោកស្រីទាំងអស់។

ជាដំបូងខ្ញុំមានមតិ ជាបឋមខ្ញុំគិតថា ខ្ញុំមិនចំណាយពេលច្រើននោះទេ ប្រហែលជាប្អូនប្រាំនាទីប៉ុណ្ណោះទាក់ទងទៅនឹងឯកសារ។ ខ្ញុំសោកស្តាយដែលខ្ញុំចាំបាច់ត្រូវតែលើកពីបញ្ហាសុខភាពរបស់កូនក្តីខ្ញុំ ប៉ុន្តែខ្ញុំត្រូវតែធ្វើដូច្នេះ។ អ្វីដែលខ្ញុំបានដឹងនៅក្នុងពេលសម្រាកអាហារថ្ងៃត្រង់ គឺថាលោកវេជ្ជបណ្ឌិត គឹម សមសាន្ត ដែលជាវេជ្ជបណ្ឌិតព្យាបាលថ្ងៃនេះ បានប្រាប់មកខាងយើងគឺមកប្រាប់មកលោក មូស្សេនី ដែលជាអ្នកគ្រប់គ្រងសំណុំរឿងថា គាត់មិនអាចវាយតម្លៃថាតើកូនក្តីរបស់យើងនឹងអាច ឬមិនអាចតាមដានកិច្ចដំណើរការនីតិវិធី បើទោះបីជាកូនក្តីរបស់យើងគាត់ភ្ញាក់ដឹងខ្លួនក៏ដោយ។ គាត់ថ្ងៃនេះ គឺថាគាត់គេងលក់ភាគច្រើន ដោយសារតែយប់មិញគាត់មិនបានគេង។

[១៣:៥៣:២០]

នៅពេលដែលលោក មូស្សេនី បានសួរវេជ្ជបណ្ឌិត ថាតើបានដាក់អ្វីនៅក្នុងរបាយការណ៍នោះ? គឺថាដោយសារផ្អែកទៅលើសមត្ថភាពរបស់គាត់ គាត់មិនប្រាកដនៅក្នុងការចេញរបាយការណ៍នៅក្នុងបញ្ជាក់របាយការណ៍ ថាតើកូនក្តីរបស់យើងមានលក្ខណៈបែបណា? គឺថាគាត់មិនអាចបញ្ជាក់ឱ្យបានច្បាស់លាស់ទៅក្នុងរបាយការណ៍នោះទេ លុះត្រាតែគាត់បានជួបជាមួយក្រុមប្រឹក្សាវេជ្ជបណ្ឌិត ដើម្បីពិភាក្សាថាតើត្រូវវាយការណ៍បែបណានៅក្នុងរបាយការណ៍នោះ។

ខ្ញុំយល់ឃើញថា នេះជាការមួយគួរឱ្យចាប់អារម្មណ៍មែនទែន។ ព្រោះថាអ្វីដែលយើងប្រាប់មកយើងកាលពីរសៀលម្សិលមិញ ដែលរបាយការណ៍បាននិយាយថា កូនក្តីរបស់ខ្ញុំអាចតាមដានកិច្ចដំណើរការនីតិវិធីពីខាងក្រោម។ ប៉ុន្តែប្រសិនបើវេជ្ជបណ្ឌិតមិនមានលទ្ធភាពក្នុងការបញ្ជាក់ថាកូនក្តីរបស់យើងអាច ឬមិនអាចតាមដានកិច្ចដំណើរការនីតិវិធី ថាតើហេតុអ្វីបានក៏គាត់អាចចេញរបាយការណ៍ ដែលបញ្ជាក់ថានៅខាងក្រោមហ្នឹងកូនក្តីយើងខ្ញុំអាចដាមដានកិច្ចដំណើរការនីតិវិធី។ ហេតុអ្វីក៏វេជ្ជបណ្ឌិតដែលត្រូវបានកោះហៅឱ្យសួរក្តីរបស់ខ្ញុំចាំបាច់ត្រូវការនូវការបញ្ជាពីក្រុមប្រឹក្សាវេជ្ជបណ្ឌិតដែលត្រូវបញ្ជាក់ថាតើអ្វីដែលគាត់ត្រូវវាយការណ៍ទៅក្នុងរបាយការណ៍នោះ។

[១៣:៥៤:៥០]

នៅក្នុងន័យមួយទៀត គឺវាហាក់ដូចជាបង្ហាញថា លោកវេជ្ជបណ្ឌិតហ្នឹងហាក់ដូចជាប្រើព័ត៌មាន

មិនត្រឹមត្រូវទៅដល់អង្គជំនុំជម្រះ ដែលលោក អៀង សារី អាចតាមដានកិច្ចនីតិវិធី។ ព្រោះថាវេជ្ជបណ្ឌិតមិនទទួលការបណ្តុះបណ្តាលផ្នែកវិជ្ជាជីវៈដើម្បីឲ្យធ្វើការតាមដានឲ្យបានល្អ គឺថាគាត់គ្រាន់តែមានសមត្ថភាពក្នុងការព្យាបាលជំងឺប៉ុណ្ណោះ។

ខ្ញុំយល់ឃើញថាតាមអ្វីដែលព្រះរាជអាជ្ញាបានបញ្ជាក់គឺថា វេជ្ជបណ្ឌិតអាចធ្វើការវាយតម្លៃប្រសិនបើមិនដូច្នោះទេ របាយការណ៍ប្រចាំថ្ងៃនោះគឺជារបាយការណ៍ដែលធ្វើឲ្យមានការយល់ច្រឡំ។ នេះគឺជាគោលជំហររបស់យើង ហើយយើងបញ្ជាក់ថា កូនក្តីរបស់យើងមិនមានលទ្ធភាពក្នុងការតាមដានកិច្ចដំណើរការនីតិវិធីនោះទេ។ ខ្ញុំទុកឲ្យអង្គជំនុំជម្រះជាអ្នកសម្រេចទៅលើបញ្ហាទាំងអស់នេះ។ នេះគឺជាការសង្កេតរបស់ខ្ញុំទាក់ទងទៅនឹងបញ្ហាសុខភាពរបស់កូនក្តីខ្ញុំ។

[១៣:៥៦:០០]

ទាក់ទងទៅនឹងឯកសារ ខ្ញុំមានចំណុចបីដែលចង់លើកឡើងមកបង្ហាញ។ ហើយខ្ញុំលើកឡើងនូវចំណុចនេះដោយចាប់ផ្តើមនិយាយថា ខ្ញុំរួមបញ្ចូលនូវការអង្កេត ក៏ដូចជាមតិរបស់ខ្ញុំដែលយើងបានធ្វើរួចមកហើយទាក់ទងទៅនឹងសវនាការឯកសារ ក៏ដូចជាអ្វីដែលបានបង្ហាញនៅថ្ងៃនេះ។ ដូច្នេះ ខ្ញុំនឹងមិននិយាយឲ្យបានលម្អិតនៅថ្ងៃនោះទេ។ ព្រោះថាយើងបាននិយាយរួចមកហើយអំពីប្រភេទនៃឯកសារដែលយើងនិយាយដូចជាអត្ថបទព័ត៌មាន ឬក៏អត្ថបទរបស់រដ្ឋាភិបាលនានា។

ទាក់ទងទៅនឹងឯកសាររបស់ព្រះរាជអាជ្ញា ខ្ញុំចង់និយាយអំពីនិយាយពីរជាក់លាក់។ ទី១ គឺឯក-សារ D199/26.2.132 ឯកសារដែលមានលេខ E3/2666 នេះគឺជាឯកសារដែលបានពង្រាងឡើងលោក ហ្សង់រីស្តូហ្វីន ដែលជាឯកអគ្គរាជទូតបារាំងប្រចាំប្រទេសថៃ ហើយកាលពីម្សិលមិញគឺព្រះរាជអាជ្ញាគាត់បានលើកយកឯកសារនេះមករៀបរាប់យ៉ាងវែងអន្លាយ។ ហើយឯកសារនេះរៀបចំឡើងដោយលោកឯកអគ្គរដ្ឋទូត ដែលរៀបរាប់អំពីលោកឧត្តមសេនីយ៍ សរ ប៊ុន។ ហើយក៏រៀបរាប់អំពីទស្សនៈរបស់លោកឯកអគ្គរដ្ឋទូត ក៏ដូចជាភាពត្រឹមត្រូវអំពីព័ត៌មានដែលលោកឧត្តមសេនីយ៍ សរ ប៊ុន បានផ្តល់ទៅគាត់។

[១៣:៥៨:១៤]

ឯកសារនេះធ្វើនៅថ្ងៃ២៣ ខែ៦ ឆ្នាំ១៩៧៦ គឺថាតាមអ្វីដែលគាត់បានឮ ឬក៏តាមពាក្យចចាមអារ៉ាមឯកសារនេះគឺបានរៀបចំឡើងយដោយមានលក្ខណៈរណ្តំណែងណងចុងចួនគ្នា។ ហើយបានរៀបចំនូវផ្នែកនីមួយៗឲ្យបានល្អឥតខ្ចោះ។ ដូច្នេះ ក្នុងករណីនេះមេធាវីការពារក្តីពិបាកក្នុងការវាយតម្លៃអំពីលក្ខណៈ

នៃឯកសារនេះ លុះត្រាតែលោកឧត្តមសេនីយ៍ហ្នឹង ឬក៏លោកអគ្គរដ្ឋទូតអាចចូលមកផ្តល់សក្ខីកម្មនៅទីនេះបាន។ ដូច្នេះយើងស្នើថា ឯកសារប្រភេទនេះមិនគួរត្រូវបានពិចារណាដោយអង្គជំនុំជម្រះនោះឡើយ។ ព្រោះថាឯកសារនេះវាបំផ្លើស។ ដូច្នេះហើយវាជាឯកសារមួយដែលថាជនជាប់ចោទមិនអាចតទល់ជាមួយនឹងសាក្សី។ វាគ្រាន់តែជាពាក្យចចាមអារ៉ាម ហើយឯកសារនេះផ្ទាល់គឺជាឯកសារដែលមានលក្ខណៈចចាមអារ៉ាមប៉ុណ្ណោះ។

[១៣:៥៩:៣៩]

អង្គជំនុំជម្រះគួរតែមិនពិចារណាទៅលើឯកសារនេះ ប៉ុន្តែយ៉ាងណាក៏ដោយឯកសារនេះត្រូវបានព្រះរាជអាជ្ញាកត់ត្រាចូលទៅក្នុងកំណត់ហេតុរួចទៅហើយ។ ខ្ញុំយល់ច្បាស់ថា ខ្ញុំយល់ច្បាស់អំពីនីតិវិធីដូច្នេះខ្ញុំចង់បញ្ជាក់ចុងក្រោយថា ប្រសិនបើចង់ប្រើប្រាស់ទៅលើឯកសារប្រភេទនេះ ឬក៏ឯកសារបែបនេះសូមមេត្តាមានការប្រុងប្រយ័ត្នឲ្យបានខ្ពស់ ហើយលុះត្រាតែយើងអាចបញ្ជាក់ដោយឯករាជ្យទៅលើឯកសារហ្នឹង ដោយបញ្ជាក់ជាមួយសាក្សីដើម្បីឲ្យសាក្សីមកទីនេះដើម្បីបញ្ជាក់ថាឯកសារហ្នឹងជាឯកសារពិត។ ឯកសារ ឬក៏ភស្តុតាងទី២ ដែលខ្ញុំចង់និយាយគឺជារូបភាពវីដេអូ ដែលយើងបានឃើញកាលពីម្សិលមិញ គឺវីដេអូលេខ១២ គឺវីដេអូ E186.1R ប្រសិនបើខ្ញុំនិយាយខុស ខ្ញុំគិតថាព្រះរាជអាជ្ញាអាចកែតម្រូវទៅលើបញ្ហានេះ គឺចាប់ផ្តើមនៅ --

[១៤:០១:០០]

គឺចាប់ផ្តើមនៅ ០១:២២:០:៥៨ (ស៊ីក) ខ្ញុំសូមកោតសរសើរដល់អ្នកផលិតករដែលបានផលិតនូវវីដេអូនេះ។ ហើយប្រហែលជាមេរៀន ឬក៏ជាអ្វីមួយដើម្បីការិយាល័យសហព្រះរាជអាជ្ញា ឬក៏សម្រាប់អ្នកស៊ើបអង្កេតក្នុងការដោះស្រាយជាមួយសាក្សីដើម្បីផ្តល់នូវសក្ខីកម្ម។ ហើយសាកសួរថាតើគេផលិតវីដេអូហ្នឹងតាមរបៀបណា? ហើយហេតុអ្វីបានជាសហព្រះរាជអាជ្ញាផ្អែកទៅលើវីដេអូនេះ? ហើយត្រូវបង្ហាញមកវិញជាភស្តុតាង ហើយស្នើសុំដល់អង្គជំនុំជម្រះដើម្បីទទួលយកខ្សែវីដេអូនេះ។ ប្រសិនបើមិនធ្វើដូច្នេះទេ មិននាំយកនូវសាក្សីដែលបានឃើញ ឬក៏ដែលបានបញ្ជាក់នូវសាក្សី -- នូវសក្ខីកម្មដើម្បីឲ្យយើងអាចសួរដេញដោលបាននោះទេ ខ្ញុំគិតថាវា -- គឺថាជនជាប់ចោទមិនអាចទទួលបាននូវការធានាតាមសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញបាននោះទេ។

[១៤:០២:១៤]

ខ្ញុំគិតថាភស្តុតាងជាឯកសារបែបនេះមិនគួរត្រូវបានពិចារណានោះឡើយ លុះត្រាតែមានសាក្សី

ដែលដើរតួនៅក្នុងខ្សែវីដេអូនោះ ខ្ញុំមិនចង់និយាយពីផលិតករទេ គឺសាក្សីដែលដើរតួក្នុងវីដេអូហ្នឹងមក បង្ហាញខ្លួននៅទីនេះដើម្បីផ្តល់ភស្តុតាង។ ប្រសិនបើៗគ្រាន់តែចង់ទទួលយកឯកសារនេះ ដូចដែលព្រះរាជអាជ្ញាបានធ្វើ ឬក៏ខាងសហចៅក្រមស៊ើបអង្កេតបានធ្វើ គឺថាគ្រាន់តែទុកឲ្យខាងសហចៅក្រមស៊ើបអង្កេតជាអ្នកពឹងផ្អែកទៅលើឯកសារនេះ ឬក៏ឲ្យអ្នកស៊ើបអង្កេតខាង ឌី.ស៊ី.ខេម ទទួលយកវាជាបញ្ហាមួយ។ ប៉ុន្តែចំពោះអង្គជំនុំជម្រះមិនគួរផ្តល់ទម្ងន់ ឬក៏ផ្តល់តម្លៃទៅលើឯកសារនោះទេ លុះត្រាតែអាចបញ្ជាក់ដោយឯករាជ្យបាន។

ចំណុចមួយទៀត គឺខ្ញុំចង់និយាយទាក់ទងទៅនឹងខាងដើមបណ្តឹងរដ្ឋប្បវេណីគឺចម្លើយ -- គឺឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី លុះត្រាតែដើមបណ្តឹងរដ្ឋប្បវេណីគាត់អាចមកទីនេះ ដើម្បីផ្តល់សក្ខីកម្មបាន ហើយគាត់នឹងអាចផ្តល់នូវចម្លើយទៅអង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន ខ្ញុំមិនមានអ្វីបន្ថែមទៀតទេ ហើយយើងក៏មិនមានឯកសារភស្តុតាង ឬក៏ឯកសារនានាដើម្បីបង្ហាញនៅក្នុងដំណាក់កាលនេះដែរ។ សូមអរគុណលោកប្រធាន។

[១៤:០៣:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកស្រីមេធាវីការពារក្តីឲ្យលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិននិយាយវែងឆ្ងាយទេ ខ្ញុំនឹងធ្វើការកត់សម្គាល់ទៅលើឯកសារដែលសហព្រះរាជអាជ្ញាបានបង្ហាញ ហើយនិងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញ។ ក៏ប៉ុន្តែជាបឋម ខ្ញុំសូមកែប្រែកំហុសមួយដែលមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ខ្ញុំចាប់អារម្មណ៍លើកំហុសនេះ។ ហើយខ្ញុំក៏សូមអភ័យទោសផងដែរ អំពីសំណាក់អ្នកបកប្រែជាភាសាអង់គ្លេស ពីព្រោះថាពេលខ្លះខ្ញុំស្តាប់ខុសទៅឃើញថា ដោយសារពីមូលហេតុដោយសារខ្ញុំនិយាយលឿនពេកអង្គាល់ពីថ្ងៃទី២២ មករាមុននេះ ខ្ញុំនិយាយលឿនពេក អ៊ីចឹងដូច្នេះ ខ្ញុំនឹងព្យាយាមនិយាយឲ្យបានយឺតបំផុត។ ដើម្បីឲ្យការនិយាយរបស់ខ្ញុំកាលពីថ្ងៃទី២២ មករា នេះច្បាស់លាស់នោះ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំជាភាសាបារាំង ខ្ញុំនិយាយយ៉ាងដូច្នេះ កាលពីថ្ងៃ២២ នោះ គឺថាប្រហែលជាម៉ោងដប់ប្រាំជាង ប្រហែលជាដប់ប្រាំម្ភៃ -- ម្ភៃប្រាំ -- ម្ភៃប្រាំបីសឺហ្គុង។ កាលនោះខ្ញុំនិយាយអំពីអនុស្សរណៈ E170 នៅក្នុងកថាខណ្ឌទី៤ ដែលមានសរសេរថា “ពុំមានពេលវេលាសម្រាប់ឆ្លើយរបស់ភាគីនោះទេ ឆ្លើយតបទៅនឹងឯកសារដែលគេបង្ហាញ”។

[១៤:០៥:៤០]

ហើយខ្ញុំសូមរៀបរាប់ឡើងវិញជាភាសាបារាំង។ ចំព្រោះក្រុម ខៀវ សំផន គឺយើងយល់ពីសវនាការលើឯកសារយ៉ាងដូច្នេះហើយ អាស្រ័យហេតុដូច្នេះហើយបានជាយើងរហូតដល់ថ្ងៃនេះ យើងនៅតែប្រកាន់យកគោលជំហររបស់យើងដដែល។ ហើយបន្តទៀត តដូចតទៅនេះ ក៏ប៉ុន្តែខ្ញុំសូមរំឭកត្រង់ចំណុចនេះ កាលពីព្រឹកមិញខ្ញុំបាននិយាយថា យើងពិតជាយល់អំពីការអត្ថាធិប្បាយដែលអនុញ្ញាតឱ្យជនជាប់ចោទធ្វើការអត្ថាធិប្បាយ ក៏ប៉ុន្តែមិនមែនជាមេធាវីនោះទេ។ ហើយខ្ញុំសូមបញ្ជាក់អំពីការយល់ច្រឡំរហូតដល់ពេលនេះ ក៏ប៉ុន្តែនៅពេលដែលយើងអានអនុស្សរណៈនោះ យើងមានចំណាប់អារម្មណ៍ពិសេសមួយ។ ខ្ញុំចង់បញ្ជាក់កន្លែងនេះ ត្រង់ថានៅក្នុងជាភាសាអង់គ្លេសនោះ បាននិយាយថា យើងមិនបានអាននៃអនុស្សារណៈហ្នឹង ក៏ប៉ុន្តែតាមពិតយើងអានអនុស្សារណៈហ្នឹង។ ដូច្នេះ អ្វីដែលយើងយល់នៅក្នុង យើងយល់អនុស្សរណៈនុ៎ង គឺថាយើងតាមរយៈការផ្លាស់ប្តូរអ៊ីម៉ែលជាមួយមន្ត្រីច្បាប់ជាន់ខ្ពស់។ ខ្ញុំសូមបញ្ជាក់ម្តងទៀត ឥឡូវនេះខ្ញុំ គេប្រាប់ខ្ញុំថា ខ្ញុំនិយាយលឿនទៀតហើយ គឺថាខ្ញុំសូមបញ្ជាក់ កាលពីថ្ងៃ២២ មករា ឆ្នាំ២០១២ នេះ នៅពេលដែលខ្ញុំឆ្លើយទៅនឹងលោកចៅក្រម ឡាវែន៍ អំពីស្ថានភាពអង្គជំនុំជម្រះយើងនេះតាមរយៈសេចក្តីសម្រេចរបស់លោកស្រីចៅក្រម ខាតវ៉ាយថ៍ ខ្ញុំបានឆ្លើយតបថា "ពិតណាស់ថ្ងៃនេះខ្ញុំយល់ច្បាស់ជាងថ្ងៃមុន ហើយខ្ញុំយល់ខុសពីអ្វីដែលយើងបានយល់អនុស្សរណៈនោះកាលពីថ្ងៃមុន"។ ដូច្នេះសូមឱ្យអង្គជំនុំជម្រះយល់ច្បាស់ទាំងអស់គ្នាជាភាសាបារាំង និងភាសាអង់គ្លេស។ គឺថាការ -- ឥឡូវនេះ ខ្ញុំធ្វើការកត់សម្គាល់ហើយៗ ខ្ញុំសូមចូលមកធ្វើការកត់សម្គាល់អំពីឯកសារដែលសហព្រះរាជអាជ្ញាបានបង្ហាញ និងសហមេធាវីនាំមុខបានបង្ហាញ។

[១៤:០៨:០២]

ការកត់សម្គាល់ទី១ ជាការពិតណាស់ដែលការកត់សម្គាល់របស់លោកមេធាវី កាណាវាសទាក់ទងទៅនឹងឯកសារដែលគាត់បានរៀបរាប់អម្បាញ់មិញនេះ គឺថាការកត់សម្គាល់គាត់ត្រឹមត្រូវណាស់ហើយយើងគាំទ្រទាំងស្រុង។ ខ្ញុំសូមរំឭកផងដែរត្រង់ចំណុចនេះ គឺថាសេចក្តីសម្រេច 96/7 លោកបានសម្រេចអំពីទម្ងន់តម្លៃភស្តុតាងរបស់អ្នកដែលមិនបានមកផ្តល់សក្ខីកម្មនៅទីនេះ។ ដូច្នេះ ខ្ញុំសូមឱ្យអង្គជំនុំជម្រះអនុវត្តសេចក្តីសម្រេចរបស់ខ្លួន។

ខ្ញុំសូមកត់សម្គាល់ផងដែរ នេះជាចំណុចទី២របស់ខ្ញុំ គឺថានៅក្នុងក្របខ័ណ្ឌនៃការបង្ហាញឯកសាររបស់ខ្លួន សហព្រះរាជអាជ្ញាឱ្យគាត់មានវិធីសាស្ត្រដ៏ប៉ិនប្រសប់ គាត់បានបញ្ចូលពេលណាមួយនោះ

គាត់បញ្ចូលសម្រង់វីដេអូ។ ដូច្នេះ ខ្ញុំសូមធ្វើការកត់សម្គាល់ជាក់លាក់មួយលើរបៀបធ្វើនេះ ហើយគឺថា ចំណុចនេះបង្កឲ្យមានបញ្ហាពាក់ព័ន្ធនឹងការបង្ហាញភស្តុតាង។ ខ្ញុំសូមពន្យល់ គឺថាគាត់បានបង្ហាញឯកសារ ជាមួយកាលបរិច្ឆេទដែលបង្ហាញកាលបរិច្ឆេទ ប្រសិនបើខ្ញុំមិនច្រឡំទេ គឺថាគាត់បានពន្យល់ខ្លឹមសារ ហើយយើងមិនដឹងថាគេថតនៅពេលណាផងវីដេអូទាំងអស់នេះ ហើយយើងមិនដឹងថាកាលៈក្នុងកាលៈ ទេសៈណា ហើយខ្ញុំមិនដឹងថាតើមានទំនាក់ទំនងពិតប្រាកដដែរឬទេជាមួយ -- ត្រឹមត្រូវដែរឬទេជាមួយ នឹងពាក្យពេចន៍ដែលនិយាយនៅក្នុងកុនឯកសារទាំងអស់នោះ។ ដូច្នេះ របៀបបង្ហាញឯកសារយ៉ាងដូច្នេះ នៅក្នុងសាលសវនាការមិនអាចទទួលយកបានទេ ពីព្រោះថាការបញ្ចូលព័ត៌មាន ដែលព័ត៌មានរបស់អ្នក ដែលថតកុននោះ ដោយមិនបង្ហាញពីកាលៈទេសនៃការថតនោះ ហើយភាគីមិនមានព័ត៌មានទាក់ទងនឹង កាលៈទេសៈ នេះនោះទេ។

[១៤:១០:២៥]

ដូច្នេះ ខ្ញុំសូមបញ្ជាក់សង្កត់ធ្ងន់ ថានៅពេលដែលយើងឃើញសាកសពនៅលើដី យើងមិនដឹងថា មនុស្សទាំងអស់នោះត្រូវបានសម្លាប់ក្នុងកាលៈទេសៈណានោះទេ។ ហើយត្រង់ចំណុចនេះ ខ្ញុំសូមជម្រាប ទៅព្រះរាជអាជ្ញាផងដែរ គាត់និយាយថាពេលនោះគាត់មិនចង់បង្ហាញអំពីការអត្ថាធិប្បាយលើរូបសាក សពទាំងអស់នោះទេ។ ក៏ប៉ុន្តែ ត្រង់ចំណុចនេះហើយដែលធ្វើឲ្យយើងមិនដឹងថាកាលៈទេសៈណាដែល មនុស្សទាំងអស់នោះត្រូវបានគេសម្លាប់ ហើយនៅលើដីនេះ។ អ៊ីចឹង នេះចង្អុលឲ្យឃើញថាខ្សែវីដេអូ ទាំងអស់នេះវាភ្ជាប់ជាមួយនឹងឯកសារណា? ផ្សាភ្ជាប់នឹងឯកសារណា? ដូច្នេះយើងសូមជំទាស់លើ របៀបបង្ហាញនេះ ពីព្រោះថា វាជាការបង្ហាញឯកសារដោយសហព្រះរាជអាជ្ញា ការចោទប្រកាន់។

[១៤:១១:៣១]

ចំណុចមួយទៀតទាក់ទងវីដេអូដែរ លោកមេធាវី កាណាវាស បានលើកឡើងថា វីដេអូហ្នឹងដូច ឈ្មោះថា ចំណងជើងថា "ថ្ងៃមួយនៅពោធិ៍ជ្រៃ"។ ជាសម្រង់ភាពយន្តឯកសាររបស់លោក ថេត សម្បត្តិ ដែលចាក់ផ្សាយនៅថ្ងៃទី២៣ មករា។ ដូចគ្នាដែរ ដូចជាចម្លើយជាលាយលក្ខណ៍អក្សររបស់អ្នកដែលមិន បានមកផ្តល់សក្ខីកម្មនៅទីនេះដែរ គឺថាមិនមានការសួរតទល់គ្នា ព្រោះថានៅពេលដែលមានការចោទ សំណួរ។ ទោះបីជាមានការចោទសំណួរទៅសាក្សីក៏ដោយ ក៏ប៉ុន្តែគាត់ជាអ្នកកាសែត ហើយយើងមិន អាចសួរអ្នកទាំងអស់នោះនៅទីនេះបាន។

អ៊ីចឹងគឺថាមានចម្លើយខ្លះជាការឆ្លើយព្រាវៗរបស់សាក្សីទាំងអស់នោះ អ្នកដែលគេសម្ភាសទាំង

អស់នោះ។ អ៊ីចឹងម្សិលមិញនេះ នៅម៉ោង ១៥:៤២ យើងមានពួនិយាយអំពីការរំលោភមនុស្សជាដើម។ អ៊ីចឹង សូមជៀសវាងការបង្ហាញឯកសាររបៀបនេះនៅក្នុងសាលសវនាការ។ ខ្ញុំសូមសង្កត់ធ្ងន់លើចំណុចនេះ ព្រោះថាបើសិនជាមិនមានសាក្សីមកបង្ហាញខ្លួននៅទីនេះទេ ដើម្បីឲ្យគេសួរដេញដោលទេ តុលាការត្រូវតែពិនិត្យលើភស្តុតាងជាឯកសារនេះយ៉ាងប្រយ័ត្នបំផុត គឺថា ធ្វើឧទាហរណ៍ដូចជាម្សិលមិញនេះ មនុស្សម្នាក់ដែលនិយាយពីការចងចាំរបស់ខ្លួនកាលពីខ្លួននៅអាយុ ចន្លោះពី១០ ទៅ១២ឆ្នាំនោះ នេះចោទជាបញ្ហា ព្រោះថាជាភស្តុតាងបទឧក្រិដ្ឋ។ ដូច្នេះ ក្នុងប្រធានបទនេះ ខ្ញុំសូមបញ្ចប់ការកត់សម្គាល់ខ្ញុំត្រឹមប៉ុននេះ ប៉ុន្តែកូនក្តីខ្ញុំនឹងអាចមានគំនិតយោបល់ខ្លះទៀត។

ហើយខ្ញុំសូមអភ័យទោសផងដែរ អំពីសំណាក់អ្នកបកប្រែ ដោយសារខ្ញុំនិយាយលឿន ហើយចេះតែភ្លេចថាខ្លួននិយាយលឿន។

[១៤:១៣:៤៣]

**ប្រធានអង្គជំនុំ៖**

អរគុណ។ បាទ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក យឺត ឆេយ័ន័រ៖**

បាទ សូមគោរពលោកប្រធាន ខ្ញុំមានចំណុចតែពីរបីទេ។ ទី១ សូមថ្លែងអំណរគុណដល់មេធាវីការពារក្តីដែលបានរៀបរាប់នូវបទបង្ហាញយ៉ាងជំនាញ ហើយច្បាស់ហើយគឺថាដូចដែលខ្សែវីដេអូបង្ហាញ ហើយ ស្ទីវិន ប៊ិលប៊ីក ទោះជាយ៉ាងណាក៏ដោយ បានជម្រាបជូនអង្គជំនុំជម្រះរួចមកហើយ។

ខ្ញុំយល់ស្របទាំងស្រុងជាមួយនឹងការលើកឡើងនឹងភាពទទួលយកបាន និងទម្ងន់នៃឯកសារទាំងអស់នេះដែលអាចនឹងទទួលយកបាន ដូចដែលលោកស្រីចៅក្រម ខាតវ៉ាយថ៍ បានពន្យល់ពីម្សិលមិញ ហើយថាភាពទទួលយកបាន និងទម្ងន់នៃឯកសារគឺថា វាខុសគ្នាទៅនឹងទស្សនទានតាមផ្លូវគតិយុត្ត។ ហើយយើងខ្ញុំយល់ឃើញថាអង្គជំនុំជម្រះនឹងទទួលយកពាក់ព័ន្ធនឹងការវាយតម្លៃអំពីទម្ងន់នៃភស្តុតាងនេះ។ ដូចដែលយើងបានលើកឡើងពីសម្រេចពីលោកវរសេនីយ៍ ទាក់ទងទៅនឹងដែលថា តើវាមានប្រយោជន៍ និងស៊ីសង្វាក់គ្នាទៅនឹង ដំណើររឿងដទៃទៀតដែរឬក៏អត់នោះ។

[១៤:១៥:០២]

ខ្ញុំសូមលើកឡើងចំណុចមួយ ដែលលោក ម៉ៃខល កាណាវាស បានលើកឡើង គាត់បានលើកជាសំណួរថា តើនឹងមានភស្តុតាងស៊ីសង្វាក់គ្នា គឺភស្តុតាងដែលបង្ហាញនៅក្នុងឯកសារនេះ។ ឧទាហរណ៍

អង្គជំនុំជម្រះអាចនឹងមានយល់ឃើញនៅក្នុងទិដ្ឋភាពតាមរយៈខ្សែវីដេអូ នូវមន្ត្រីរាជការរបស់ លន់ នល់ ដែលបានឈរនៅក្នុងបរិវេណតុលាការ នៅក្នុងទីធ្លាមួយនៅថ្ងៃ១៧ មេសា។ ប្រហែលជា បើសិនជាអាចកោះហៅមកភស្តុតាង ប្រហែលជាពួកគេអាចនឹងជម្រាបជូនតុលាការ ថាតើមានអ្វីកើតឡើងទៅដល់អ្នកទាំងអស់ មន្ត្រីរដ្ឋការទាំងអស់នោះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី និងអង្គសវនាការទាំងមូល។

ខ្ញុំមានពីរចំណុចសម្រាប់ជាការចាប់អារម្មណ៍ជាបឋម ពាក់ព័ន្ធនឹងអ្វីដែលលោក អៀង សារី អ៎! មេធាវីរបស់លោក អៀង សារី លោក ម៉ៃខល កាណាវាស លើកពាក់ព័ន្ធទៅនឹងទង្វើ -- អាកប្បកិរិយារបស់លោកគ្រូពេទ្យ។ ខ្ញុំបានគិតថានេះយើងគួរតែពិនិត្យទៅលើ ថាតើគ្រូពេទ្យដែលបានចាត់តាំងមកនេះ ពិនិត្យលោក អៀង សារី គាត់មានក្របខ័ណ្ឌសមត្ថកិច្ចរបស់គាត់ត្រឹមណា និងបែបបទការងាររបស់គាត់ត្រឹមណា ដើម្បីវិនិច្ឆ័យថាតើគាត់ធ្វើត្រឹមត្រូវឬទេ ពាក់ព័ន្ធនឹងចម្លើយដែលគាត់បានឆ្លើយចំពោះក្រុមការងាររបស់លោក អៀង សារី។

[១៤:១៦:៤៧]

ចំណុចទី២ គឺពាក់ព័ន្ធទៅនឹងទាំងលោក អៀង សារី ក៏ដូចជា អ៎! មេធាវីរបស់លោក អៀង សារី ក៏ដូចជាលោកស្រីមេធាវី អង់តា ហ្គីសសេ បានលើកអំពីថា ភស្តុតាងដែលជាវីដេអូ ដែល ឬក៏ -- ដែលនៅក្នុងមានសាក្សី ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងនោះ មិនអាចយកមកធ្វើជាការបានមិនមានតម្លៃតាមផ្លូវតុលាការទេ ប្រសិនបើមិនបាន មិនមានលទ្ធភាពក្នុងការហៅគាត់មក ឬក៏មិនបានហៅពួកគាត់មក។ ពាក់ព័ន្ធនឹងចំណុចនេះ ខ្ញុំគ្រាន់តែធ្វើការសូមកត់សម្គាល់ថា លទ្ធភាពគួរតែមានជាការពិតដល់មេធាវីរបស់ជនជាប់ចោទនៅក្នុងការកោះហៅ ហើយជាពិសេសសម្រាប់ដើមបណ្តឹងរដ្ឋ-ប្បវេណី គឺដើមបណ្តឹងរដ្ឋប្បវេណី គឺអាចមានលទ្ធភាពនៅក្នុងការមកស្រាយបំភ្លឺអំពីអ្វីដែលគាត់បានសរសេរនៅក្នុងសេចក្តីថ្លែងការណ៍របស់គាត់ ប្រសិនបើមេធាវីរបស់ជនជាប់ចោទមានបំណងនៅក្នុងការហៅគាត់មកបំភ្លឺបន្ថែម។ ដូច្នេះ គាត់នឹងអាចអញ្ជើញមក។ បាទ សូមអរគុណ។ ហើយលោកស្រី

មេធាវី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត នឹងមានមតិបន្តិចបន្ថែមទៀត។ សូមអរគុណលោកប្រធាន។

[១៤:១៨:២៦]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំគ្រាន់តែចង់បន្ថែមពីរបីម៉ាត់ទេ ឆ្លើយតបទៅនឹងខាងការពារក្ដី ជាពិសេសគឺថា មេធាវីការពារក្ដីលោក អៀង សារី ទាក់ទងទៅនឹងឯកសារដែលមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានបង្ហាញ។ គឺថាជាការកត់សម្គាល់ទូទៅមួយ ខ្ញុំសូមសួរថា តើមានមធ្យោបាយណាមួយ ឬក៏មុខវិជ្ជាណាមួយ ដើម្បីកុំយើងត្រឡប់មកនិយាយអំពីអ្វី រឿងដែលយើងធ្លាប់និយាយហើយ ហើយនិងនិយាយច្រើនដងហើយ ធ្លាប់បានសម្រេចច្រើនដងហើយ។ ខ្ញុំនិយាយអំពីការសម្បថរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រោះយើងបានផ្លោះប្ដូរសារណាគ្នា ហើយអង្គជំនុំជម្រះក៏បានចេញសេចក្ដីសម្រេចផងដែរត្រង់ចំណុចនេះ។

ទាក់ទងទៅនឹងការសម្បថរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនេះ ខ្ញុំសូមជម្រាបជូនថា វាមិនចាកប្រធានទាំងស្រុង មិនសមស្របទាំងអស់ ដែលនិយាយថាដើមបណ្ដឹងរដ្ឋប្បវេណីមិនស្បថ ហើយដោយសារខ្លួនមិនស្បថនោះ អ៊ីចឹងមិនអាចចាត់ទុកជាតម្លៃភស្តុតាងបាន។ ខ្ញុំចង់និយាយថា មិនមែនថាគេមិនស្បថនោះ បានន័យថាគេកុហកនោះទេ មនុស្សទាំងជាង៤.០០០នាក់នេះ ឬក៏មនុស្សហ្នឹងក៏ចេះតែស្រមើស្រមៃរវើរវាយ។

[១៤:១៩:៤១]

ដូច្នេះយើងអាចៗស្ដាប់ចម្លើយសាក្សី ដែលស្បថរាប់ខែរាប់ឆ្នាំ ដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនស្បថនៅទីនេះ គឺថាយើងអាចទាញយកភាពស្មោះត្រង់ ទទួលយកភាពស្មោះត្រង់របស់ដើមបណ្ដឹងរដ្ឋ-ប្បវេណីបានដែរ។ អ៊ីចឹងខ្ញុំសូមគូសបញ្ជាក់ថា បទបញ្ញាផ្ទៃក្នុងយើងនៅទីនេះ គឺថាវាខុសស្រឡះពីអ្វីដែលសហភាតារបស់ខ្ញុំគិតនោះ គឺថាមិនបានចែងថា ផ្ដល់តម្លៃសមស្របណាមួយទៅចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ដោយសារតែខ្លួនមិនបានស្បថនោះទេ ក៏ប៉ុន្តែផ្ទុយទៅវិញ កាលដែលដើមបណ្ដឹងរដ្ឋប្បវេណីមិនស្បថនេះ គឺថាជាការគោលការណ៍របស់ច្បាប់ស៊ីវិលឡដែលយើងអនុវត្តនៅទីនេះ។ ដូច្នេះ ខ្ញុំសោកស្ដាយដែលលើកឡើងរឿងនេះម្ដងទៀត។

នៅទីបញ្ចប់ខ្ញុំសូមជម្រាបរំឭកថា អម្បាញ់មិញសហភាតាខ្ញុំត្អូញត្អែរលើពាក្យចចាមអារ៉ាមនៃពាក្យ

សក្ខីកម្មមួយចំនួន។ ក៏ប៉ុន្តែចំពោះដើមបណ្តឹងរដ្ឋប្បវេណីគឺថា សម្តែងចេញមកដោយពិតប្រាកដ គឺថា ចន្លោះឆ្នាំ៧៥-៧៩នេះ គាត់បានឃើញ គាត់បានឆ្លងកាត់នូវព្រឹត្តិការណ៍ដែលខ្ញុំបានអានកាលពីព្រឹកមិញនេះ។ ដូច្នេះនេះជាការកត់សម្គាល់របស់ខ្ញុំ។ ខ្ញុំសូមបញ្ចប់ត្រឹមនេះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវី ម៉ែខល កាណាវាស!

[១៤:២១:១៥]

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ទាក់ទងទៅនឹងវេជ្ជបណ្ឌិត ខ្ញុំសូមអញ្ជើញឲ្យអង្គជំនុំជម្រះកោះហៅវេជ្ជបណ្ឌិតដើម្បីសាកសួរអំពីគុណវុឌ្ឍិរបស់គាត់ ដែលធ្វើឲ្យមានចោទជាបញ្ហាទៅដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនេះ។

ទាក់ទងទៅនឹងយោបល់មួយដែលលើកឡើងដោយសហមេធាវីនាំមុខជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីថា មេធាវីការពារក្តីគួរតែហៅអ្នកទាំងអស់នេះ។ ខ្ញុំសូមរំឭកថាមេធាវីមិនមានបន្ទុកនៃភស្តុតាងអ្វីទេនេះ។ នេះជាគោលការណ៍ជាសាកលដែលអ្នកទាំងអស់មានសិទ្ធិ មានទាំងនៅក្នុងតុលាការកម្ពុជាដែលអាចអនុវត្តទាំងនៅតុលាការកម្ពុជា តុលាការអន្តរជាតិ។ មិនមែនយើងខ្ញុំជាអ្នកទៅសម្រេចកោះហៅអ្នកទាំងអស់នេះទេ ប្រសិនណាជាព្រះរាជអាជ្ញាឬតំណាងដើមបណ្តឹងរដ្ឋប្បវេណីចង់កោះហៅនោះគឺថាស្នើសុំអង្គជំនុំជម្រះ។

តាមការអនុវត្តជាក់ស្តែង ក្នុងការអនុវត្តល្អបំផុត គឺត្រូវកោះហៅសាក្សីទាំងអស់នេះឲ្យមកផ្តល់ភស្តុតាង ហើយត្រូវមានការសួរតទល់ដេញដោល យើងខ្ញុំមិនលើកត្រឹមថា អ្វីដែលត្រូវកោះហៅមកត្រូវចាត់ទុកថាជាចម្លើយដែលត្រូវទទួលយកបានទេ ប៉ុន្តែទី១ គឺត្រូវតែមានដែនកម្រិតរបស់វា កាលណាពាក់ព័ន្ធទៅនឹងភរនីយហេតុនៃភស្តុតាងនោះ។ ដូច្នេះយើងមានការខុសគ្នារវាងភាពអាចទទួលយកបាន និងភរនីយហេតុនៃភស្តុតាងពាក់ព័ន្ធទៅនឹងឯកសារភស្តុតាងណាមួយនោះ ជាពិសេសពាក់ព័ន្ធទៅនឹងចៅក្រមជាតិតែម្តង។

[១៤:២៣:០០]

ទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី គឺថាយើងខ្ញុំមានសិទ្ធិក្នុងការលើកជាយោបល់។ ខ្ញុំមិនយល់ថា ហេតុអ្វីបានជាយើងគ្រាន់តែបំពេញការងាររបស់យើងប៉ុណ្ណោះមិនបាននោះ។ វាជាការពិតនៃ

ជីវិតនៃជីវិតរស់នៅ ជាការពិតដែលយើងត្រូវតែនិយាយថា នៅពេលដែលអ្នកណាម្នាក់ផ្តល់ភស្តុតាងដោយមិនបានស្បថនោះ ជាការពិតណាស់ ជាស្វ័យប្រវត្តិគឺថាវាមានតម្លៃនៃភស្តុតាងតិចមែនទែន។ ដោយសារអី? ដោយសារការផ្តល់ភស្តុតាងនេះ គឺថាមិនបានស្បថ។ ដូច្នេះបើមិនបានស្បថបែបនេះ វាអាចនឹងទទួលរហូតទៅដល់ការដាក់ទទួលទណ្ឌកម្មទៀត ដោយសារថាវាអាចនឹងកុហក។ ត្រូវតែសួរដេញដោលថា តើនៅក្នុងប្រព័ន្ធច្បាស់ស៊ីវិល គឺថាត្រូវតែស្បថ។ ជនជាប់ចោទនេះស្ថិតនៅក្នុងការជំនុំជម្រះដែលអនុវត្តច្បាប់ប្រព័ន្ធស៊ីវិល។ ដូច្នេះគាត់ ដូច្នេះបើមិនស្បថ គាត់អាចនឹងកុហក ដោយសារតែអាងមានឯកសិទ្ធិ ឬក៏យ៉ាងណានោះ។ ហើយវាអាចនឹងនាំឱ្យអង្គជំនុំជម្រះពិបាកនឹងស្វែងយល់ និងស្វែងរកឱ្យច្បាស់ថា វាស្មោះត្រង់ ឬក៏អត់នោះ។

[១៤:២៤:០៩]

ខ្ញុំសូមលើកឱ្យបានច្បាស់ជូនលោកស្រីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីថា យើងខ្ញុំមិនដែលលើកឡើងថា សក្ខីកម្មរបស់គេមិនមានតម្លៃនោះទេ ចម្លើយរបស់គាត់មិនមានតម្លៃនោះទេ។ ក៏ប៉ុន្តែថាតើចម្លើយហ្នឹងផ្តល់ដោយមានការស្បថ ឬក៏មិនបានស្បថនៅឡើយទេ។ ២) បើសិនជាដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវមកឱ្យសាកសួរនោះ គឺត្រូវឱកាសឱ្យមេធាវីការពារក្តីចោទសួរ។ ដោយសារថាចម្លើយរបស់គាត់នោះគឺថាមិនទាន់បានសួរតទល់នូវឡើយទេ។ ដូច្នេះនៅក្នុងនាមឱ្យលោក អៀង សារី យើងទទួលស្គាល់នូវសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ យើងខ្ញុំទទួលស្គាល់ថា គាត់មានសិទ្ធិផ្តល់នូវចម្លើយ ក៏ប៉ុន្តែដោយសារថាមិនបានស្បថ។ ដូច្នេះ អង្គជំនុំជម្រះបានអនុញ្ញាតនឹងត្រូវពិចារណា ដោយពិចារណាទៅលើភស្តុតាងទាំងអស់ដទៃទៀតផង។ ដូច្នេះខ្ញុំសូមបន្តទៅទៀតថា ជាមួយសហការីរបស់ខ្ញុំលោក អាង ឧត្តម គាត់នឹងបន្ត ដើម្បីលើកជាសំណើនៅពេលណាដែលថាត្រូវឱ្យធ្វើបែបណាៗ ឱ្យស្បថ ឬក៏យ៉ាងណា។ សូមអរគុណ។

[១៤:២៥:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣០:១៤]

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្ត ដើម្បីឱ្យមានភាពច្បាស់លាស់លើបញ្ហាគ្រូពេទ្យ ដែលទទួលពិនិត្យថែទាំសុខភាពរបស់ជនជាប់ចោទនៅ អ.វ.ត.ក នេះ ដែលមេធាវីការពារក្តីលោក អៀង សារី លើកម្តងហើយម្តង

ទៀត។ ហើយបញ្ហានេះអង្គជំនុំជម្រះបានសម្រេចជាច្រើនលើករួចមកហើយ មានទាំងសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរផង ប៉ុន្តែបញ្ហានៅតែមាន។ ហើយបញ្ហាមួយទៀតគឺ បញ្ហាដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ថាតើត្រូវស្បថ ឬក៏មិនចាំបាច់ស្បថនេះក៏បានជជែកពិភាក្សា និងសម្រេចរួចហើយដែរ។ តាមប្រព័ន្ធច្បាប់ដែលអនុវត្តនៅទីនេះ គឺស៊ីវិលឡ ដែលមានក្រមនីតិវិធីព្រហ្មទណ្ឌខ្មែរ ហើយនិងវិធានផ្ទៃក្នុងដែលអនុវត្តនៅ អ.វ.ត.ក ប៉ុន្តែនៅតែមានបញ្ហានេះដដែល។

ដើម្បីឲ្យដោះស្រាយបញ្ហាឲ្យច្បាស់លាស់ អង្គជំនុំជម្រះសូមផ្ដល់វេទិកាភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីបញ្ជាក់បំភ្លឺបន្ថែមលើបញ្ហាទាំងពីរនេះឲ្យភាគី និងសាធារណជនជ្រាបឲ្យបានច្បាស់។

សូមអញ្ជើញលោកស្រីចៅក្រម!

[១៤:៣១:៣៤]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ពាក់ព័ន្ធទៅនឹងមតិដែលមេធាវី អៀង សារី បានលើកឡើងពាក់ព័ន្ធទៅនឹងស្ថានភាពសុខភាពរបស់កូនក្ដីគាត់ក្នុងបច្ចុប្បន្ននេះ បញ្ហាទី១ គឺថា ខ្ញុំសូមបញ្ជាក់ឡើងវិញថា អង្គជំនុំជម្រះបានសម្រេចច្បាស់លាស់រួចមកហើយ យ៉ាងហោចណាស់ក៏បានពីរដងដែរ កាលពីពេលកន្លងមក ថាវេជ្ជបណ្ឌិតដែលទទួលព្យាបាល គឺត្រូវរាយការណ៍ដោយផ្ទាល់មកអង្គជំនុំជម្រះសាលាដំបូងតែអំពីការប្រែប្រួលសំខាន់ៗណាមួយរបស់ជនជាប់ចោទតែប៉ុណ្ណោះ។

វាមិនមានប្រយោជន៍អ្វីនោះទេ ក្នុងការឲ្យអ្នកច្បាប់ ឬក៏អ្នកដែលមិនមានជំនាញវេជ្ជសាស្ត្រទៅសួរនាំដេញដោលវេជ្ជបណ្ឌិតនោះឡើយ។ ព្រោះថាវេជ្ជបណ្ឌិតគាត់រាយការណ៍មកផ្ទាល់មកអង្គជំនុំជម្រះរួចហើយ។ ហើយជាចុងក្រោយ ហើយនិង ខ្ញុំគិតថា ដោយសារតែមិនមានការយល់ទៅលើពាក្យកាតព្វកិច្ច ដែលជាភាសាអង់គ្លេសមានន័យថា វេជ្ជបណ្ឌិតអាចចេញនូវរបាយការណ៍ដែលត្រឹមត្រូវ។

[១៤:៣៣:០០]

ចំពោះការពិភាក្សាអំពីបញ្ហាថាតើដើមបណ្ដឹងរដ្ឋប្បវេណីត្រូវស្បថ ឬមិនស្បថនោះ ព្រមទាំងផលវិបាកនៃការស្បថ ឬមិនក៏ស្បថនេះ យើងបានពិភាក្សាជាច្រើនដងរួចមកហើយ។ ហើយអង្គជំនុំជម្រះបានដឹងច្បាស់លាស់អំពីការទទួលខុសត្រូវដែលបានធ្វើឡើង។ ហើយយើងមិនចង់ឲ្យមានការលើក

ឡើងនូវទឡ្ហីករណ៍ដដែលៗ ឬក៏លើកឡើងជាញឹកញាប់បែបនេះនោះទេ។

លោកប្រធាន ខ្ញុំគិតថាមានបញ្ហាមួយទៀតចុងក្រោយ ទាក់ទងទៅនឹងការសម្រេចកាលបរិច្ឆេទសម្រាប់សប្តាហ៍ក្រោយ។ តើលោកប្រធានចង់ឲ្យខ្ញុំបញ្ជាក់ ឬមួយក៏យ៉ាងដូចម្តេចដែរលោកប្រធាន?

ទាក់ទងទៅនឹងការកំណត់កាលបរិច្ឆេទសប្តាហ៍ក្រោយ យើងបានបញ្ជាក់រួចមកហើយថា ប្រធានបទនៃស្ថានភាពសុខភាពរបស់ជនជាប់ចោទ នួន ជា ហើយនិងចេតនារបស់គាត់ក្នុងការលះបង់ ឬមិនលះបង់ក្នុងការចូលរួមសវនាការ យើងនឹងស្តាប់សាក្សីដែលមានលេខរហស្សនាមត្រូវបានហៅពីមុននេះមកហើយនៅថ្ងៃចន្ទ។

ក្នុងករណីដែលយើង -- អានេះគឺក្នុងករណីដែលលោក ខៀវ សំផន ត្រូវបានគេបញ្ជូនចេញពីមន្ទីរពេទ្យ ហើយគាត់អាចចូលរួមនៅសប្តាហ៍ក្រោយបាន។

[១៤:៣៤:៣០]

យើងនឹងបន្តសវនាការលើឯកសារភស្តុតាងនៅថ្ងៃពុធ ហើយនឹងធ្វើបទបង្ហាញដោយខាងព្រះរាជអាជ្ញាទៅលើប្រធានបទតួនាទីរបស់ជនជាប់ចោទ ហើយយើងផ្អាកនៅថ្ងៃស្អែក ហើយនិងសប្តាហ៍ក្រោយក៏យើងអត់មានសវនាការដែរ ដោយសារតែវាជាថ្ងៃបុណ្យជាតិ។

ខ្ញុំគិតថា ខ្ញុំបញ្ជាក់បានច្បាស់រួចអស់ទៅហើយលោកប្រធាន តើមានអ្វីដែលត្រូវបន្ថែមទៀតដែរឬទេ?

[១៤:៣៤:០៣]

*(សម្រាករយៈពេលខ្លី)*

[១៤:៣៥:២៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីចៅក្រមដែលបានជម្រាបជូនទៅភាគីពាក់ព័ន្ធ ព្រមទាំងផ្តល់ព័ត៌មានទៅសាធារណជនបានយ៉ាងក្បោះក្បាយរួចហើយ លើបញ្ហាដែលបាននឹងកំពុងតែប្រឈមម្តងហើយម្តងទៀតនាពេលនេះ ហើយព្រមទាំងលទ្ធភាពនៃការធ្វើការសវនាការនៅសប្តាហ៍ក្រោយផង។ ហើយឥឡូវនេះបញ្ហាដែលគ្រោងនឹងលើកយកមកពិភាក្សាសម្រាប់សវនាការថ្ងៃនេះឃើញថាអស់ហើយ។ ហេតុដូច្នេះអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី២៨ ខែមករា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ ដោយមានលក្ខខណ្ឌនៃបញ្ហាពាក់ព័ន្ធ

ទៅនឹងស្ថានភាពសុខភាពជនជាប់ចោទ ដែល និងជនជាប់ចោទមួយរូបដែលគាត់មានបញ្ហាសុខភាពដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ ថាតើគាត់លះបង់សិទ្ធិ ឬយ៉ាងណានោះ ដែលអង្គជំនុំជម្រះសង្ឃឹមថា មេធាវីលោក នួន ជា នឹងប្រឹងប្រែង និងផ្តល់ព័ត៌មានឱ្យអង្គជំនុំជម្រះឱ្យបានឆាប់រហ័សនៅថ្ងៃស្អែកដើម្បីឱ្យអង្គជំនុំជម្រះហ្នឹងមានលទ្ធភាពក្នុងការជូនព័ត៌មានទាំងអស់នេះទៅភាគីបានជ្រាបច្បាស់អំពីការសវនាការដែលយើងគ្រោងធ្វើនៅថ្ងៃចន្ទ សប្តាហ៍ក្រោយនេះ។

ដូច្នេះសវនាការថ្ងៃនេះផ្អាកត្រឹមនេះ។ បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៤:៣៧ នាទី)*